ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ពិភពលោកអន្លង់វែង
- ឥណ្ឌូនេស៊ីទស្សនកិច្ច «បណ្ណាល័យសម្ដេចម៉ែ»

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា
លេខ២៥១ ខែវិច្ឆិកា ឆ្នាំ២០២០

# ស្វែងរកការពិត

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៥១ ខែវិច្ឆិកា ឆ្នាំ២០២០


## មាតិកា

### សំបុត្រ


◆ ពិភពលោកអន្លង់វែង ..........................១


### ផ្នែកឯកសារ


◆ ចាន់ ម៉ុន ហៅ គុលលេខាតំបន់ ៤២ ......... ៤


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


◆ ឥណ្ឌូនេស៊ីទស្សនកិច្ច «បណ្ណាល័យ.............. ៨

◆ ស៊ើរពេញមួយជីវិតជួបតែសង្គ្រាម .......... ១២

◆ ផ្លែន រុន ជនជាតិស្មៀងនៅក្នុងភូមិអញ្ចាញ .. ១៧

◆ ភូមិអញ្ចាញ ឬ ភូមិកោះថ្ម ក្នុងរបប ......... ១៩

◆ យី ធា អតីតពេទ្យខ្មែរក្រហម.............. ២២

◆ ខ្ញុំនៅសង្ឃឹមថានឹងបានជួបបងប្រុស..........២៥

◆ ប៊ុន ម៉ាច៖ អន្លង់វែង គឺជាលំនៅដ្ឋាន...... ២៨

◆ ប្រវត្តិ និងបទឧក្រិដ្ឋរបស់ អោម អាន ...... ៣០

◆ ស្នូរគ្រាប់កាំភ្លើង.............................៣៤


### ផ្នែកច្បាប់


សាលក្រមសំណុំរឿង០០២/០២ ............... ៤១


### ផ្នែកវេទិកាសាធារណៈ


វេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជា ......៥០


### ផ្នែកស្រាវជ្រាវរកគ្រួសារ


«ដេះដង់ធូលី» រឿងរ៉ាវចេញពីប្រជាជនថ្មី ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

អ៊ុក ស៊ីវត្ថា ៖ គ្រូបង្រៀន........................ ៥៤

ជួន លាង រួច ៖ គ្រូបង្រៀន...................... ៥៦

ហុក ឆាយ ស្រេង ៖ ប៉ូលីស ...................... ៥៦

ឡៅ អ៊ុំ ៖ គ្រូបង្រៀន............................ ៥៨




ស្ពានមេទឹក ឬស្ពានជ័យជម្នះ ដែលសង់ពីបេតុង ស្ថិតនៅក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ៣៧៥៣.មប្រក

ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ៖** ឆាំង យុ, ប៉ាង ពីវ័ន្ត, វេនី ខកហៀល, ផាត ចាន់សុនីតា, សុខ វណ្ណៈ, រី លក្ខិណា, គាត ស្រីខ្លួន, ហ៊ាន ពិសី, មេក វិន, សួត វិចិត្រ

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ហូ ថុនា,ដារ៉ាវរដ្ឋ មេត្តា, អ៊ុន សុដាវី **អ្នកបកប្រែ៖** ហួយ លីយាង

**និពន្ធនាយកទូទៅ៖** សោម ប៊ុនថន **ជំនួយការនិពន្ធនាយក៖** ហូ ថុនា

**ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង



Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ពិភពលោកអន្លង់វែង

ឆាំង យុ



*បុរសម្នាក់កំពុងស្រាវសំណាញ់នៅបឹងអន្លង់វែង ឬបឹងតាម៉ុក ស្ថិតនៅក្នុងស្រុកអន្លង់វែងខេត្តឧត្តរមានជ័យ។ ភ្នំខាងក្រោយបុរសនោះគឺជាជួរភ្នំដងរែកដែលលាតសន្ធឹងនៅភាគខាងជើងនៃប្រទេសកម្ពុជា និងជាព្រំប្រទល់រវាងប្រទេសកម្ពុជា និងប្រទេសថៃ។ (អ៊ូច មករា/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

លាតសន្ធឹងតាមបណ្តោយព្រំដែនកម្ពុជា-ថៃ, អន្លង់វែង ផ្តល់នូវឱកាសនិងបទពិសោធន៍ ក្នុងការស្វែងយល់អំពីប្រវត្តិសាស្ត្រជាលក្ខណៈបុគ្គល តាមរយៈការសន្ទនាជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ការធ្វើទស្សនកិច្ច ទៅកាន់តំបន់ប្រវត្តិសាស្ត្រចំណាស់នានា និងការស្វែងយល់អំពីតំបន់នេះ ដែលស្ថិតនៅក្នុងភាពដាច់សង្វែងនៅឡើយ។

ប្រសិនបើប្រៀបធៀបជាមួយនឹងរាជធានីភ្នំពេញ ឬគោលដៅទេសចរណ៍ដ៏ចម្បងនៅក្នុងខេត្តសៀមរាប ចំណុចពិសេសរបស់អន្លង់វែង ដែលបម្រើដល់ការសិក្សាអំពីប្រវត្តិសាស្ត្រ បរិស្ថាន ឬវប្បធម៌មិនស្តែងចេញមកភ្លាមៗទេ។ ក៏ប៉ុន្តែទីតាំងរបស់អន្លង់វែង ក៏ដូចជាប្រវត្តិសាស្ត្រនិងភូមិសាស្ត្រនៃស្រុកនេះ គឺជាធនធានដ៏វិសេសវិសាលមួយ។ អន្លង់វែង ស្ថិតនៅក្នុងរយៈចម្ងាយកៀកទៅនឹងប្រាង្គប្រាសាទមួយចំនួនដែលមានភាពលេចធ្លោ និងជាកេរមរតកនៃអាណាចក្រអង្គរពីបុរាណកាលព្រមទាំងជាតំបន់បេតិកភណ្ឌវប្បធម៌ពិភពលោកទៀតផង។ អន្លង់វែង ស្ថិតនៅរយៈចម្ងាយប្រមាណ១ម៉ោង

និង៣០នាទីតែប៉ុណ្ណោះ ប្រសិនបើធ្វើដំណើរតាមរថយន្ត ពីខេត្តសៀមរាប និងតំបន់ប្រាសាទព្រះវិហារដែលជាបេតិកភណ្ឌពិភពលោក និង២ម៉ោងនិង៣០នាទីទៅ៣ម៉ោង ពីប្រាសាទកោះកេរ ដែលស្ថិតនៅដាច់ពីគេនិងជាអតីតរាជធានីនៃអាណាចក្រខ្មែរ។

ក្រៅពីប្រវត្តិសាស្ត្រពីបុរាណកាលតំបន់អន្លង់វែង ត្រូវបានស្គាល់ជាទូទៅថា ជាតំបន់តស៊ូចុងក្រោយរបស់ចលនាខ្មែរក្រហម និងជាចំណុចផ្តោតមួយដ៏សំខាន់នៃគោលនយោបាយឈ្នះ-ឈ្នះរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងនាមជាទីតាំងតស៊ូ តំបន់នេះត្រូវបានធ្វើប្រតិបត្តិការជាទីស្នាក់ការកណ្តាលរបស់មេដឹកនាំដែលមានឈ្មោះអសោចមួយចំនួនរបស់ចលនាតស៊ូខ្មែរក្រហម ដឹកនាំដោយ ប៉ុល ពត។ តំបន់នេះ ប្រមូលផ្តុំទៅដោយកេរដំណែលជាច្រើនបន្សល់ទុកពីចលនាតស៊ូ បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត ក្នុងនោះរួមមាន ប្រវត្តិសាស្ត្រនានាទាក់ទងនឹងស្តេចត្រាញ់នៅមូលដ្ឋានម្នាក់ឈ្មោះ តាម៉ុក។ ដោយសារតែអន្លង់វែងមានសារសំខាន់ក្រៃលែងចំពោះភាពស្វិតស្វាញនៃចលនាតស៊ូរបស់ខ្មែរក្រហម តំបន់នេះគឺជាទីតាំងនិមិត្តរូបតំណាងឲ្យជ័យជម្នះចុងក្រោយនៃគោលនយោបាយឈ្នះ-ឈ្នះរបស់រាជរដ្ឋាភិបាលកម្ពុជា។

គោលនយោបាយឈ្នះ-ឈ្នះ គឺជាយុទ្ធវិធីនយោបាយជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាព ក្នុងការបំបែកកងទ័ពខ្មែរក្រហម តាមរយៈកត្តាជំរុញទឹកចិត្តផ្នែកសេដ្ឋកិច្ចនិងនយោបាយ ដែលរុញច្រានទៅកាន់សន្តិភាពនិងសមាហរណកម្មសាជាថ្មីទៅក្នុងសង្គមកម្ពុជា។ គោលនយោបាយឈ្នះ-ឈ្នះ តែងតែពិចារណាលើបរិបទនយោបាយរបស់ប្រទេសកម្ពុជា ក៏ប៉ុន្តែក្នុងកាលៈទេសៈផ្សេងៗគ្នា គោលនយោបាយនេះ តំណាងឲ្យកត្តាដ៏សំខាន់មួយនៅក្នុងប្រវត្តិសាស្ត្រសន្តិសុខក្នុងតំបន់អាស៊ីអាគ្នេយ៍។ ក្នុងកាលៈទេសៈជាច្រើន គោលនយោបាយនេះ មិនទាន់ត្រូវបានធ្វើការសិក្សាស្រាវជ្រាវឲ្យបានសមស្រប ឬមិនត្រូវបានទទួលសារឲ្យបានសក្តិសមនៅឡើយទេ។ ការសិក្សាស៊ីជម្រៅមួយអំពីគោលនយោបាយឈ្នះ-ឈ្នះ តាមរយៈប្រវត្តិសាស្ត្រអន្លង់វែង អាចនឹងផ្តល់ជាគោលគំនិត មេរៀន ជាបទពិសោធន៍និងការអនុវត្តជាក់ស្តែងដ៏ប្រសើរបំផុតដល់ប្រទេសដទៃទៀត ជាពិសេស ថាតើគោលនយោបាយនេះមានប្រសិទ្ធភាពយ៉ាងដូចម្តេចក្នុងការបញ្ចប់ជម្លោះផ្នែកនយោបាយនិងផ្នែកយោធា នៅថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ និងថ្នាក់ជាតិ។

ដោយសារតែតំបន់អន្លង់វែង គឺជាទីស្នាក់ការកណ្តាលដ៏សំខាន់នៃចលនាតស៊ូរបស់ខ្មែរក្រហម នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ តំបន់នេះក៏ជាទីតាំងពិសេសមួយនៃប្រវត្តិសាស្ត្រពិភពលោក ដោយតំណាងឲ្យចំណុចប្រសព្វនៃមនោគមវិជ្ជារបស់សហរដ្ឋអាមេរិក សហភាពសូវៀត ចិន និងវៀតណាម ព្រមទាំងកងកម្លាំង និងរបៀបវារៈនយោបាយជាច្រើនប្រភេទ ដែលរួមផ្សំបង្កើតបានជាតំបន់អាស៊ីអាគ្នេយ៍ក្នុងសតវត្សរ៍ទី២០។ អន្លង់វែង មិនត្រឹមតែរំលេចនូវជម្លោះរវាងនយោបាយ ទាក់ទងនឹងភូមិសាស្ត្រនៃក្រុមបក្សសម្ព័ន្ធតែប៉ុណ្ណោះទេ ក៏ប៉ុន្តែតំបន់នេះបង្ហាញអំពីជម្លោះរវាងកងយោធានិងសំណល់ប្រវត្តិសាស្ត្រដែលកំណត់នូវបច្ចុប្បន្នកាលរបស់យើង។ តំបន់អន្លង់វែងជាសម្បុកនៃសំណល់សង្គ្រាម និងកេរដំណែលនៃយុគសម័យដែលហាក់ដូចជាត្រូវបានបំភ្លេចចោល។

ជាចុងក្រោយ អន្លង់វែង គឺជាតំបន់ប្រកបទៅដោយសម្រស់ស្រស់ត្រកាល។ ដោយរួមផ្សំនូវទឹកធ្លាក់ ទន្លេព្រៃព្រឹក្សា និងភ្នំដងរែក អន្លង់វែងផ្តល់ជាទីតាំងសម្រាប់ការដើរភ្នំ និងដំណើរផ្សងព្រេងនានា ទៅកាន់តំបន់ដែលស្ថិតនៅដាច់សង្វែងពីទិសដៅទេសចរណ៍ដ៏ពេញនិយមផ្សេងៗនៃខេត្តសៀមរាប។

ភ្នំដងរែក ផ្តល់នូវតម្លៃជាសកលមិនអាចកាត់ថ្លៃបាន តាមរយៈគោលគំនិតនៃប្រវត្តិសាស្ត្រ បរិស្ថាន និងសម្រស់ធម្មជាតិ។ នាពេលបច្ចុប្បន្ន ទោះបីជាជួរភ្នំដងរែកមានតួនាទីជាព្រំប្រទល់ធម្មជាតិ ខណ្ឌចែកប្រទេសកម្ពុជា និងប្រទេសថៃយ៉ាងណាក៏ដោយ ជួរភ្នំនេះធ្លាប់ជាទីសម្រាកលំហែមួយក្នុងចំណោមទីតាំងដទៃទៀត ស្ថិតនៅប៉ែកឧត្តរក្នុងអាណាចក្រខ្មែរ។ ជួរភ្នំដងរែក ពោរពេញទៅដោយសំណល់បុរាណវិទ្យាជាច្រើនរួមបញ្ចូលទាំងចម្លាក់ឆ្លាក់ជាប់នឹងថ្ម ជ្រលងគាស់យកថ្មនាបុរាណកាល ក៏ដូចជាទីសក្ការៈតំណាងឲ្យព្រលឹងដូនតា និងប្រាង្គប្រាសាទនានា។ ភ្នំដងរែក អាចចាត់ចូលជាទីតាំងបេតិកភណ្ឌវប្បធម៌ពិភពលោក ក្រោមមូលហេតុជាច្រើនទៀត។



លោក ផាទ្រិក ម័រហ្វី ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅអំឡុងពេលទស្សនកិច្ចទៅកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងស្ថិតនៅលើខ្នងភ្នំដងរែក កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០។ (ស្លូត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រវត្តិសាស្ត្រអាចនឹងត្រូវលើកយកមកបង្ហាញក្នុងសណ្ឋានជាច្រើន ដោយសារមូលហេតុនេះហើយ មជ្ឈមណ្ឌលឯកសារកម្ពុជា បានខិតខំប្រឹងប្រែងក្នុងការបង្កើតជាដំណើរទស្សនកិច្ចទៅកាន់តំបន់អន្លង់វែង។ មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាអង្គការក្រៅរដ្ឋាភិបាលមួយ ដែលផ្តួចផ្តើមបង្កើតឲ្យមានដំណើរទស្សនកិច្ចទៅកាន់ស្រុកអន្លង់វែង។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតឲ្យមានមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលរួមមានបន្ទប់អំណាននិងថ្នាក់រៀន នៅក្នុងអតីតអគារខ្មែរក្រហម។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ថែមទាំងបានផ្តល់ជាវគ្គបណ្តុះបណ្តាល ស្តីអំពីប្រវត្តិសាស្ត្រក្នុងតំបន់និងថ្នាក់ជាតិដល់មគ្គុទេសក៍ទេសចរណ៍និងអ្នកសម្របសម្រួលនៅក្នុងតំបន់នេះយ៉ាងទៀងទាត់ទៀតផង។

កិច្ចសន្ទនាតទល់គ្នាជាមួយអតីតយុទ្ធជនខ្មែរក្រហម និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក៏ដូចជាទស្សនកិច្ចថ្មើរជើងទៅកាន់ទីតាំងប្រវត្តិសាស្ត្រនានា សុទ្ធសឹងជាកិច្ចផ្តួចផ្តើមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា រួមសហការជាមួយនឹងក្រសួងទេសចរណ៍ ដើម្បីបង្កើតជាទិសដៅទេសចរណ៍ថ្មីមួយ ដែលមិនធ្លាប់ត្រូវបានដាក់បញ្ចូលជាទិសដៅទស្សនារបស់ទេសចរពីមុនមក។

ដំណើរទស្សនកិច្ចទៅកាន់ស្រុកអន្លង់វែង បង្កើតឲ្យមានការចូលរួមពីសំណាក់ប្រជាជនមូលដ្ឋាន ដែលជាក្រុមគ្រួសារ និងជាអតីតកម្មាភិបាលខ្មែរក្រហម ឬអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានចំនួនស្ទួបស្ទើងក្នុងតំបន់និងមិនមែនជាផ្នែកមួយនៃរបបនេះ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ក៏ផ្តល់ជាបទបង្ហាញស្តីអំពីប្រវត្តិសាស្ត្រនិងកិច្ចពិភាក្សាជាក្រុមលើប្រធានបទស្តីពីសន្តិភាព និងថាតើប្រវត្តិសាស្ត្រក្នុងស្រុកមានទំនាក់ទំនងជាមួយនឹងប្រវត្តិសាស្ត្រតំបន់អាស៊ីអាគ្នេយ៍ ក៏ដូចជាប្រវត្តិសាស្ត្រសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុបយ៉ាងដូចម្តេចខ្លះ។

ដូចគ្នានឹងតំបន់ដទៃជាច្រើនផ្សេងទៀតនៅក្នុងប្រទេសកម្ពុជាដែលជាប្រទេសក្រោយជម្លោះ អន្លង់វែងគឺគ្រាន់តែជា ផ្នែកតូចមួយដែលត្រូវបានរួមបញ្ចូលទៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសនិងតំបន់តែប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក្តី ក្នុងនាមជាករណីសិក្សាគំរូ អន្លង់វែងមិនត្រឹមតែជាបង្គួចភ្ជាប់ទៅកាន់ប្រវត្តិសាស្ត្រជាតិជារួមតែប៉ុណ្ណោះទេ ក៏ប៉ុន្តែបង្ហាញអំពីបទពិសោធន៍ជាលក្ខណៈបុគ្គលនិងមនុស្សជាតិជារួម ហើយសមាសធាតុទាំងនេះសក្តិសមបំផុតចំពោះការយល់ដឹងអំពីអនាគតរបស់យើង។ ដោយសារមូលហេតុទាំងអស់នេះ អន្លង់វែង គឺជាផ្នែកមួយនៃប្រវត្តិសាស្ត្រនិងអនាគតពិភពលោក៕

# ចាន់ ម៉ុន ហៅ គុល លេខាតំបន់ ៤២ ភូមិភាគឧត្តរ

ដារ៉ារដ្ឋ មេត្តា



នៅក្នុងឆ្នាំ១៩៧៦ កែ ពក ត្រូវបានចាត់តាំងឲ្យធ្វើជាលេខាភូមិភាគឧត្តរ (៣០៣) បន្ទាប់ពី កុយ ធួន ត្រូវបានចាប់ខ្លួន។ នៅឆ្នាំ១៩៧៧ កែ ពក ត្រូវបានចាត់តាំងឲ្យធ្វើជាលេខាភូមិភាគកណ្តាលដែលទើបបង្កើតថ្មី ហើយលេខាថ្មីរបស់ភូមិភាគឧត្តរគឺ កង ចាប។ ភូមិភាគឧត្តរ រួមមាន ខេត្តកំពង់ធំទាំងមូល, ផ្នែកខាងស្តាំទន្លេមេគង្គនៃខេត្តកំពង់ចាម និងស្រុកមួយក្នុងខេត្តក្រចេះ គឺព្រែកប្រសព្វ។ ភូមិភាគនេះចែកចេញជាបីតំបន់គឺ តំបន់៤១, តំបន់៤២ និង តំបន់ ៤៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ចាន់ ម៉ុន ហៅ គុល។ ខ្ញុំមានអាយុ៣៩ឆ្នាំ នៅក្នុងឆ្នាំ១៩៧៧។ ខ្ញុំមានទឹកដីកំណើតនៅភូមិដោមឃុំក្រវាញ (បច្ចុប្បន្នឃុំបាក់ស្នា) ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ នៅក្នុងឆ្នាំ១៩៦៤ ពេលខ្ញុំមានអាយុ២៦ឆ្នាំ ខ្ញុំបានចូលធ្វើបដិវត្តន៍តាមរយៈបងពក។ បងពក បានចាត់តាំងខ្ញុំឲ្យធ្វើការសម្ងាត់នៅក្នុងភូមិរបស់ខ្ញុំ។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៦៤ បងពក បានចាត់តាំងខ្ញុំនៅក្នុងអង្គការសមាគមកសិករភូមិ។

រយៈពេលមួយឆ្នាំក្រោយមក គឺនៅក្នុងឆ្នាំ១៩៦៥ បងពក និង ចន បានបញ្ចូលខ្ញុំជា បក្សជន។ នៅក្នុងឆ្នាំ១៩៦៧ បងពក បានហៅខ្ញុំមកជួយធ្វើការ និងឲ្យខ្ញុំរៀនសូត្រអំពីទស្សនៈសភាពការណ៍ និងផែនការរបស់បក្សដែលរៀបចំវាយយកអាវុធពីខ្មាំង។ បងពក បានចាត់តាំងខ្ញុំជាអ្នកដឹកនាំកម្លាំងចំនួន ៤០នាក់ ទៅវាយយកអាវុធពីខ្មាំងនៅ ប៉ុលតាប្រុក។ ខ្ញុំដឹកនាំកម្លាំងវាយចូលបន្ទាយខ្មាំង និងយកអាវុធបានចំនួន ៤ដើម រួមមានកាំភ្លើងសេកាសេចំនួន ៣ដើម និងកាំភ្លើងកាវ៉ាប៊ីនចំនួន ១ដើម។ ក្រោយពីបានអាវុធ ខ្ញុំនាំកម្លាំងទាំងនេះទៅជួបបងពក នៅក្នុងព្រៃភ្នំដែលជាមូលដ្ឋានបង្អែក។ ខ្ញុំទៅនៅជាមួយ បងពក រយៈពេល១អាទិត្យ។ ក្រោយមក បងពក បានចាត់តាំងខ្ញុំ និង ចន ឲ្យទៅពិនិត្យមើលសភាពការណ៍នៅបន្ទាយ និងត្រូវត្រឡប់មករាយការណ៍ជូនគាត់វិញ។ បងពក បានលើកពីគោលការណ៍កម្ទេចកម្លាំងប្រតិកិរិយានៅភូមិបាក់ខ្នាចំនួន៨នាក់ទៀត។ ក្រោយពីកម្ទេចកម្លាំងប្រតិកិរិយាហើយ បងពក បានចាត់តាំងខ្ញុំនិង ចន នាំកម្លាំងមកមូលដ្ឋានបង្អែក។ ខ្ញុំបានដាច់ការទាក់ទងជាមួយ បងពក មួយរយៈ។

នៅខែសីហា ឆ្នាំ១៩៦៧ ខ្ញុំបានជួប បងពក វិញ។ បងពក បានឲ្យខ្ញុំចុះមកធ្វើការងារនៅមូលដ្ឋានបង្អែកបន្តទៀត។ រហូតដល់ខែមិថុនា ឆ្នាំ១៩៦៨ ខ្ញុំ និង ចន ត្រូវខ្មាំងចាប់បានពេលខ្ញុំចូលលួចអង្ករប្រជាជននៅភូមិដោម ឃុំបាក់ខ្នា។ ខ្មាំងបានបញ្ជូនខ្ញុំមកដាក់គុកនៅខេត្តកំពង់ធំ។ ខ្ញុំបានជាប់ឃុំរយៈពេល២ថ្ងៃ បន្ទាប់មកខ្មាំងបានហៅខ្ញុំទៅសួរចម្លើយអំពីប្រវត្តិរូប និងការរស់នៅ។ ខ្ញុំបានសារភាពប្រាប់ខ្មាំងអំពីមូលហេតុដែលខ្ញុំចូលព្រៃ ដោយមានទាហានដេញបាញ់ប្រជាជន។ ខ្មាំងបានសួរខ្ញុំអំពីក្រុមដែលនាំគ្នាទៅវាយយកកាំភ្លើងពីប៉ុស្តិ៍តាប្រុក និងបាក់ខ្នា។ ខ្ញុំនៅតែឆ្លើយមិនដឹងព្រោះខ្ញុំមានគ្នាតែពីរនាក់មិនអាចធ្វើសកម្មភាពបានឡើយ។ ក្រោយមកខ្ញុំបានទាក់ទងទាហានស័ក្តិ ៣ ឈ្មោះឈុំ នៅខេត្តកំពង់ធំ ដើម្បីសុំសំបុត្រចុះចូលមួយច្បាប់ ដោយសង្ឃឹមថាខ្មាំងអាចសម្រាលទោសខ្ញុំ និងដោះលែងខ្ញុំ។ ខ្ញុំបានជូនលុយចំនួន ១៥០០រៀល ទៅ ឈុំ។ ឈុំបានសរសេរសំបុត្រសុំចុះចូលឲ្យខ្ញុំ និង ចន ម្នាក់មួយច្បាប់។ ប៉ុន្តែពេលខ្ញុំទទួលបានសំបុត្រចុះចូលរួច ស្រាប់តែនៅខែសីហា ឆ្នាំ១៩៦៨ ខ្មាំងបានបញ្ជូនខ្ញុំមកដាក់គុកព្រៃសទៀត។

បន្ទាប់ពីខ្ញុំមកដល់គុកព្រៃស ខ្មាំងបានសួរចម្លើយសំណួរដដែលម្តងទៀត។ ខ្ញុំបានប្រាប់តាមចម្លើយដែលខ្ញុំធ្លាប់ឆ្លើយប្រាប់ពីមុនទៅខ្មាំង។ នៅខែវិច្ឆិកា ឆ្នាំ១៩៦៨ ខ្ញុំបានទាក់ទងជាមួយ ម៉ន ហើយយើងបានរាប់អានគ្នាជាមិត្តភក្តិ។ ម៉ន តែងនិយាយប្រាប់ខ្ញុំអំពីជីវិតនៃការរស់នៅនិងធ្វើរោងចក្រសប្បាយរីករាយ សប្បូរហូបចុក និងមានសិទ្ធិសេរីភាព។ ខ្ញុំមានសតិអារម្មណ៍គិតនៅពេលខ្ញុំចេញពីគុក ខ្ញុំនឹងធ្វើការនៅរោងចក្រជាមួយ ម៉ន។

នៅខែវិច្ឆិកា ឆ្នាំ១៩៦៩ ខ្ញុំ, ចន និងបងប្អូននៅខេត្តកំពង់ធំ ចំនួន ២០នាក់ និងខេត្តកំពង់ចាម ចំនួន ១៦នាក់ បានរួចពីគុកព្រៃស។ បន្ទាប់ខ្ញុំចេញពីគុក ខ្ញុំមករស់នៅជាមួយគ្រួសារ ជួយធ្វើស្រែចម្ការគ្រួសាររហូតដល់កើតមានរដ្ឋប្រហារ ឆ្នាំ១៩៧០។ នៅក្នុងខែមេសា ឆ្នាំ១៩៧០ ខ្ញុំនិងចនបានធ្វើការទាក់ទងជាមួយបង ពក នៅឯព្រៃម្តងទៀត។ បងពក បានចាត់តាំងខ្ញុំ និង ចនឲ្យនាំកម្លាំងមកប្រចាំការនៅស្រុកសន្ទុក និងស្រុកបារាយណ៍ ខេត្តកំពង់ធំ។ បងពក បានចាត់តាំងខ្ញុំដឹកនាំយោធាមួយអនុសេនាធំ ចំណែក ចន ដឹកនាំមួយអនុសេនាតូច។

ក្រោយមក ខ្ញុំបានផ្លាស់មកធ្វើការនៅស្រុកសន្ទុកវិញ។ ខ្ញុំបានទាក់ទងជាមួយឈ្មួញ ដោយធ្វើសំបុត្រអនុញ្ញាតឲ្យឈ្មួញអាចចេញចូលតំបន់រំដោះ និងអាចនាំទំនិញមកលក់បាន។ ខ្ញុំបានទទួលក្រណាត់ ថ្នាំពេទ្យ និងអំបិលពីឈ្មួញ។ សម្ភារទាំងនេះខ្ញុំមិនបានកត់ក្នុងបញ្ជី និងរាយការណ៍ជូនអង្គការទេ គឺខ្ញុំបានទុកស៊ីចាយសេរីនៅក្នុងអង្គភាពខ្ញុំ។ ខ្ញុំ និង ចនក៏បានទាក់ទងជាមួយ ម៉ន លេខាស្រុកចម្ការលើដែរ ហើយ ម៉នបានមកជួបយើងនៅស្រុកសន្ទុក។ បន្ទាប់ពីយើងបានជួបនិងសួរសុខទុក្ខគ្នារួច ម៉ន់បានសួរខ្ញុំអំពីស្ថានភាពនៅសមរភូមិ និងការចាប់អារម្មណ៍ចំពោះតំបន់រំដោះ។ កាលពីមុនមានប្រជាជនរស់នៅសប្បាយកុះករ មានផ្សារកំពង់ថ្ម និងផ្សារតាំងក្រសាំង ប៉ុន្តែបច្ចុប្បន្នត្រូវបានបំផ្លាញខ្ទេចខ្ទីដោយសារសង្គ្រាម។

នៅខែសីហា ឆ្នាំ១៩៧០ ម៉នបានមកជួបខ្ញុំម្តងទៀត។ ម៉ន មិនបាននិយាយអ្វីក្រៅពីសរសើររបបសេរីនោះទេ។ ទោះបីជាតំបន់រំដោះមានផ្ទៃដី ៧៥ ភាគរយ ក៏ពិតមែន ប៉ុន្តែគឺជាស្រុកស្រែចម្ការ ចំណែកទីប្រជុំជន រដ្ឋអំណាចសេដ្ឋកិច្ច នៅតាមខេត្ត គឺស្ថិតនៅក្រោមការ គ្រប់គ្រងរបស់ លន់ នល់។ ខ្ញុំបានអប់រំ យ៉នបន្តអំពីមាគ៌ាកុម្មុយនីស្ត បន្ទាប់ពីបង ម៉ន អប់រំខ្ញុំ។

នៅខែមករា ឆ្នាំ១៩៧១ ខ្ញុំ, ចន ដែលក្រោយមកគឺជាលេខាតំបន់៤៣ និង យ៉នបានធ្វើការទាក់ទងជាមួយបងឃួន។ បងឃួនបាន ហៅយើងទាំង៣នាក់ទៅធ្វើការនៅក្នុងមន្ទីរកណ្តាលស្ថិតនៅសង្កាត់ក្រយ៉ា ស្រុកសន្ទុក ខេត្តកំពង់ធំ។ ខ្ញុំបានស្គាល់ បងឃួន តាំងពីឆ្នាំ១៩៧០ មកម្ល៉េះ។ បងឃួនបានសួរខ្ញុំអំពីស្ថានភាពប្រជាជនតាមផ្លូវជាតិលេខ៦ ។ បងឃួន និយាយថា នៅថ្ងៃអនាគតនឹងក្លាយជាកុម្មុយនីស្ត ដូច្នេះយើងត្រូវតស៊ូជាមួយបដិវត្តន៍ ហើយការតស៊ូជាមួយបដិវត្តន៍គឺ ត្រូវ ទាក់ទងជាមួយរដ្ឋអំណាចចាស់ដើម្បីមានខ្នងបង្អែក, ទប់ទល់ជាមួយចលនាបដិវត្តន៍, បញ្ចុះបញ្ចូលប្រជាជនឲ្យធ្វើទាហាន (លន់ នល់), ទប់ទល់កុំឲ្យរំដោះប្រទេសបានឆាប់ ដើម្បីមានពេលកសាងកម្លាំងបន្ថែម។

នៅខែកុម្ភៈ ឆ្នាំ១៩៧១ បងឃួនបានចាត់តាំងខ្ញុំឲ្យនាំកងទ័ពមកប្រចាំការនៅស្រុកបារាយណ៍ និងស្រុក

តាំងគោកៗ ខ្ញុំបានពិភាក្សាជាមួយ ចន និង យ៉ន ដោយចង់បើកច្រកសេដ្ឋកិច្ចឲ្យប្រជាជនចេញចូលរកស៊ីនៅស្រុកចម្ការលើ ស្រុកតាំងគោក និងស្រុកបារាយណ៍ ដោយនាំសណ្តែក ពោត ចេក មាន់ ជ្រូក គោ និង អង្ករមកលក់ៗ

នៅខែឧសភា ឆ្នាំ១៩៧១ ខ្ញុំបាននាំចលនាប្រជាជនចំនួន ៣០គ្រួសារ ឲ្យចូលទៅស្រុកតាំងគោក ក្នុងគោលបំណងឲ្យប្រជាជនធ្វើទាហាន(លន់នល់) នៅស្រុកតាំងគោក តាមការណែនាំរបស់ បងឃួនៗ

នៅខែសីហា ឆ្នាំ១៩៧១ យោធា (ខ្មែរក្រហម) បានប្រតិបត្តិការលើកទី២ដើម្បីបើកការវាយយកផ្លូវជាតិលេខ៦ ចាប់ពីតាំងគោក ទៅតាំងក្រសាំង ព្រោះជាផ្លូវសំខាន់ក្នុងការទាក់ទងទៅថ្នាក់លើជាមូលដ្ឋានសេដ្ឋកិច្ច និងមានប្រជាជនរស់នៅច្រើនកុះករៗ រហូតដល់ខែមករា ឆ្នាំ១៩៧២ អង្គការរំដោះបានផ្លូវជាតិលេខ៦ៗ

នៅចុងខែមិថុនា ឆ្នាំ១៩៧២ បងឃួនបានហៅខ្ញុំទៅជួបគាត់នៅមន្ទីរ២២ៗ នៅទីនោះខ្ញុំបានជួប ស្រេង លេខាតំបន់៤១, ចន, យ៉ា, មន, ម៉ែន និង ម៉ុនៗ បងឃួន បានរៀបចំបញ្ចូលខ្ញុំទៅក្នុងបក្សពលករកម្ពុជាៗ បក្សពលលករកម្ពុជា មានគោលបំណងប្រឆាំងជាមួយបក្សកុម្មុយនីស្តកម្ពុជា គឺធ្វើឲ្យប្រទេសកម្ពុជាមានសិទ្ធិសេរីភាព កម្មសិទ្ធិឯកជនផ្សារ និងចាយប្រាក់វិញៗ នៅខែវិច្ឆិកា ឆ្នាំ១៩៧២ ខ្ញុំបានទទួលផែនការពី បងឃួន ដកកងទ័ពចេញពីសមរភូមិចម្ងាយ២គីឡូម៉ែត្រ ពីក្រុងកំពង់ចាមៗ

នៅខែមិថុនា ឆ្នាំ១៩៧៣ ពេលយោធា (ខ្មែរក្រហម) វាយចូលក្រុងកំពង់ចាម ខ្ញុំ និង បងឃួនបានធ្វើការទាក់ទងជាមួយ ប៉ែន ដូៗ ប៉ែន ដូ គឺជាមេទាហានស័ក្តិ៤ នៅក្រុងកំពង់ចាមៗ ខ្ញុំបានឲ្យ ប៉ែន ដូ រៀបចំកងទ័ពខ្មាំង និង កងទ័ពម៉ារីនជាខ្សែត្រៀមដើម្បីស្កាត់នៅពេលដែលយោធា (ខ្មែរក្រហម) វាយចូលតំបន់បឹងកុក វត្តជីដុះ និង បឹងស្នាយៗ

នៅខែសីហា ឆ្នាំ១៩៧៣ ខ្ញុំ និង បងឃួនបានធ្វើការទាក់ទងជាមួយបងភឹម នៅក្នុងមន្ទីរស្រុកក្រូចឆ្មារៗ ខ្ញុំបានជួប បងភឹម, បងចាន់ អនុលេខាភូមិភាគបូព៌ា, ឈូក សមាជិកភូមិភាគបូព៌ា និង ជាលេខាតំបន់២៤, ខិម លេខាតំបន់ ២០ លីន ប្រធានមន្ទីរភូមិភាគ, ខុន ប្រធានពេទ្យតំបន់២១ និង បូ លេខាតំបន់២១ និងជាលេខាស្រុកពាមជីលាំងៗ

នៅខែកក្កដា ឆ្នាំ១៩៧៤ ខ្ញុំ, បូ និង វឿង បានសហការគ្នាឲ្យប្រជាជនចំនួន ៣៦ គ្រួសារ ក្នុងស្រុកក្រូចឆ្មារ ធ្វើដំណើរតាមកាណូតម៉ារីនកាត់តាមទន្លេបិទសំដៅទៅភ្នំពេញៗ ប្រជាជនទាំងនោះត្រូវបានបញ្ជូនឲ្យធ្វើជាទាហានៗ

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៤ តាមការណែនាំរបស់បងឃួន ខ្ញុំបានទាក់ទងជាមួយ បងចាន់, ឈូក, លីន និង ខិម ដើម្បីពិភាក្សាគ្នាអំពីគម្រោងរបស់ បងភឹម ៗ បងឃួនបានណែនាំឲ្យទប់ទល់កម្លាំងកុំឲ្យរំដោះទីក្រុងភ្នំពេញបាននៅរដូវប្រាំងឆ្នាំ១៩៧៥ ហើយសមរភូមិនីមួយៗ ត្រូវរៀបចំផែនការជាពិសេសខាងផ្នែកដឹកជញ្ជូន និងត្រូវយកចិត្តទុកដាក់រៀបចំកម្លាំងតាមអង្គភាពយោធាៗ

នៅខែកុម្ភៈ ឆ្នាំ១៩៧៥ ខ្ញុំ និង ស្រេង បានសហការជាមួយ បូ, ឯក និង វឿន ដកកម្លាំងចេញពីសមរភូមិក្រុងកំពង់ចាម និង ទន្លេបិទ ក្នុងគោលបំណងឲ្យទាហានខ្មាំងធ្វើសកម្មភាពដេញចាប់ប្រជាជនៗ ចំណែកសមរភូមិនៅខេត្តកំពង់ធំ ក៏ធ្វើឲ្យស្របតាមផែនការរបស់បងឃួន និង បងភឹម ដែរៗ សកម្មភាពបន្តគឺយើងរៀបចំកម្លាំងមួយក្រុមធ្វើចម្រូងដែកក្នុងគោលបំណងបំផ្លាញកង់ឡានដឹកទំនិញរបស់អង្គការតាមផ្លូវជាតិលេខ៦ និងលេខ៧ៗ

រហូតដល់ខែមេសា ឆ្នាំ១៩៧៥ យើងបានបំផ្លាញឡានដឹកបន្លែ និង ឡានសេអឹមសេ ដែលអាចរាំងស្ទះដល់ការវាយសម្រុករបស់បក្សរំដោះភ្នំពេញៗ នៅក្នុងខែមេសាដដែល ខ្ញុំបានទទួលសំបុត្ររបស់ បងឃួន មួយច្បាប់ណែនាំខ្ញុំ និងស្រេង ឲ្យចាំទទួលប្រជាជនជម្លៀសចេញពីទីក្រុងភ្នំពេញៗ ក្រោយមកខ្ញុំ និង ស្រេង បាននាំទាហានទៅលាក់នៅក្នុងសហករណ៍ ដើម្បីទុកឲ្យបម្រើនូវសកម្មភាពរបស់យើងមាន ដូចជា ៖ អ៊ុ ទុយ អតីតចៅហ្វាយខេត្តកំពង់ចាម នៅសហករណ៍សង្កាត់ចើងដើងស្រុកបារាយណ៍, ប៉ែនដូ ស័ក្តិ ៤កន្ទះ ជាខ្សែទាក់ទងរបស់បងឃួន, អ៊ុង ហុងសាធ សហករណ៍ សង្កាត់បារាយណ៍, សន ស័ក្តិ ៤កន្ទះ សហករណ៍ស្ទឹងត្រង់, ស្វាយ មិ ស័ក្តិ ៣ ស្វាយទាប ស្រុកចម្ការលើ, ម៉ុស ខ្ចី ស័ក្តិ ២ នៅ

ស្វាយទាប ស្រុកចម្ការលើ, សារូ ហៅ រឿង ស័ក្តិ២ សង្កាត់សាមគ្គី ស្រុកតាំងគោក, សោម សេក ស័ក្តិ ៣ ស្រុកបារាយណ៍, នឹម ស័ក្តិ២ ស្រុកតាំងគោក, សាយ ស័ក្តិ ៣ សង្កាត់ចុងដូង, ណែម ស័ក្តិ១ សហករណ៍ស្ពឺ ស្រុកចម្ការលើ, ហូ ស័ក្តិ២ ស្រុកស្ទឹងត្រង់ , ណោង ស័ក្តិ២, អ៊ឹម មិន ស័ក្តិ៣ ព្រែកកក់ ស្រុកស្ទឹងត្រង់, អ៊ី ហេង ស័ក្តិ២ សង្កាត់ល្វាលើ ស្រុកចម្ការលើ, ហោ ម៉េង ស័ក្តិ១ សង្កាត់ស្វាយទាប ស្រុកចម្ការលើ និង នៅ ជា ស័ក្តិ១ សង្កាត់ល្វាលើ ស្រុកចម្ការលើ។

នៅខែឧសភា ឆ្នាំ១៩៧៥ បងឃួនបានធ្វើការបើកអង្គប្រជុំមួយនៅមន្ទីរគ ១៥ ក្នុងនោះមានបងភឹម បងយ៉ា អ្នកដឹកនាំប្រជុំ។ ខាងភូមិភាគឧត្តរ មានបងឃួន, ឌឿន, សុក ខ្ញុំ ឈឿន, ចន និង ងិន។ ចំណែកខាងបូព៌ាមានបងចាន់, ឈូក, លីន, ប៊ឹម, នឹម និងបូ។ យើងប្រជុំអំពីគម្រោងរបស់បងភឹម ដែលបានរាយការណ៍ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អំពីសភាពការណ៍លំបាកដែលត្រូវប្រឈម និងផែនការសម្រាប់ឆ្នាំ១៩៧៥-១៩៧៦ ។

នៅក្នុងឆ្នាំ១៩៧៦ នៅភូមិភាគបូព៌ា មាន បងភឹម, បងចាន់, លី, ដឹកនាំអនុវត្តផែនការ។ ចំណែកនៅខាងភូមិភាគឧត្តរមាន បងស្រេង, ខ្ញុំ, ចន និង ងិន ក្រោយពីបងឃួន បានលាមកធ្វើការនៅភ្នំពេញ។ ចំណែកតំបន់សមរភូមិ១០៦ គឺបងឃួនបានចាត់តាំង សុត និង បេង ទៅនៅនោះ។

នៅខែមករា ឆ្នាំ១៩៧៧ ខ្ញុំ និង ស្រេង បានរៀបចំកន្លែងប្រជុំនៅទឹកឆា តំបន់ ៤១ ធ្វើការផ្សព្វផ្សាយផែនការដែលបានទទួលពីបងភឹម សម្រាប់ឆ្នាំ១៩៧៧ និង១៩៧៨។ នៅពេលនោះអ្នកចូលរួមប្រជុំមាន ស្រេង, ខ្ញុំ ,ចន, ងិន, តាំង, សោ, ជោត, សី, ផៃ, ផាន់, ទៀង, កា, ខែម, ពេជ, ទុន, លេន, មាស, ពូល, គុន, ស៊្រុន និង ប៉ាង។ ទាំងប៉ុន្មាននាក់ខាងលើមកទទួលផែនការដែលខ្ញុំ និង ស្រេង បានទទួលពីបងភឹម។ ផែនការនោះ គឺយើងត្រូវរិតខំកសាងកម្លាំងស្នូលបង្កប់ជាសំខាន់នៅក្នុងឆ្នាំ១៩៧៧ និង១៩៧៨ ដោយត្រូវកំណត់ចំនួនពី ៦០ ទៅ៦៥ភាគរយ តាំងពីកម្មាភិបាល និងយុទ្ធជន ដើម្បីរំដោះប្រទេសកម្ពុជាពីរបបកុម្មុយនីស្តមកគ្រប់គ្រងចាត់ចែងដោយខ្លួនឯង។ ចំណែកកម្លាំងដែលកសាងបានមិនទាន់ខ្លាំងក្លានោះទេ ជាពិសេសនៅក្នុងអង្គភាពយោធា និងត្រូវយកចិត្តទុកដាក់ពង្រឹងកម្លាំងចាស់របស់យើងដែលមាននៅក្នុងសហករណ៍។ យើងត្រូវយកចិត្តទុកដាក់បន្ថែមក្នុងការគ្រប់គ្រងកម្លាំងប្រជាជន ធ្វើយ៉ាងណាឲ្យប្រជាជនចូលរួមជាមួយយើង។ បងភឹម បានកំណត់ថាយើងត្រូវរំដោះភូមិភាគឧត្តរមុន បន្ទាប់មករំដោះភូមិភាគបូព៌ា។ ភូមិភាគឧត្តររបស់យើង គឺមានលក្ខណៈទឹកដីសម្បូរដោយធម្មជាតិ ភោគផលស្រូវ និងផលដំណាំផ្សេងៗ និងមានប្រជាជនរស់នៅច្រើន។ យើងយកភូមិភាគឧត្តរធ្វើជាមូលដ្ឋានសេដ្ឋកិច្ច និងកម្លាំងភូមិភាគឧត្តរជាមូលដ្ឋានបង្អែក។ ក្រោយមកអង្គប្រជុំបានរួមមតិឯកភាពគ្នាលើគម្រោងផែនការសម្រាប់ភូមិភាគឧត្តរ ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ ដោយប្តេជ្ញាយកផែនការនេះទៅអនុវត្តឲ្យមានសម្រេចតាមសំណូម ពរ និងទិសដៅរបស់បក្សពលករកម្ពុជាដែលបានលើកឡើង។ ក្រោយពីប្រជុំ ខ្ញុំ និង ស្រេង បានបំផ្លាញផែនការរបស់បក្ស បំផ្លាញទំនប់ទឹក និងបំផ្លាញស្ពានីយ៍នៅស្រុកបារាយណ៍ និងបំផុសប្រជាជនឲ្យរត់ចេញពីការដ្ឋានត្រឡប់ទៅផ្ទះ វិញ ព្រមទាំងបំផ្លាញអគ្គិសនីមិនឲ្យមានភ្លើងសម្រាប់អង្គការធ្វើការងារពេលយប់។ រហូតដល់ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ ត្រូវអង្គការចាប់ខ្លួន ។

កំណត់ចំណាំ ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារD០០៤០៧ ។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់ចាន់ ម៉ុន ហៅ គុល ពិតប្រាកដនោះទេ។

# ឥណ្ឌូនេស៊ីទស្សនកិច្ច «បណ្ណាល័យសម្តេចម៉ែ»

**ផាត ចាន់សុនិតា**

ចក្ខុវិស័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺផ្តោតលើយុត្តិធម៌ និងការចងចាំ ដែលជាគ្រឹះក្នុងការធ្វើឲ្យសះស្បើយសម្រាប់អ្នករស់រានមានជីវិតនៃរបបខ្មែរក្រហម លើកេរដំណែលប្រកបដោយវិនាសកម្មនៃរបបនេះ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រើប្រាស់មធ្យោបាយ ការអភិរក្សសិល្បៈ វប្បធម៌ និងបេតិកភណ្ឌជាតិមួយចំនួន ដែលជាមូលដ្ឋានសំខាន់ក្នុងការផ្សះផ្សា។ នៅឆ្នាំ២០១៥ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានចូលរួមសិក្ខាសាលារៀបចំឡើងដោយសារមន្ទីរជាតិឥណ្ឌូនេស៊ីស្តីអំពីប្រធានបទការការពារនិងថែរក្សា។ នៅទីនោះ ក្រុមការងារបានប្រាស្រ័យទាក់ទងសិល្បករឥណ្ឌូនេស៊ីមួយរូបគឺលោក នីយ៉ូម៉ែន នូអាតា (Nyoman Nuata) ដែលមានជំនាញផ្នែកសិល្បៈចម្លាក់។ ក្រុមការងារបានលើកឡើងអំពីការសហការជាមួយសិល្បកររូបនេះបង្កើតរូបចម្លាក់មួយតំណាងឲ្យស្ត្រីកម្ពុជា ដែលជាទស្សនវិស័យមួយបានរំលេចឡើងជាសាធារណៈតាំងពីឆ្នាំ២០០៨ មកម្ល៉េះ ។ លោក នីយ៉ូម៉ែន (Nyoman) និងភរិយាបានធ្វើទស្សនកិច្ចមកកាន់ទីក្រុងភ្នំពេញ និងខេត្តសៀមរាប ដើម្បីប្រមូលគំនិតទាក់ទងនឹងរូបចម្លាក់ ព្រមទាំងធ្វើបទសម្ភាសជាមួយស្ត្រីមួយចំនួនដែលជាអ្នករស់រានមានជីវិតពីសម័យខ្មែរក្រហម។

ជាលទ្ធផលនៃដំណើរទស្សនកិច្ច លោក នីយ៉ូមេន (Nyoman) បានបង្កើតស្នាដៃរូបចម្លាក់តំណាងស្ត្រីមួយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីផ្តល់កិត្តិយសនិងសេចក្តីគោរពដល់ស្ត្រីខ្មែរ ដោយដាក់ងារថា "រូបបដិមាវីរស្ត្រីកម្ពុជានៃក្តីសង្ឃឹម" ("PILLAR OF HOPE")។ "រូបបដិមាវីរស្ត្រីកម្ពុជានៃក្តីសង្ឃឹម" មានមូលន័យដូចតទៅ៖



"ក្នុងសម័យកាលដ៏ខ្មៅងងឹត ជីវិតមនុស្សហាក់ដូចជាគ្មានអត្ថន័យ។ ការសម្លាប់រង្គាលបានកើតឡើងដោយគ្មានមូលហេតុអ្វីទាល់តែសោះ។ មានតែអ្នកមានអំណាចប៉ុណ្ណោះ ដែលអាចមើលឃើញអនាគតរបស់ខ្លួន ព្រមទាំងបានប្រាថ្នាលើសពីអ្វីដែលខ្លួនត្រូវការ។ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច អំពើឃោរឃៅនិងការបង្ករឈាមជាតិសាសន៍ខ្លួនបានកើតឡើង។ ខ្មែរក្រហមបានធ្វើឲ្យស្ត្រីនិងកុមារជាច្រើនរស់នៅដោយគ្មានស្វាមីនិងឪពុកដែលជាមេគ្រួសារ។ គ្រប់គ្នាទូទាំងពិភពលោកបានដឹងថាមានអំពើប្រល័យពូជសាសន៍នៅកម្ពុជា ប៉ុន្តែ

មានមនុស្សមួយចំនួនតូចតែប៉ុណ្ណោះ ដែលបានដឹងថាស្ត្រី គឺជាអ្នកបានតស៊ូជម្នះរាល់ឧបសគ្គទាំងអស់ក្រោយពី របបប្រល័យពូជសាសន៍ខ្មែរក្រហមដួលរលំ ដើម្បីចិញ្ចឹម បីបាច់ថែរក្សាកូនៗ កសាងជីវិត និងប្រទេសជាតិរបស់ខ្លួន សាជាថ្មីឡើងវិញ។ រូបបដិមានេះ គឺជាការឧទ្ទិសដល់ ស្ត្រីទាំងអស់ដែលជាវីរស្ត្រីកម្ពុជា”។

ដើមដំបូងរហូតដល់រូបចម្លាក់លេចចេញជារូបរាង គឺជា បទពិសោធន៍មួយ និងជាការផ្ទេរចំណេះដឹងក្នុងវិស័យ ចម្លាក់ៗ គួររំឭកថា ក្រៅពីរូបចម្លាក់នេះ ឥណ្ឌូនេស៊ី និង កម្ពុជា ក៏ធ្លាប់មានទំនាក់ទំនងផ្នែកសិល្បៈយ៉ាងជិតស្និទ្ធ ជាមួយគ្នានារយៈពេលកន្លងមក ទៅលើផ្នែករបាំដែលមាន សម្តេចព្រះរាម បុប្ផាទេវី រាំរបាំអប្សរាឥណ្ឌូនេស៊ីបាន


រូបបដិមាវីរស្ត្រីកម្ពុជានៃក្តីសង្ឃឹម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


សម្តេចព្រះរាម បុប្ផាទេវី រាំរបាំអប្សរាឥណ្ឌូនេស៊ីដើម្បីទទួល ស្វាគមន៍គណៈប្រតិភូបរទេស។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដោយសារបញ្ហាប្រឈមមួយចំនួនដូចជា ការដឹក ជញ្ជូនរូបចម្លាក់ពីប្រទេសឥណ្ឌូនេស៊ី មកកាន់ប្រទេស កម្ពុជា និងទីតាំងស័ក្តសមសម្រាប់ដាក់តម្កល់ស្នាដៃដ៏ ប្រណិតនេះ ធ្វើឲ្យមានការរាំងស្ទះទទួលយករូបចម្លាក់ នេះមកកាន់ប្រទេសកម្ពុជា។ ក្រោយមក សិល្បករ នីយ៉ូម៉ែន (Nyoman) បានដាក់រូបចម្លាក់នេះចូលរួមក្នុងកម្មវិធីដេញ ថ្លៃសិល្បៈ និងត្រូវបានទិញយកដោយសហគ្រិនម្នាក់ក្នុង ឆ្នាំ២០១៩។ ទោះបីជា រូបចម្លាក់នេះ មិនអាចបង្ហាញ វត្តមាននៅក្នុងប្រទេសកម្ពុជាយ៉ាងណាក្តី ដំណើរការពី

យ៉ាងល្អិតល្អន់ ដើម្បីទទួលស្វាគមន៍គណៈប្រតិភូបរទេស។ មជ្ឈមណ្ឌលឯកសារកម្ពុជានៅតែបន្តបំពេញការងារ ដើម្បីបព្វហេតុការពារនិងអភិរក្សសិល្បៈ វប្បធម៌ ព្រម ទាំងលើកកម្ពស់ការស្រាវជ្រាវអប់រំនៅកម្ពុជា។

«បណ្ណាល័យសម្តេចម៉ែ» ចាប់បដិសន្ធិឡើង ដើម្បី ថ្វាយព្រះរាជកិត្តិយសជូនសម្តេចម៉ែ និងស្ត្រីកម្ពុជា គ្រប់រូប។ ស្ត្រីកម្ពុជាបានខិតខំប្រឹងប្រែង ដោយមិនរួញរា ក្នុងការស្តារ លើកស្ទួយ និងកសាងប្រទេសជាតិសាជាថ្មី



តាមរយៈការចិញ្ចឹមបីបាច់គ្រួសារ ភ្ជាប់យកនិងពង្រីកឱកាសសេដ្ឋកិច្ច អភិរក្ស ការពារ និងពង្រឹងសហគមន៍ វប្បធម៌ និងប្រទេសជាតិរបស់ខ្លួន ក្រោយពេលដែលរបបខ្មែរក្រហមបានដួលរលំទៅនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ «បណ្ណាល័យសម្តេចម៉ែ» បង្កើតឡើងដើម្បីឧទ្ទិសដល់ស្ត្រីកម្ពុជា ទាំងនៅក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល។

ដើម្បីទទួលស្គាល់និងអបអរសាទរចំពោះសមិទ្ធផលដ៏វិសេសវិសាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ ភ្ញៀវកិត្តិយសចំនួន១០រូប តំណាងឲ្យស្ថានទូតសាធារណរដ្ឋឥណ្ឌូនេស៊ីប្រចាំនៅព្រះរាជាណាចក្រកម្ពុជាបានទស្សនកិច្ច «បណ្ណាល័យសម្តេចម៉ែ» នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្ឌិត ហ្វូលីយ៉ូ អេ. ដែលជ្រេស អតីតអ្នកសរសេរព្រះរាជជីវប្រវត្តិរបស់សម្តេចព្រះបរមរតនកោដ្ឋ បានរៀបរាប់ជូនភ្ញៀវកិត្តិយសអំពី ១) ពិព័រណ៌សំខាន់ៗទាំងពីររបស់បណ្ណាល័យសម្តេចម៉ែ រួមមានពិព័រណ៌ព្រះឆាយាល័ក្ខណ៍របស់សម្តេចព្រះបរមរតនកោដ្ឋ និងអត្ថន័យប្លង់រចនាអគារវិទ្យាស្ថានស្លឹករឹតរបស់លោកស្រី ហ្សាហា ហាឌីដ ដែលជាស្ថាបត្យករល្បីល្បាញនិងកម្រមួយរូប និង២) បរិក្ខារនានានិងម៉ាស៊ីនផ្ទុកឯកសារជាទម្រង់ឌីជីថលរបស់បណ្ណាល័យសម្តេចម៉ែ។

លោកស្រី សូ ហ្វារីណា បានបង្ហាញអំពីទីតាំងស្រាវជ្រាវ, មជ្ឈមណ្ឌលស្រាវជ្រាវ និងបណ្ណាល័យខ្មែរក្រហមនៅតាមបណ្តាខេត្តទាំង១០ ដែលជាផ្នែកមួយនៃគម្រោងអប់រំអំពីរបបកម្ពុជាប្រជាធិបតេយ្យ នៃគម្រោងសំណង់តាមផ្លូវតុលាការ នៅក្នុងក្របខណ្ឌនៃសំណុំរឿង០០២ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាលពីឆ្នាំ២០១៣។

នៅចុងបញ្ចប់នៃដំណើរទស្សនកិច្ចប្រតិភូកិត្តិយស និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា បានពិភាក្សាលើប្រធានបទជុំវិញការងារផ្សេងៗ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើកន្លងមកនិងកំពុងបន្តអនុវត្ត។ ទន្ទឹមនឹងនេះ លោក ឆាំង យុ បានបកស្រាយអំពីគោលគំនិតក្នុងការប្រើប្រាស់សិល្បៈនិងគំនូរ ដើម្បីអប់រំនិងផ្សព្វផ្សាយពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យទៅកាន់សាធារណជន។ លោកបានរំលេចឡើងអំពីការងារសិល្បៈមួយចំនួន ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រតិបត្តិ រួមមាន ល្ខោននិយាយ ខ្សែភាពយន្តឯកសារ ការផលិតភាពយន្តខ្នាតខ្លី និងការស្រាវជ្រាវលើសិល្បៈបុរាណ និង សហសម័យរបស់កម្ពុជា។

លោកស្រី ឡោទី នីអា តំណាងឲ្យប្រតិភូកិត្តិយស និងស្ថានទូតសាធារណរដ្ឋឥណ្ឌូនេស៊ីប្រចាំនៅកម្ពុជាបានចារចំណារអនុស្សាវរីយ៍លើសៀវភៅក្រាំងមាសរបស់ «បណ្ណាល័យសម្តេចម៉ែ» ដែលមានអត្ថន័យដូចតទៅ៖

***"យើងខ្ញុំពិតជាសូមអរគុណជាពន់ពេកសម្រាប់ទស្សនកិច្ចក្នុងថ្ងៃនេះ ដោយយើងខ្ញុំបានសិក្សាផ្លូវគ្រប់អំពីរឿងរ៉ាវជាច្រើន។ យើងខ្ញុំជឿជាក់ថាដំណើរទស្សនកិច្ចនេះ ពិតជាអាចជួយឱ្យយើងសិក្សាអំពីប្រវត្តិសាស្ត្រ ហើយយើងខ្ញុំសង្ឃឹមថាជនជាតិឥណ្ឌូនេស៊ីជាច្រើនទៀតនឹងអាចធ្វើទស្សនកិច្ចមកកាន់ «បណ្ណាល័យសម្តេចម៉ែ» ដើម្បីសិក្សាអំពីប្រវត្តិសាស្ត្រ រៀនសូត្រពីបទពិសោធន៍ និងបន្តដំណើរទៅមុខដើម្បីអនាគតដ៏ប្រសើរ។ ហើយជាការពិតណាស់ អ្វីទាំងអស់នេះ គឺជាការចងចាំដ៏វិសេសវិសាលមួយសម្រាប់យើងខ្ញុំ។ សូមជូនពរឆ្លងជោគជ័យដល់មជ្ឈមណ្ឌលឯកសារកម្ពុជា។"***











ភ្ញៀវកិត្តិយស តំណាងឲ្យស្ថានទូតសាធារណរដ្ឋឥណ្ឌូនេស៊ីប្រចាំនៅព្រះរាជាណាចក្រកម្ពុជាបានទស្សនកិច្ច «បណ្ណាល័យសម្តេចម៉ែ» នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០២០។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ស្ទើរពេញមួយជីវិតជួបតែសង្គ្រាម

សុខ វណ្ណៈ



*ហែម ជាវ អាយុ៦៩ឆ្នាំ រស់នៅក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ (សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ហែម ជាវ អាយុ៦៩ឆ្នាំ មានស្រុកកំណើតនៅស្រុកកំពង់ត្រឡាចលើ ខេត្តកំពង់ឆ្នាំង។ ហែម ជាវ មានប្រពន្ធឈ្មោះ កង សុធាវី និងកូនចំនួនពីរនាក់។

សព្វថ្ងៃ ហែម ជាវ និងក្រុមគ្រួសាររស់នៅក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ ហែម ជាវ បានរៀបរាប់ថា ខ្ញុំបានឃ្លាតចេញពីស្រុកកំណើតតាំងពីអាយុ១៨ឆ្នាំ ដោយសារតែប្រទេសជាតិកើតមានសង្គ្រាម។

កាលពីកុមារភាពខ្ញុំធ្លាប់ស្រមៃថា ពេលធំឡើងសុំឪពុកម្តាយចូលរៀនសូត្រឲ្យមានចំណេះដឹងខ្ពង់ខ្ពស់អាចចូលធ្វើជាមន្ត្រីរាជការបាន ជាពិសេសធ្វើគ្រូបង្រៀនមានប្រាក់ខែច្រើន មានញាតិមិត្តស្រឡាញ់រាប់អាន។ ខ្ញុំខំរៀនបានរហូតប្រឡងជាប់ឌីប្លូម និងមានបំណងរៀនបន្តនៅភ្នំពេញ។ ប៉ុន្តែមិននឹកស្មានថាបំណងទាំងនោះបានរលាយបាត់អស់នៅពេលប្រទេសជាតិកើតមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ។ ពេលនោះប្រទេសជាតិមានភាពវឹកវរ និងមានបាតុកម្មតវ៉ាទាមទារឲ្យសម្តេចព្រះ នរោត្តម សីហនុ មកគ្រប់គ្រងប្រទេសវិញ។ ចំណែកប្រជាជនភាគច្រើននៅតាមស្រុកស្រែចម្ការមិនគាំទ្ររបបសាធារណរដ្ឋដែលដឹកនាំដោយលោកសេនាប្រមុខ លន់ នល់ ឡើយ។

ខ្ញុំជាយុវជនមួយរូបដែលមានភក្តីភាពចំពោះសម្តេចព្រះ នរោត្តម សីហនុ បានឮការអំពាវនាវរបស់ព្រះអង្គដែលបានចាក់ផ្សាយតាមវិទ្យុពីទីក្រុងប៉េកាំងប្រទេសចិនមកថា កូនចៅក្រោកឈរឡើងតស៊ូដើម្បីរំដោះជាតិ រំដោះទឹកដីឲ្យរួចផុតពីរបបជិះជាន់ របបនាយទុនសក្តិភូមិ។ នៅក្នុងខែ៨ឆ្នាំ១៩៧០ ខ្ញុំបានស្ម័គ្រចិត្តចូលព្រៃម៉ាគីជាមួយមិត្តភក្តិដែលរស់នៅក្នុងភូមិជាមួយគ្នាចំនួន៧នាក់ ទៀត ដោយមុនដំបូងខ្ញុំបានចូលធ្វើជាយោធាស្រុកកំពង់ត្រឡាច។

នៅឆ្នាំ១៩៧២ អង្គការបានបញ្ជូនខ្ញុំឲ្យទៅធ្វើជាយោធានៅក្នុងភូមិភាគនិរតី ក្នុងកងពលទី១ ដែលមានប្រធានកងពលឈ្មោះ សឿង ឈ្មោះ ស៊ុំ ម៉េត និងមានសមាជិកកងពលឈ្មោះតាល្វៃ។ នៅឆ្នាំ១៩៧៣ ខ្ញុំបានឡើងជាសមាជិកអនុសេនាតូចលេខ៣០២ ដែល

មានប្រធានឈ្មោះ វឿនៗ ពេលនោះកងពលទី១ មានមុខព្រួញវាយតទល់ជាមួយទាហានលោក លន់ នល់ តាមផ្លូវជាតិលេខ៥ សំដៅមកទីក្រុងភ្នំពេញៗ ពេលឡើងវាយនៅក្នុងសមរភូមិម្តងៗខ្ញុំបានឃើញទាហាន លន់ នល់ ស្លាប់ និងរបួសច្រើនជាងយោធាខ្មែរក្រហមៗ

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមគ្រប់កងពលទាំងអស់បានវាយយកទីក្រុងភ្នំពេញបានទាំងស្រុងៗ ខ្ញុំបានឃើញប្រជាជនមួយចំនួនមានការភ័យខ្លាច រីឯមួយចំនួនទៀត ដើរតាមដង្ហែរជាមួយយោធាខ្មែរក្រហមដើម្បីអបអរជ័យជម្នះៗ បន្ទាប់មកខ្ញុំបានឃើញប្រជាជនមួយចំនួនធំរៀបចំឥវ៉ាន់ និងនាំកូនចៅចាកចេញពីផ្ទះសំបែងដើម្បីសំដៅទៅស្រុកកំណើត ឬ ទៅតំបន់ផ្សេងៗដែលអាចទៅបាន ព្រោះទីក្រុងភ្នំពេញមិនតម្រូវឲ្យប្រជាជនរស់នៅឡើយៗ យោធាខ្មែរក្រហមបានប្រាប់ប្រជាជនថា មានយន្តហោះអាមេរិកាំងមកទម្លាក់គ្រាប់បែកដូច្នេះបងប្អូនត្រូវប្រញាប់ចាកចេញៗ ក្រោយពីប្រជាជនចាកចេញអស់ អង្គភាពរបស់ខ្ញុំ បានមកស្នាក់នៅទីក្រុងភ្នំពេញបានរយៈពេលជាងមួយខែ ដើម្បីបោសសម្អាតទីក្រុង បន្ទាប់មកអង្គការបានបញ្ជូនខ្ញុំទៅឈរជើងនៅកំបូល ក្នុងស្រុកអង្គស្នួលវិញៗ

នៅខែធ្នូ ឆ្នាំ១៩៧៥ ខ្ញុំនិងអង្គភាពទាំងមូលត្រូវអង្គការចាត់តាំងឲ្យទៅការពារព្រំដែនក្នុងខេត្តកោះកុង ដែលមានទីបញ្ជាការនៅជិតវត្តជោតញ្ញាណទល់មុខបឹងយុនឆាងៗ កាលនោះខ្ញុំនៅក្នុងវរសេនាធំលេខ៣៨ ដែលមានប្រធានឈ្មោះ ផល់ និងឈ្មោះ វឿន រីឯខ្ញុំទទួលតួនាទីជាប្រធានកងរយដឹកនាំមនុស្សប្រមាណមួយរយនាក់ៗ ពេលខ្ញុំមកដល់ដំបូង ខ្ញុំឃើញប្រជាជនតែ ៣០ ទៅ៤០ គ្រួសារប៉ុណ្ណោះ ព្រោះប្រជាជនមួយចំនួនបានភៀសខ្លួន



ផ្លូវក្រាលគ្រួសក្រហមនៅលើភ្នំតាកុច ក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ៗ (សោម ប៊ុនថន/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ស្ពានដែក ឬស្ពានថ្មដា ដែលទទួលរងការខូច ហើយបច្ចុប្បន្នប្រជាជនឈប់ប្រើប្រាស់ហើយ។ ប្រជាជនបានធ្វើដំណើរលើស្ពាន និងផ្លូវដែលទើបសាងសង់ថ្មីជំនួសវិញ។
( ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ស្ទឹងមេទឹក ស្ថិតនៅក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។
( ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ទៅតំបន់គិរីវង់ ព្រំដែនកម្ពុជា-ថៃ និងមួយចំនួនទៀតបានចូលទៅក្នុងទឹកដីថៃ។ ខ្ញុំបានដឹកនាំកម្លាំងយោធាសំដៅទៅគិរីវង់ ប៉ុន្តែមិនបានឃើញប្រជាជនទេ។ ខ្ញុំឃើញតែចម្ការដំឡូង ចម្ការត្រឡាច ល្ពៅ និងម្ទេស ដែលប្រជាជនបោះបង់ចោល។ នៅតាមផ្លូវ ខ្ញុំបានឃើញសាកសពមនុស្សដែលរលួយ និងឃើញស្លាកស្នាមដែលសត្វខ្លាខាំអូសនៅរាយប៉ាយតាមផ្លូវ។

ពេលខ្ញុំមកដល់ដំបូងមានឈ្មោះ តាប្រាឆារ ហៅ ប្រសិទ្ធ ហៅ ចុង គឺជាគណៈតំបន់១១ តំបន់កោះកុង ប៉ុន្តែគាត់រួមទាំងកម្មាភិបាលខ្មែរក្រហមមួយចំនួនទៀតត្រូវបានអង្គការចាប់ខ្លួន។ មានកម្មាភិបាលខ្មែរក្រហមមួយចំនួនដែលដឹងខ្លួនមុនក៏បានរត់គេចខ្លួនចូលព្រៃ និងបន្តទៅលាក់ខ្លួននៅក្នុងទឹកដីប្រទេសថៃ។

បន្ទាប់ពីអង្គការចាប់ខ្លួនកម្មាភិបាលថ្នាក់តំបន់កោះកុងអស់ អង្គការបានជម្លៀសប្រជាជនទាំងអស់ចេញពីតំបន់កោះកុងឲ្យមករស់នៅតំបន់ ៣៧។ ប្រធានយោធាតំបន់៣៧ ឈ្មោះ អួនយ៉ង់ ដែលបានដឹកនាំកងទ័ពការពារព្រំដែនគោក និងព្រំដែនទឹកនៅកោះកុងក្រៅ។ ចំណែកវរសេនាធំលេខ៣៨ ប្រចាំការនៅទួលគគីរ ទួលស្វាយ និងគិរីវង់។ នៅខែមេសា ឆ្នាំ១៩៧៦ យោធាខ្មែរក្រហមបានវាយប្រយុទ្ធជាមួយទាហានថៃចំនួនបីលើកនៅព្រំដែនគោក ហើយក្រោយមកក៏បានស្ងប់ស្ងាត់ទៅវិញ។

នៅឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយចូលមក មាស មុត ប្រធានកងពលលេខ ១៦៤ ប្រចាំការនៅក្រុងកំពង់សោម បានយកកប៉ាល់ថ្មីបួនគ្រឿងដែលប្រទេសចិនផ្តល់ឲ្យរបបកម្ពុជាប្រជាធិបតេយ្យទុកសម្រាប់ការពារដែន



ទេសភាពឈូងសមុទ្រ និងភូមិរបស់ប្រជាជនថៃ ថតពីលើកំពូលភ្នំ១០០ ស្ថិតនៅឃុំបាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង។ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

សមុទ្រមកកម្ទេចចោលនៅខេត្តកោះកុង។ បន្ទាប់មកខ្ញុំនិងយោធានៅក្នុងកងពល ១៦៤ បាននាំគ្នាឡើងគោករត់ចូលព្រៃ។ ខ្ញុំមិនហ៊ានត្រឡប់ទៅស្រុកកំណើតវិញទេ ព្រោះខ្លាចកងទ័ពវៀតណាម។ ខ្ញុំបានភៀសខ្លួនចូលព្រៃជាមួយយោធាក្នុងអង្គភាព និងកម្មករលាយឡំជាមួយប្រជាជន។ ខ្ញុំវង្វេងផ្លូវ និងវង្វេងនៅក្នុងព្រៃជាច្រើនថ្ងៃ។ ខ្ញុំមានសំណាងបានយោធាដែលរួមដំណើរជាមួយជួយរកអាហារឲ្យហូបរហូតបានជួប តាសេង តារ៉ែន តាអ៊ឹម ប្រធានកងពលទី ២ និងទី ៣។ បន្ទាប់មកយើងបានរស់នៅតស៊ូប្រឆាំងនឹងកងទ័ពវៀតណាមនៅម្តុំថ្មដា និងតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។

ពេលនោះ ខ្ញុំ និងកងកម្លាំងខ្មែរក្រហមដទៃទៀតយល់ថា វត្តមានកងទ័ពវៀតណាមនៅលើទឹកដីកម្ពុជាគឺជាការឈ្លានពាន។ សង្គ្រាមបានចាប់ផ្តើមសារជាថ្មីម្តងទៀតរវាងកងកម្លាំងខ្មែរក្រហម និងកងទ័ពវៀតណាមដែលសហការជាមួយកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ការច្បាំងគ្នាបានបន្តជាងមួយទសវត្សរ៍ ដែលធ្វើឲ្យមនុស្សស្លាប់ និងពិការជាច្រើននាក់។ កងកម្លាំងខ្មែរក្រហមមានចំនួនតិចតួច និងគ្មានទីតាំងឈរជើងច្បាស់លាស់ដូចកងទ័ពវៀតណាមនិងកងទ័ពនៃរបបសាធា-រណរដ្ឋប្រជាមានិតកម្ពុជាទេ។ ដូច្នេះយោធាខ្មែរក្រហមបានប្រើយុទ្ធសាស្ត្រវាយឆ្មក់។

នៅឆ្នាំ១៩៨៤ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានកេណ្ឌប្រជាជនឲ្យមកកាប់ឆ្ការព្រៃធ្វើផ្លូវដើម្បីងាយស្រួលដល់កងទ័ពវៀតណាម និងកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាវាយដណ្តើមកាន់កាប់តំបន់ព្រំដែនកម្ពុជា-ថៃ។ ពេលនោះយោធាខ្មែរក្រហមបានរត់ទៅជ្រកលើទឹកដីថៃមួយរយៈ បន្ទាប់មកបានលួច

ចូលមកក្នុងទឹកដីកម្ពុជាធ្វើសង្គ្រាមវាយឆ្មក់បន្តទៀត។

នៅឆ្នាំ១៩៨៩ កងទ័ពវៀតណាមបានដកចេញពីប្រទេសកម្ពុជា ដែលជាឱកាសសម្រាប់យោធាខ្មែរក្រហមវាយដណ្ដើមយកទីតាំងមួយចំនួនមកកាន់កាប់វិញ ដូចជា ភ្នំ១០០ ភ្នំតាកុប ថ្មដា ស្ទឹងមេទឹក ស្ទឹងតូច និងកន្លែងជាច្រើនទៀត។ ទោះបីកងទ័ពវៀតណាមដកគ្រឡប់ទៅប្រទេសវិញពិតមែនប៉ុន្តែកងទ័ពខាងរដ្ឋាភិបាល និងកម្លាំងខ្មែរក្រហមនៅតែបន្តធ្វើសង្គ្រាម។

នៅឆ្នាំ១៩៩៣ អង្គការសហប្រជាជាតិបានរៀបចំមានការបោះឆ្នោតជាលើកដំបូងនៅកម្ពុជា រីឯកម្លាំងខាងខ្មែរក្រហមបានបដិសេធមិនចូលរួមក្នុងការបោះឆ្នោតទេ ដែលធ្វើឲ្យសង្គ្រាមនៅតែអូសបន្លាយ។ ពេលនោះយោធាខ្មែរក្រហមមួយចំនួនបានចាប់ផ្ដើមរកស៊ីជាមួយថៃ និងបង្កើតបានភូមិសម្រាប់រស់នៅជាមួយក្រុមគ្រួសារនៅតាមជាយដែន។ ខ្ញុំនិងយោធាខ្មែរក្រហមដ៏ទៃទៀតមិនហ៊ានសង់ផ្ទះរឹងមាំរស់នៅទេ គឺធ្វើតែខ្ទមតូចៗ ព្រោះសង្គ្រាមនៅបន្ត។ ខ្ញុំបានចល័តទៅរស់នៅទីតាំងផ្សេងៗ។

នៅឆ្នាំ១៩៩៦ ខ្ញុំមានការសប្បាយចិត្តដោយសារសម្ដេច ហ៊ុន សែន ប្រកាសគោលនយោបាយឈ្នះ ឈ្នះ ដោយគ្មានអ្នកឈ្នះ គ្មានអ្នកចាញ់ គឺទី១) រក្សាអាយុជីវិត ទី ២) រក្សាតួនាទី និងទី៣) រក្សាទ្រព្យសម្បត្តិដីធ្លីដល់កងកម្លាំងខ្មែរក្រហមដែលបានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា។ សព្វថ្ងៃខ្ញុំមានផ្ទះសម្បែងបានទៅលេងឪពុកម្ដាយបងប្អូននិងបានទៅធ្វើបុណ្យនៅវត្ត ចំណែកកូនចៅរបស់ខ្ញុំបានចូលរៀនសូត្រនៅសាលា។



ភ្នំថ្មដា ស្ថិតនៅក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ផ្លែន រុន ជនជាតិស្ទៀងនៅភូមិអញ្ចាញ

**រី លក្ខិណា**



ផ្លែន រុន អាយុ៦០ឆ្នាំ គឺជាជនជាតិស្ទៀង មានស្រុកកំណើតនៅភូមិអញ្ចាញ ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម បច្ចុប្បន្នស្ថិតនៅខេត្តត្បូងឃ្មុំ។ (រី លក្ខិណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ផ្លែន រុន អាយុ៦០ឆ្នាំ គឺជាជនជាតិស្ទៀង មានស្រុកកំណើតនៅភូមិអញ្ចាញ ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម បច្ចុប្បន្នស្ថិតនៅខេត្តត្បូងឃ្មុំ។ ឪពុករបស់ខ្ញុំឈ្មោះ ផ្លែន និងម្ដាយឈ្មោះប៉ុ។ ខ្ញុំមានបងប្អូនបង្កើតចំនួន ៤នាក់ គឺស្រី១នាក់ និងប្រុស៣នាក់។ ខ្ញុំជាកូនច្បងនៅក្នុងគ្រួសារ។ ប្រពន្ធរបស់ខ្ញុំឈ្មោះ ច្រឹង សាមុត និងមានកូនចំនួន៥នាក់ (ស្រីចំនួន២នាក់ និងប្រុសចំនួន៣នាក់)។

កាលពីនៅតូចខ្ញុំមិនសូវបានរៀនសូត្រទេ ពីព្រោះនៅចុងទសវត្សរ៍ឆ្នាំ១៩៦០ ភូមិអញ្ចាញ និងតំបន់ជុំវិញនោះមានការទម្លាក់គ្រាប់បែក និងមានសង្គ្រាមកើតឡើងរវាងកងទ័ពវៀតកុងដែលបានមកបោះជំរំនៅតាមព្រំដែនកម្ពុជា-វៀតណាម, តាមព្រៃក្បែរៗភូមិអញ្ចាញ និងកងទ័ពអាមេរិក។ អ្នកភូមិបាននាំគ្នាយកស្រូវទៅលាក់ទុកក្នុងព្រៃ ហើយក៏គ្មានអ្នកណាហ៊ានរស់នៅក្នុងភូមិដែរ។ យើងបាននាំគ្នាទៅលាក់ខ្លួននិងដាំបាយហូបក្នុងព្រៃ នៅពេលយប់ស្ងាត់ៗ ឪពុកខ្ញុំ និងអ្នកភូមិផ្សេងទៀត បានរកស៊ីលក់អង្ករឲ្យកងទ័ពវៀតកុងនៅព្រំដែនកម្ពុជា-វៀតណាម នៅតាមទន្លេចាមៗ ឪពុករបស់ខ្ញុំបានទិញអង្ករដែលឈ្មួញដឹកមកពីក្រុងកំពង់ចាម ក្រុងសួង ដោយក្នុងមនុស្សម្នាក់អាចទិញអង្ករបានតែ ២ទៅ៣បាវ ប៉ុណ្ណោះ ដើម្បីទុកលក់បន្ត។ របរលក់អង្ករនេះ ឪពុកខ្ញុំបានធ្វើដោយលួចលាក់ គឺគាត់ដឹកចេញទៅលក់នៅពេលយប់ៗ ខ្ញុំធ្លាប់បានឃើញកងទ័ពយៀកកុងចេញចូលក្នុងភូមិអញ្ចាញ បន្ទាប់មកបានធ្វើដំណើរបន្តចូលទៅ ស្រុកដំបែរ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម និង ស្រុកស្នួល ខេត្តក្រចេះ។ ខ្ញុំមិនធ្លាប់បានឃើញកងទ័ពវៀតកុងធ្វើបាបប្រជាជនទេ ប៉ុន្តែខ្ញុំបានឃើញទាហានធីវគី លួច ឆក់ ប្លន់ និងធ្វើបាបប្រជាជន។ នៅសម័យនោះ ទាហានធីវគីបាននិយាយថា ប្រជាជនខ្មែរគឺមានសម្បុរខ្មៅ ចំណែកអ្នកដែលមានសម្បុរស គឺជាកងទ័ពវៀតកុង ដូច្នេះត្រូវតែចាប់ធ្វើទារុណ និងសម្លាប់ចោល។ ស្រីៗដែលមានរូបសម្រស់ស្អាតមួយចំនួនក៏ត្រូវបានទាហានធីវគីចាប់រំលោភ និងធ្វើបាបដែរ។ ឃើញដូច្នេះប្រជាជនមួយចំនួនបានរត់ទៅចូលរួមជាមួយចលនាបដិវត្តន៍ខ្មែរក្រហមវិញ។ ពេលនោះឈ្មោះភូមិមួយក៏ត្រូវបានផ្លាស់ប្ដូរឈ្មោះដែរ ដូចជា ភូមិអញ្ចាញដែលចាស់ៗ បានហៅតាមឈ្មោះ អូរតូច មួយស្ថិតនៅក្នុងភូមិ។ នៅក្នុង

អំឡុងឆ្នាំ១៩៧៤ កម្មាភិបាលខ្មែរក្រហមម្នាក់ឈ្មោះ សេង គឺជាប្រធានយុវជនស្រុកត្រមូង ប្រចាំការនៅភូមិអញ្ចាញ និងជាអ្នកដើរឃោសនាប្រជាជននៅក្នុងភូមិ តែងតែលើកឡើងថា ឈ្មោះភូមិអញ្ចាញៗ គឺគាត់ពិបាកហៅដោយសារតែសំនៀងៗ មានថ្ងៃមួយ សេង និងកងឈ្លបខ្មែរក្រហមម្នាក់ទៀតបានទៅបេះក្រូចថ្លុងនៅដីចម្ការ បន្ទាប់មកបានដើរចុះងូតទឹកនៅព្រែកទន្លង ពេលនោះក៏ឃើញថ្មដុះនៅចំកណ្តាលព្រែក និងមានទឹកហូរអមសងមើលទៅហាក់ដូចជាកោះៗ ក្រោយមក សេង ក៏បានហៅកម្មាភិបាល យុទ្ធជន និងប្រជាជននៅក្នុងភូមិមកប្រជុំគ្នាដើម្បីប្តូរឈ្មោះ ពីភូមិអញ្ចាញមកភូមិកោះថ្ម និងជាប់ឈ្មោះរហូតមកដល់សព្វថ្ងៃ។

បន្ទាប់ពីខ្មែរក្រហមឡើងកាន់កាប់ប្រទេសកម្ពុជានៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ភូមិរបស់ខ្ញុំនៅហូបបាយតាមផ្ទះរៀងខ្លួននៅឡើយៗ រហូតដល់ឆ្នាំ១៩៧៦ ទើបអង្គការប្រមូលប្រជាជនឲ្យហូបបាយរួមនៅក្នុងសហករណ៍ៗ កាលនោះតំបន់ដែលខ្ញុំរស់នៅគឺអង្គការបានចាត់ឈ្មោះតាចែម ធ្វើជាប្រធានឃុំ, ឈ្មោះតាពាល ធ្វើជាប្រធានភូមិ និងឈ្មោះ តាហែ ធ្វើជាអនុភូមិៗ ការងាររបស់ខ្ញុំពេលនោះគឺអង្គការចាត់តាំងឲ្យចូលកងចល័ត ធ្វើស្រែ និងលើកទំនប់ៗ

នៅអំឡុងឆ្នាំ១៩៧៧ ប្រធានឃុំដើរជ្រើសរើសយោធាស្រុកនៅតាមភូមិ ដោយក្នុងមួយភូមិត្រូវជ្រើសរើសយកមនុស្ស ៣ នាក់ ។ នៅក្នុងសម័យនោះឃុំទន្លូងមាន ៣ភូមិ ដូច្នេះ យោធាដែលរើសចេញពីឃុំទន្លូងមាន៩នាក់ៗ ក្នុងចំណោមអ្នកដែលត្រូវបានជ្រើសរើសនោះក៏មានឈ្មោះខ្ញុំដែរៗ ខ្ញុំបានផ្លាស់ពីកងចល័តមកធ្វើជាយោធាស្រុកដែលមានប្រធានយោធាស្រុកឈ្មោះ សឿន, គណៈស្រុកឈ្មោះ ស្រេង និងអនុស្រុកឈ្មោះ ព្រឿងៗ ចាប់តាំងពីពេលនោះមកខ្ញុំក៏បានបែកពីឪពុកម្តាយខ្ញុំៗ

នៅចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨ ប្រជាជនភូមិកោះថ្ម ត្រូវបានជម្លៀសឲ្យមករស់នៅតាំឡាំ ឬហៅថាស្រែទូលាយ ដែលមានចម្ងាយប្រហែល ១០ គីឡូម៉ែត្រពីភូមិកោះថ្មៗ នៅក្នុងពាក់កណ្តាលឆ្នាំ១៩៧៨ កងទ័ពមជ្ឈិមបានចុះមកចាប់ថ្នាក់ដឹកនាំស្រុក ឃុំ និងភូមិ ចំណែកប្រជាជនកោះថ្មត្រូវបានជម្លៀសពីស្រែទូលាយទៅរស់នៅភូមិអាលួចក្នុងស្រុកស្នួល តំបន់ស្វយ័ត៥០៥ ឬតំបន់ក្រចេះវិញៗ នៅភូមិអាលួចនោះ ប្រជាជនមិនមានរបបអាហារហូបចុកគ្រប់គ្រាន់ទេ គឺហូបតែបបរប៉ុណ្ណោះ ហើយថែមទាំងកម្មាភិបាលខ្មែរក្រហមនៅមូលដ្ឋានបានចោទប្រជាជនទាំងនោះថា «ក្បាលយួន ខ្លួនខ្មែរ» ទៀតៗ ឪពុករបស់ខ្ញុំ និងប្រជាជនដែលបានជម្លៀសពីភូមិកោះថ្មមកនៅភូមិអាលួចបានស្លាប់អស់ជាច្រើន ដោយសារអត់អាហារ និងធ្វើការហួសកម្លាំងៗ

ក្រោយពីឈប់ធ្វើយោធា ខ្ញុំត្រូវបានជម្លៀសទៅភូមិអាលួចដែរៗ នៅទីនោះគឺជាព្រៃ ដូច្នេះប្រជាជនត្រូវកាប់គាស់គល់ឈើដើម្បីរានដីធ្វើស្រែៗ ខ្ញុំរស់នៅភូមិអាលួចបានមួយរយៈ ខ្មែរក្រហមបានជម្លៀសខ្ញុំមកនៅស្រុកចម្ការលើ តំបន់ ៤២វិញ ។ នៅទីនោះ កម្មាភិបាលខ្មែរក្រហមបានបែងចែកប្រជាជនទៅតាមក្រុមផ្សេងៗគ្នាៗ ខ្ញុំនៅខាងក្រុមបេះផ្លែកប្បាសៗ ខ្ញុំត្រូវភ្ញាក់នៅម៉ោង៤ភ្លឺដើម្បីហូបបាយ ហើយម៉ោង៦ត្រូវចេញទៅធ្វើការៗ នៅវេលាថ្ងៃត្រង់ខ្ញុំឡើងមកហូបដំឡូង រួចហើយធ្វើការបន្តរហូតដល់ល្ងាចម៉ោង៦ទើបបានហូបបាយៗ

ខ្ញុំធ្វើការនៅចម្ការលើបានរយៈពេលមួយខែ កងទ័ពវៀតណាមបានវាយចូលមកដល់ៗ ខ្ញុំបានរត់ភៀសខ្លួនទៅដល់ខាងស្រុកបារាយណ៍ខេត្តកំពង់ធំៗ ពេលនោះកងទ័ពរបស់វៀតណាម បានបែងចែកកងកម្លាំងទៅតាមទិសដៅ ខេត្តកំពង់ធំ ស្គន់ ភ្នំពេញ និងកំពង់ឆ្នាំងៗ កងទ័ពវៀតណាមប្រកាសប្រាប់ប្រជាជនឲ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនៗ នៅតាមផ្លូវ ខ្ញុំមានការខ្វះខាតអាហារយ៉ាងខ្លាំងៗ ខ្ញុំបានទៅបូតស្រូវទុំនៅតាមវាលស្រែយកមកបុករែងយកអង្ករ មកដាំបាយហូប ដើម្បីបន្តដំណើរទៀតៗ ខ្ញុំបានចំណាយរយៈពេលប្រាំពីរថ្ងៃទើបមកដល់ផ្ទះៗ ខ្ញុំបានជួបម្តាយនិងប្អូនៗនៅស្រុកចម្ការលើ និងបានត្រឡប់មកស្រុកកំណើតជាមួយគ្នាៗ យើងបាននាំគ្នាកាប់ឆ្ការព្រៃនៅក្នុងភូមិដើម្បីសង់លំនៅដ្ឋានឡើងវិញៗ

# ភូមិអញ្ចាញ ឬ ភូមិកោះថ្ម ក្នុងរបបខ្មែរក្រហម

គាត ស្រីឡែន


ខ្ទមអ្នកតាក្រហមកចាស់។ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០។ (រី លក្ខិណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)


ខ្ទមអ្នកតាក្រហមកដែលត្រូវបានសាងសង់ថ្មីៗ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០។ (រី លក្ខិណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ភូមិអញ្ចាញ ឬ ភូមិកោះថ្ម ស្ថិតនៅក្នុងឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម ដែលសព្វថ្ងៃស្ថិតនៅក្នុងខេត្តត្បូងឃ្មុំ។ អ្នកភូមិអញ្ចាញភាគច្រើនមានដើមកំណើតជាជនជាតិភាគតិច ស្ទៀង និងមានជំនឿលើការបន់ស្រន់អារក្ស និងអ្នកតា។ នៅពេលមានជួបគ្រោះអាសន្នដូចជាមានជំងឺព្យាបាលមិនជា ឬបាត់របស់ទ្រព្យ អ្នកភូមិតែងតែនាំគ្នាទៅបញ្ជូនអារក្ស ឬបន់ស្រន់សូមជំនួយពីអ្នកតាសូមឲ្យជាសះពីជំងឺតម្កាត់ ឬបានរកឃើញរបស់ទ្រព្យដែលបាត់បង់នោះផង។ នៅពេលដែលការបន់ស្រន់បានសម្រេចដូចបំណង អ្នកភូមិតែងតែយក ជ្រូក មាន់ ទា គោ ក្របី ទៅថ្វាយដើម្បីលាបំណន់ និងដើម្បីអរគុណដល់អារក្ស ឬអ្នកតាដែលបានជួយថែរក្សា។ អ្នកតាដែលអ្នកភូមិកោះថ្មភាគច្រើនបានជឿជាក់ថាស័ក្តិសិទ្ធិមានឈ្មោះ «អ្នកតាក្រហមក»។

សព្វថ្ងៃខ្ទមអ្នកតាក្រហមកមានទីតាំងនៅមុខសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុនសែន កោះថ្ម។ អ្នកភូមិតែងតែធ្វើពិធីឡើងអ្នកតាជារៀងរាល់ឆ្នាំនៅរយៈពេល២-៣ថ្ងៃមុនពេលពិធីចូលឆ្នាំខ្មែរចូលមកដល់។ នៅពេលធ្វើ

ពិធីឡើងអ្នកតាម្តងៗ អ្នកភូមិបានចូលរួមតាមលទ្ធភាព និងការស្ម័គ្រចិត្ត ដោយយក មាន់ ទា ជ្រូក និង ក្បាលជ្រូក មកចូលរួមពិធីសែនព្រេនរួមគ្នាៗ បន្ទាប់ពីរៀបចំសែនព្រេនរួចហើយ អ្នកភូមិនាំគ្នាហូបបាយជុំគ្នា និងកម្មវិធីលេងល្បែងប្រជាប្រិយយ៉ាងសប្បាយរីករាយៗ

បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃ១៨ មីនា ឆ្នាំ១៩៧០ ភូមិអញ្ចាញ ឬកោះថ្ម ត្រូវបានខ្មែរក្រហមគ្រប់គ្រងឬហៅថាតំបន់រំដោះៗ ប្រជាជនម្នាក់ដែលបានរស់នៅក្នុងភូមិកោះថ្មបានរៀបរាប់ថា៖

ខ្ញុំឈ្មោះ មិច មាន់ សព្វថ្ងៃអាយុ៧៨ឆ្នាំ មានប្រពន្ធឈ្មោះ មេ ដេង អាយុ៧៣ឆ្នាំ និងមានកូន៧នាក់ៗ កូនរបស់ខ្ញុំបានស្លាប់អស់២នាក់ ដោយសារជំងឺ ៗ ខ្ញុំមានស្រុកកំណើតនៅភូមិអញ្ចាញ ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម ដែលសព្វថ្ងៃខេត្តត្បូងឃ្មុំៗ



មិច មាន់ ផ្តល់បទសម្ភាសន៍ដល់ គាត ស្រីឡែន នៅផ្ទះរបស់គាត់ នៅក្នុងភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំៗ
(គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីតូច ខ្ញុំត្រូវបានឪពុកម្តាយបញ្ជូនឲ្យទៅរៀនជាមួយព្រះសង្ឃនៅវត្តក្តុលផ្សារ ពីព្រោះនៅក្នុងភូមិអញ្ចាញមិនទាន់មានសាលារៀនៗ ខ្ញុំបានឈប់រៀននៅមុនឆ្នាំ១៩៧០ៗ ពេលនោះខ្ញុំអាចអាន និងសរសេរអក្សរបានបន្តិចបន្តួចប៉ុណ្ណោះៗ នៅឆ្នាំ១៩៧៣ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យបង្រៀនក្មេងៗនៅក្នុងភូមិអញ្ចាញៗ ខ្ញុំបង្រៀនក្មេងៗទៅតាមសមត្ថភាពដែលខ្ញុំបានចេះ ដូចជា បង្រៀនក្មេងៗឲ្យអានអក្សរ សរសេរអក្សរកម្រិតថ្នាក់កុមារដ្ឋាន និងបង្រៀនពីរបៀបធ្វើប្រមាណវិធី បូក ដក គុណ និងចែកៗ

បន្ទាប់ពីខ្មែរក្រហមបានឡើងកាន់អំណាចនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានផ្លាស់ខ្ញុំពីគ្រូបង្រៀនក្មេងមកធ្វើជាប្រធានក្រុមដឹកនាំប្រជាជនធ្វើស្រែចម្ការវិញៗ នៅខណៈនោះ ប្រជាជនត្រូវបានរៀបចំឲ្យរស់នៅហូបចុកក្នុងសហករណ៍ និងបានបែងចែកឲ្យធ្វើការងារពលកម្មតាមកង និងក្រុមរៀងៗខ្លួនៗ នៅក្នុងភូមិកោះថ្ម ខ្មែរក្រហមបានរៀបចំជាសហករណ៍មួយ ហើយប្រជាជនទាំងអស់តម្រូវឲ្យមកហូបចុករួមគ្នាៗ

ប្រជាជននៅភូមិកោះថ្មត្រូវបានបែងចែកឲ្យធ្វើការងារពលកម្ម ដូចជា លើកទំនប់ ជីកប្រឡាយ និងធ្វើស្រែចម្ការតាមកង និងក្រុមរៀងៗខ្លួនៗ ចំណែកខ្ញុំដែលជាប្រធានក្រុម ត្រូវ ទទួលបញ្ជាពីប្រធានកងឲ្យដឹកនាំសមាជិកក្នុងក្រុមចុះទៅលើកទំនប់ និងធ្វើការការស្រែចម្ការៗ នៅពេលនោះខ្ញុំបានបែងចែកសមាជិកក្រុមជាពួកៗ ដើម្បីងាយស្រួល និងធ្វើការងារបានលឿនតាមផែនការដែលប្រធានកងដាក់ឲ្យធ្វើៗ នៅពេលមានការប្រជុំជាមួយប្រធានកង ខ្ញុំត្រូវដើរហៅសមាជិកក្រុមមកចូលរួមប្រជុំដើម្បីស្តាប់តាមការណែនាំ និងការចាត់ចែងការងារពីប្រធានកង ដូចជា ការលើកភ្លឺស្រែ និងទប់ទំនប់ស្រែប្រាំងៗ ទោះខ្ញុំជាប្រធានក្រុមក៏ខ្ញុំត្រូវធ្វើការងារពលកម្មដូចសមាជិកក្រុមដែរៗ នៅក្នុងរបបខ្មែរក្រហម ប្រជាជនត្រូវធ្វើការងារពលកម្មជាច្រើនម៉ោងក្នុងថ្ងៃៗ ដូចជា លើកទំនប់ ជីកប្រឡាយ លើកភ្លឺស្រែ ភ្ជួរស្រែ ប្រូតស្រូវ និងដឹកជញ្ជូនៗ ចំណែករបបអាហារហូបចុក

គឺមិនបានគ្រប់គ្រាន់ទេ មានពេលខ្លះត្រូវហូបបាយលាយពោត ឬដំឡូង និងមានពេលខ្លះទៀតត្រូវហូបបបរជាមួយសម្លប្រលឹត និងត្រកួនៗ នៅក្នុងរបបខ្មែរក្រហម បើនរណាម្នាក់ហ៊ានគេចវេះមិនធ្វើតាមបញ្ជាថ្នាក់លើ គឺអ្នកនោះត្រូវបានថ្នាក់លើហៅទៅកសាងមិនខានៗ ពាក្យថាកសាងនរណាក៏ខ្លាចដែរ ពីព្រោះមានពេលខ្លះបើថ្នាក់លើហៅទៅកសាងហើយ គឺអ្នកនោះមិនឃើញត្រឡប់មកវិញទេៗ

នៅពាក់កណ្ដាលឆ្នាំ១៩៧៧ អ្នកភូមិកោះថ្មទាំងអស់ត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅ តុំថ្មុំ ឬហៅថាស្រែទូលាយ ដែលមានចម្ងាយប្រមាណជាង ១០គីឡូម៉ែត្រ ពីភូមិកោះថ្ម ។ អ្នកភូមិកោះថ្មបានរស់នៅនិងធ្វើស្រែនៅស្រែទូលាយបានរយៈពេលមួយវស្សាៗ បន្ទាប់ពីច្រូតស្រូវរួច ខ្មែរក្រហមបានជម្លៀសប្រជាជនភូមិកោះថ្មឲ្យទៅនៅក្នុងភូមិមួយក្នុងស្រុកស្នួល ខេត្តក្រចេះៗ ការរស់នៅស្រុកស្នួល គឺមានការលំបាកវេទនាខ្លាំង ហើយប្រជាជនមូលដ្ឋានមានការរើសអើងខ្លាំងជាមួយនឹងអ្នកជម្លៀសៗ ពេលនោះ ខ្ញុំត្រូវបានខ្មែរក្រហមប្រើឲ្យទៅដឹកដើមដំឡូងឈ្វាជាមួយប្រជាជនមូលដ្ឋាន **«កាលនោះ ខ្ញុំខ្លាចចិត្តណាស់យើងបររទេះទៅជាមួយគេដឹករបស់របរហូបចុកទៅជាមួយ យើងបររទេះនៅពីក្រោយ គេនៅពីមុខយើងដល់ពេលគេមានអីហូបគេហូបតែគ្នាគេ គេមិននឹកឃើញយើងបររទេះនៅពីក្រោយទេ គេមានពោតលីញហូប យើងនៅក្រោយអីចឹងគេគ្មានហៅយើងហូបមួយម៉ាត់ ពេលគេហូបឆ្អែត គេសុខចិត្តបោះពោតលីញនោះចោល មិនឲ្យយើងហូបសូម្បីមួយគ្រាប់»** ។

នៅចុងឆ្នាំ១៩៧៨ នៅខណៈពេលដែលកងទ័ពវៀតណាមវាយចូលមកដល់ស្រុកស្នួល ខ្មែរក្រហមបានជម្លៀសអ្នកភូមិកោះថ្មទៅទីរួមខេត្តក្រចេះបន្តទៀតៗ បន្ទាប់មកខ្មែរក្រហម បានដឹកប្រជាជានទាំងនោះតាមកាណូតពីខេត្តក្រចេះមកស្រុកស្ទឹងត្រង់នៃភូមិភាគកណ្ដាលៗ ពេលមកដល់ស្រុកស្ទឹងត្រង់ខ្មែរក្រហមបានដឹកប្រជាជនតាមឡានមកដាក់នៅស្រុកចម្ការលើបន្តទៀតៗ នៅយប់ដែលខ្មែរក្រហមដឹកប្រជាជនតាមឡាននោះខ្ញុំបានឮខ្មែរក្រហមនិយាយគ្នាអំពីផែនការសម្លាប់មនុស្ស ប៉ុន្តែខ្ញុំមិនបានដឹងច្បាស់ថា ខ្មែរក្រហមចង់សំដៅ



ផ្លូវនៅក្នុងភូមិកោះថ្មៗ ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២០ៗ
(វី លក្ខិណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

មកលើប្រជាជនភូមិកោះថ្មឬយ៉ាងណានោះទេៗ **«ខ្ញុំចេះតែមើលទៅទិសខាងកើត ហើយគិតក្នុងចិត្តថា បើសិនជា ស្លាប់ឬរស់ ធ្វើយ៉ាងម៉េចឲ្យតែបានត្រឡប់មកស្រុកកំណើតវិញស្លាប់ក៏អស់ចិត្តដែរ នឹកឃើញកូនអ្នកភូមិមួយចំនួននៅតូចមិនទាន់ចេះដើរផង បើស្លាប់មែនសូមស្លាប់នៅស្រុកកំណើតខ្លួនឯងវិញចុះ»**ៗ ខ្ញុំរស់នៅក្នុងស្រុកចម្ការលើបានប្រហែលប្រាំទៅប្រាំមួយថ្ងៃ កងទ័ពវៀតណាមក៏បានចូលទៅដល់ នៅខណៈនោះ ខ្ញុំ និងអ្នកភូមិកោះថ្មបានធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញៗ នៅតាមផ្លូវ ខ្ញុំបានជួបឪពុករបស់ខ្ញុំ ហើយក៏ធ្វើដំណើរមកផ្ទះជាមួយគ្នាៗ នៅពេលត្រឡប់មកដល់ភូមិកោះថ្មដំបូងក្នុងភូមិគ្មានមនុស្សទេ ខ្ញុំនិងក្រុមគ្រួសារបានមករស់នៅលើផ្ទះរបស់យើងវិញ និងប្រកបរបរធ្វើស្រែចម្ការដូចដែលយើងធ្លាប់ធ្វើកន្លងមកៗ

# ឃី ធា អតីតពេទ្យខ្មែរក្រហម

ហ៊ាន ពិសី



ឃី ធា និង ហ៊ាន ពិសី អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។

ឃី ធា ភេទស្រី អាយុ៦៦ឆ្នាំ មានទីកន្លែងកំណើតនៅភូមិស្វាយជុំក្រោម ឃុំបុស្សរីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។ សព្វថ្ងៃ ឃី ធា រស់នៅឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ បានរំឭករឿងរ៉ាវអតីតកាលរបស់គាត់ដូចខាងក្រោម៖

នៅក្នុងជំនាន់ លន់ នល់ ខ្ញុំគឺជាកូនកសិករ ដែលមានជីវភាពខ្វះខាត។ ខ្ញុំបានសម្រេចចិត្តឈប់រៀន ខណៈពេលដែល លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្ដេច នរោត្តម សីហនុ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ខ្ញុំចាំបានថា កាលណោះ ឪពុករបស់ខ្ញុំបានចូលរួមក្នុងចលនាបះបោរប្រឆាំងនឹងរដ្ឋប្រហារ ហើយក៏កើតមានព្រឹត្តិការណ៍ទម្លាក់គ្រាប់បែកឥតឈប់ឈរចាប់តាំងពីពេលនោះមក។ ភូមិរបស់ខ្ញុំដែលស្ថិតនៅតាមបណ្ដោយមាត់ទន្លេ ក៏ទទួលរងការទម្លាក់គ្រាប់បែកដែរ។ សំណាងល្អប្រជាជននៅក្នុងភូមិភាគច្រើនបានរស់រានមានជីវិតពីព្រឹត្តិការណ៍ដ៏គួរឲ្យរន្ធត់នោះ។ ទោះបីជាយ៉ាងណាក៏ដោយ សង្គ្រាមនៅតែបន្តរវាងកងទ័ព លន់ នល់ និងយោធាខ្មែរក្រហម។ ខ្ញុំបានឃើញខ្មែរក្រហមជីករណ្ដៅដែលមានប្រវែងវែងៗ នៅ

ក្រោយផ្ទះប្រជាជន និងនៅតាមវាលស្រែសម្រាប់កប់សាកសពអ្នកស្លាប់ៗ។

រហូតដល់ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានខ្មែរក្រហមបង្ខំឲ្យចូលធ្វើការនៅកងចល័ត។ ខ្ញុំមិនត្រូវបានប្រធានកងបញ្ជូនឲ្យទៅរែកដី និងជីកប្រឡាយទេ គឺខ្ញុំត្រូវធ្វើការនៅផ្នែករោងបាយ។ ខ្ញុំនិងប្រជាជនផ្សេងទៀតបានរស់នៅក្នុងស្ថានភាពយ៉ាងលំបាកនៅក្នុងសហករណ៍ ដោយសារការហូបចុកមិនគ្រប់គ្រាន់។ ក្រោយមក ខ្មែរក្រហមបានបញ្ជូនខ្ញុំទៅខេត្តមណ្ឌលគិរី ដើម្បីរៀនពេទ្យយោធានៅទីនោះ។ ខ្ញុំបានរៀនខាងផ្នែកវេជ្ជសាស្ត្រ ដោយផ្តើមចេញពីការចេះអានអក្សរបន្តិចបន្តួច និងព្យាយាមស្វែងយល់ប្រភេទថ្នាំនីមួយៗ ដែលមានបិទអក្សរនៅលើនោះ។ មិនយូរប៉ុន្មាន ខ្មែរក្រហមបានផ្លាស់ខ្ញុំឲ្យទៅធ្វើជាពេទ្យឆ្មប និងជាប្រធានផ្នែកពេទ្យទៀតផង។

នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវបានខ្មែរក្រហមបង្ខំឲ្យរៀបការ។ ពេលនោះមានប្រជាជនរហូតទៅដល់១២០គូ។ ការរៀបការដោយបង្ខំបែបនេះ បានធ្វើឲ្យប៉ះពាល់ដល់ផ្លូវចិត្តរបស់ប្រជាជនស្ទើរគ្រប់រូប ដែលអ្នកខ្លះបានធ្វើអត្តឃាតព្រោះខ្លួនមិនពេញចិត្ត។ ចំណែកខ្ញុំក៏មិនពេញចិត្តការរៀបការរបស់ខ្ញុំដែរ ប៉ុន្តែខ្ញុំគ្មានជម្រើស។

នៅក្នុងឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀតណាមបានវាយចូលមកប្រទេសកម្ពុជា ខ្មែរក្រហមបានបញ្ជូនប្តីរបស់ខ្ញុំទៅសមរភូមិមុខដើម្បីប្រយុទ្ធ។ ប្តីរបស់ខ្ញុំបានស្លាប់បាត់បង់ជីវិត នៅអំឡុងពេលសង្គ្រាមនោះ។ ខ្ញុំនិងប្រជាជនជាច្រើននាក់ផ្សេងទៀតបានរត់ចូលព្រៃជាមួយខ្មែរក្រហម។ ជីវិតរបស់យើងមានការលំបាកខ្លាំងណាស់ ដោយសារយើងពុំមានបាយហូប។ ជារឿយៗ យើងតែងតែដើរជីកក្តួច និងដំឡូងព្រៃសម្រាប់បរិភោគជាក្រុម។ យើងបានធ្វើដំណើរប្រមាណជិតកន្លះខែឆ្ពោះទៅកាន់ទន្លេរពៅ ដោយឆ្លងកាត់ឧបសគ្គជាច្រើននៅតាមផ្លូវធ្វើដំណើរ។ ប្រជាជនជាច្រើនបានស្លាប់បាត់បង់ជីវិត ដោសារលង់ទឹក និងមានជំងឺគ្មានថ្នាំព្យាបាលជំងឺ។

នៅទន្លេរពៅ យើងបានរស់នៅលើទីទួលសុវត្ថិភាព និងរួចផុតពីការបាញ់ប្រហារ។ យើងត្រូវបានខ្មែរក្រហមជ្រើសតាំងឲ្យចូលធ្វើការក្នុងកងដឹកជញ្ជូន។ យើងបានដឹកជញ្ជូនគ្រាប់ និងគ្រឿងសព្វាវុធទៅកាន់សមរភូមិខាងក្នុងប្រទេសប្រមាណពីបួនទៅប្រាំដងក្នុងមួយខែ។ យើងបានធ្វើដំណើរចុះភ្នំឡើងភ្នំ និងប្រើពេលវេលាជាច្រើនថ្ងៃទម្រាំទៅដល់គោលដៅ។ ទោះបីជាការដឹកជញ្ជូនមានការនឿយហត់ ប៉ុន្តែការហូបចុករបស់យើងហាក់មានភាពប្រសើរឡើងវិញ។ ជារៀងរាល់ដប់ថ្ងៃម្តង ឬមួយខែម្តង យើងទទួលបាន អង្ករ ត្រីខកំប៉ុង និងសម្ភារប្រើប្រាស់ផ្សេងៗដើម្បីសម្រួលដល់ការរស់នៅប្រចាំថ្ងៃ។

នៅឆ្នាំ១៩៨០ ខ្ញុំបានរៀបការជាថ្មីម្តងទៀតនៅតំបន់១០០១។ ខ្ញុំបានបន្តរស់នៅតំបន់ ១០០១ រហូតដល់ដើមទសវត្សរ៍ឆ្នាំ១៩៩០ ទើបខ្ញុំនិងប្រជាជនបានធ្វើដំណើរមកតំបន់អន្លង់វែង។ ខ្ញុំបានរស់នៅភូមិអូរថ្ម ដែលបច្ចុប្បន្នប្តូរឈ្មោះទៅភូមិឯកភាព នៃតំបន់អន្លង់វែង។ ដំបូងខ្ញុំមានការភ័យខ្លាចយ៉ាងខ្លាំង ដោយសារនៅទីនេះគឺជាតំបន់ព្រៃក្រាស់។ ខ្ញុំនិងគ្រួសារ ចាប់ផ្តើមកាប់ឆ្ការព្រៃដើម្បីយកដីសាងសង់ផ្ទះ។ ខ្ញុំនិងគ្រួសារបានទទួលការជួយទំនុកបម្រុងពី តាម៉ុក ដូចជាអង្ករ ត្រីខ និងគ្រឿងសម្ភារប្រើប្រាស់ផ្សេងៗទៀត និងបានខិតខំកាប់ឆ្ការព្រៃដាំដំណាំបន្ថែមទៀត។

ខ្ញុំនៅចាំបានថា ក្រោយពីប្រមូលផលស្រូវរួចមិនបានយូរប៉ុន្មាន យើងត្រូវរត់ភៀសខ្លួនម្តងទៀតទៅកាន់ជំរំភូណយ ក្នុងទឹកដីថៃ ដោយសារកងទ័ពខាងរដ្ឋាភិបាលវាយចូលមកតំបន់អន្លង់វែង។ ជីវិតទៅដល់ទីនោះមានភាពល្អប្រសើរ ដោយសារកាកបាទក្រហមអន្តរជាតិជួយផ្តល់ស្បៀងអាហារ សម្លៀកបំពាក់ និងសម្ភារជាច្រើនមុខទៀត។ រយៈពេលពីរឆ្នាំនៅទីនោះ ខ្ញុំនិងគ្រួសារបានបង្កើតមុខរបរមួយ ដោយខ្ញុំនិងប្តីបានដើរប្រមូលទិញទូរទស្សន៍ចាស់ៗ ពីប្រជាជនថៃយកមកជួសជុល ហើយលក់ឲ្យប្រជាជនដែលរស់នៅក្នុងជំរំជាមួយគ្នា។ ខ្ញុំនិងគ្រួសារ អាចដោះស្រាយជីវភាពបានមួយកម្រិត។

នៅក្នុងឆ្នាំ១៩៩៨ គឺជាឆ្នាំដែលយោធាខ្មែរក្រហមនៅតំបន់អន្លង់វែងបានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំនិងគ្រួសារត្រូវបានបញ្ជូនពីជំរំ

*ភូណយ មកកាន់តំបន់អន្លង់វែង តាមរថយន្តខ្មែរក្រហម។ ប្រជាជនមួយចំនួនទៀត ត្រូវធ្វើដំណើរដោយថ្មើរជើងមកអន្លង់វែងតាមក្រុមនីមួយៗ។ ចាប់ពីពេលនោះ យើងបានចាប់ផ្ដើមប្រកបរបរ និងរស់នៅជាឯកជន ធ្វើស្រែធ្វើចម្ការដោយខ្លួនឯង ព្រោះយើងលែងមានរបបអាហារដូចពីមុនទៀតហើយ។ មិនតែប៉ុណ្ណោះ ក្រោយពេលប្រទេសទទួលបាននូវសុខសន្តិភាព ប្ដីរបស់ខ្ញុំដែលធ្លាប់បម្រើការជាយោធា ត្រូវបានរដ្ឋាភិបាលកាត់រំសាយ និងផ្ដល់ថវិកាមួយចំនួនសម្រាប់ផ្គត់ផ្គង់ជីវភាពក្រុមគ្រួសារថែមទៀត។ ក្រោយមក ប្ដីរបស់ខ្ញុំបានចូលធ្វើជាគ្រូបង្រៀននៅសាលាស្ថិតក្នុងភូមិឯកភាព។*

*បច្ចុប្បន្នខ្ញុំសង្កេតឃើញថាប្រជាជននៅក្នុងភូមិ ក៏ដូចជាសហគមន៍នៅអន្លង់វែង មានការរីកចម្រើនដែលខុសពីពេលមុន ដូចជា មាន ផ្លូវថ្នល់ សាលារៀន និងមន្ទីរពេទ្យ។ ជាពិសេសប្រជាជនអាចប្រកបមុខរបរផ្សេងៗ និងមានសិទ្ធិសេរីភាពគ្រប់គ្រាន់ក្នុងការរស់នៅ។*



*យី ធា នៅផ្ទះរបស់គាត់ស្ថិតនៅឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។*



*ផ្ទះរបស់ យី ធា ស្ថិតនៅឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

# ខ្ញុំនៅសង្ឃឹមថានឹងបានជួបបងប្រុសរបស់ខ្ញុំ

## អ៊ុន សុជាទី



*ស៊ុំ ភាគ និង ស៊ុំ ឡូន សព្វថ្ងៃរស់នៅឃុំសានគរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ (ស៊ុំ ភាគ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

បងប្រុសរបស់ខ្ញុំឈ្មោះ ស៊ុំ ផុន កើតនៅឆ្នាំ១៩៥៣ ក្នុងឃុំព្រះដំរី ស្រុកស្ទោង ខេត្តកំពង់ធំ។ បងផុន មានសប្បុរស្រអែម ហើយគាត់តែងតែសិតសក់វែកភ្លឺមកខាងស្តាំជានិច្ច។ គាត់និយាយស្តីញាប់ៗ និងជួនពេលខ្លះគាត់និយាយជាប់គ្នាត្រដិតៗ។ កាលពីនៅកុមារ បងផុនបានកាប់គ្រាប់ត្នោត ហើយបានកាប់ត្រូវចុងម្រាមដៃចង្អុរខាងស្តាំបណ្តាលឲ្យពិការតាំងពីពេលនោះមក។ បងផុន ឈប់រៀនត្រឹមថ្នាក់ទី៤នៅក្នុងសម័យសង្គមរាស្ត្រនិយម។

នៅក្នុងឆ្នាំ១៩៦៨ ក្រុមគ្រួសាររបស់ខ្ញុំ ដែលមានឪពុកឈ្មោះ ស៊ុំ ដៃ, ម្តាយឈ្មោះ សុខ លួន, បងប្រុសឈ្មោះ ស៊ុំ ផុន, ប្អូនប្រុសឈ្មោះ ស៊ុំ ភាគ និងខ្ញុំឈ្មោះ ស៊ុំ ឡូន បានសម្រេចចិត្តចាកចេញពីស្រុកកំណើតនៅក្នុងឃុំសានគរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ទៅរស់នៅឯស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ។ ខេត្តព្រះវិហារ ស្ថិតនៅភូមិភាគឧត្តរ ដែលជាតំបន់ខ្ពង់រាបតំបន់ព្រៃភ្នំ និងទីតាំងភូមិសាស្ត្រមានភាពទូលំទូលាយ ហើយសម្បូរទៅដោយព្រៃឈើ សត្វព្រៃ ធនធានធម្មជាតិ និងសំណង់ប្រវត្តិសាស្ត្របុរាណ។ ស្ថានភាពដីនៅក្នុងខេត្តព្រះវិហារមានលក្ខណៈអំណោយផលយ៉ាងខ្លាំងដល់ការដាំដុះ, ការធ្វើស្រែចម្ការ ថែមទាំងមានសេសសល់ដីធំទូលាយជាច្រើនកន្លែងទៀតផង។ នៅពេលនោះ ប្រជាជនមិនសូវទៅរស់នៅច្រើនកុះករនោះទេ។ ក្រុមគ្រួសាររបស់ខ្ញុំបានសម្រេចចិត្តចាកចេញពីស្រុកកំណើតផ្លាស់ទៅរស់នៅឯខេត្តព្រះវិហារ ដោយសង្ឃឹមថា យើងនឹងអាចស្វែងរកដីធំទូលាយសម្រាប់ធ្វើស្រែចម្ការ សម្រាប់ជួយផ្គត់ផ្គង់ដល់ជីវភាពគ្រួសាររបស់យើងបន្ថែមទៀត។

រហូតមកដល់ឆ្នាំ១៩៧៣ បងផុន បានរៀបការជាមួយនឹងនារីម្នាក់ឈ្មោះ ហុង ឡាយ ដែលជាអ្នករស់នៅក្នុងខេត្តព្រះវិហារ។ បងផុន រៀបការមិនទាន់បានមួយឆ្នាំផង ប្រពន្ធរបស់គាត់បានស្លាប់ចោល ដោយសារជំងឺគ្រុនចាញ់។ បន្ទាប់ពីប្រពន្ធស្លាប់ បងផុន បានសម្រេចចិត្តចូលបម្រើបដិវត្តន៍។ បងផុន ធ្វើជាយោធាខ្មែរក្រហម ហើយបានចាកចេញពីផ្ទះតាំងពីពេលនោះ និងមិនដែលត្រឡប់មកជួបក្រុមគ្រួសារវិញឡើយ។ នៅអំឡុងពេលនោះ ខេត្តព្រះវិហារ គឺជាតំបន់ស្វយ័តដែលត្រូវបានខ្មែរក្រហមគ្រប់គ្រង។ ខ្ញុំនិងក្រុមគ្រួសារបានរស់នៅក្នុងស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ។

មកដល់ដំបូង ខ្មែរក្រហមបានរៀបចំបែងចែកប្រជាជនណាដែលមានជីវភាពក្រលំបាក និងមានស្រុកកំណើតនៅក្នុងខេត្តព្រះវិហារ ធ្វើជាប្រធាន ចំណែកឯប្រជាជនណាដែលមានជីវភាពមធ្យមនិងខ្ពស់ឲ្យធ្វើជាប្រជាជនធម្មតាៗ ក្រោយមក ខ្មែរក្រហមបានរៀបចំឲ្យប្រជាជនរស់នៅជាសហករណ៍។ ក្រុមគ្រួសាររបស់ខ្ញុំត្រូវខ្មែរក្រហមចាត់ទុកនៅក្នុងវណ្ណៈកណ្តាល។ យើងត្រូវទៅរស់នៅនិងធ្វើការងាររួមជាមួយប្រជាជនដទៃទៀត។ ការងារប្រចាំថ្ងៃរបស់ប្រជាជននៅក្នុងភូមិ គឺធ្វើស្រែចម្ការ លើកទំនប់ ជីកប្រឡាយ និងរៀបចំប្រព័ន្ធធារាសាស្ត្រជាច្រើនដើម្បីស្រោចស្រពដំណាំស្រូវ និងដំណាំផ្សេងៗទៀត។ ប្រជាជនដែលខ្មែរក្រហមបានចាត់ចូលក្នុងវណ្ណៈអ្នកមាន និងវណ្ណៈកណ្តាល ត្រូវទទួលរងការធ្វើបាបយ៉ាងខ្លាំង។ ក្រុមគ្រួសាររបស់ខ្ញុំត្រូវបានខ្មែរក្រហម ធ្វើបាបដូចជាប្រជាជនដទៃទៀតដែរ។ រៀងរាល់ថ្ងៃ យើងធ្វើការងារក្នុងវាលស្រែ និងតាមចម្ការ ហើយយើងក៏មិនធ្លាប់ទទួលបានអាហារហូបចុកគ្រប់គ្រាន់ដែរ។

នៅក្នុងឆ្នាំ១៩៧៤ ឪពុករបស់ខ្ញុំបានស្លាប់ដោយសារតែគាត់មិនអាចទ្រាំទ្រទៅនឹងភាពអត់ឃ្លាន ការធ្វើការងារធ្ងន់ធ្ងរ និងជំងឺប្រចាំកាយរបស់គាត់បាន។ ឪពុករបស់ខ្ញុំបានធ្លាក់ខ្លួនឈឺ ប៉ុន្តែគាត់មិនដែលទទួលបានថ្នាំសង្កូវដើម្បីយកមកព្យាបាលជំងឺរបស់គាត់ទេ។ ឪពុករបស់ខ្ញុំមិនបានទទួលអាហារហូបចុកគ្រប់គ្រាន់ឡើយ។ នៅពេលដែលឪពុករបស់ខ្ញុំធ្លាក់ខ្លួនឈឺ ហើយធ្វើការងារអ្វីលែងកើត អង្គការបានបើកអង្ករឲ្យទៅគាត់ចំនួន ១កំប៉ុងសម្រាប់ហូបក្នុងរយៈពេល៣ថ្ងៃ។ បន្ទាប់ពីឪពុករបស់ខ្ញុំស្លាប់ទៅ ម្តាយរបស់ខ្ញុំបានខិតខំប្រឹងប្រែងធ្វើការងារយ៉ាងខ្លាំង ដើម្បីរក្សាជីវិតរស់នៅមើលថែរក្សាកូនៗ។

រហូតមកដល់ចុងឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានវាយប្រយុទ្ធជាមួយនឹងយោធាខ្មែរក្រហមនៅក្នុងខេត្តព្រះវិហារ។ ខ្ញុំឮសូរសំឡេងគ្រាប់កាំភ្លើងផ្ទុះស្ទើរតែរៀងរាល់ថ្ងៃ។ មិនយូរប៉ុន្មាន យោធាខ្មែរក្រហម និងបក្ខពួករបស់ខ្លួន បាននាំគ្នារត់ខ្ចាត់ខ្ចាយអស់គ្មានសល់។ យោធាខ្មែរក្រហមខ្លះរត់ឡើងលើភ្នំ រីឯខ្លះទៀតរត់គេចខ្លួនសំដៅទៅព្រំដែនខ្មែរនិងថៃ។ ក្រុមខ្មែរក្រហម មិនហ៊ានលាក់ខ្លួននៅក្នុងភូមិឡើយ ព្រោះខ្លាចកងទ័ពវៀតណាមចាប់ខ្លួន។ បន្ទាប់ពីក្រុមខ្មែរក្រហមរត់ចេញអស់ពីភូមិ ប្រជាជនសម្តែងទឹកចិត្តត្រេកអរពន់ពេក ហើយបាននាំគ្នាដើរស្វែងរកសាច់ញាតិ និងត្រឡប់មករស់ជួបជុំគ្នាវិញ។ ប្រជាជនបាននាំគ្នាចាប់ផ្តើមជីវិតឡើងវិញដោយសហការគ្នាសាងសង់លំនៅដ្ឋាន និងធ្វើស្រែចម្ការប្រវាស់ដៃគ្នា។

អំឡុងឆ្នាំ ១៩៧៩ មិត្តភក្តិរបស់ បងផុន ឈ្មោះ ទី និង ង៉ែត បានវិលត្រឡប់មកពីទីក្រុងភ្នំពេញ ដើម្បីមកសួរសុខទុក្ខក្រុមគ្រួសារនៅឯខេត្តព្រះវិហារ។ មិត្តភក្តិរបស់បងផុន បានប្រាប់ខ្ញុំថា បងផុន នៅមានជីវិតនៅឡើយ ហើយគាត់ក៏ចង់មកលេងក្រុមគ្រួសារដែរ ប៉ុន្តែអង្គការមិនទាន់អនុញ្ញាតឲ្យមក។ ទី និង ង៉ែត បានរៀបរាប់បន្ថែមទៀតថា បងផុន បានមកធ្វើការនៅក្នុងទីក្រុងភ្នំពេញអំឡុងឆ្នាំ១៩៧៧។ គាត់ធ្វើជាយោធាខ្មែរក្រហម ព្រមទាំងបានប្តូរឈ្មោះពី ស៊ុំ ផុនមក សុក ឈានវិញ។ ដំណឹងរបស់ បងផុន ពីមិត្តភក្តិរបស់គាត់ បានធ្វើឲ្យខ្ញុំចេះតែសង្ឃឹមក្នុងចិត្ត និងទន្ទឹងចាំមើលផ្លូវគាត់ត្រឡប់មកផ្ទះវិញ។

នៅអំឡុងឆ្នាំ ១៩៨១ អ្នកជំនួយម្នាក់មកពីខេត្តកំពង់ធំ បានប្រាប់ក្រុមគ្រួសាររបស់ខ្ញុំថា នៅក្នុងខេត្តកំពង់ធំកំពុងតែមានការបែងចែកដីធ្លី និងអាចប្រកបមុខរបរបានស្រួលទៅថ្ងៃមុខៗ ដោយខ្ញុំអស់សង្ឃឹម ហើយលែងមានអ្នកដែលអាចពឹងពាក់បាន ព្រោះឪពុកបានស្លាប់ចោល ហើយបងប្រុសក៏បាត់ដំណឹងសូន្យឈឹងទៀតនោះ ខ្ញុំនិងក្រុមគ្រួសារ បានសម្រេចចិត្តវិលត្រឡប់មកស្រុកកំណើតនៅឯខេត្តកំពង់ធំវិញរហូតដល់សព្វថ្ងៃនេះ។

នៅក្នុងឆ្នាំ១៩៨៣ ខ្ញុំបានរៀបការជាមួយប្តីរបស់ខ្ញុំឈ្មោះ សួន សឿន។ យើងមានកូនស្រីម្នាក់។ ក្រោយមកប្តីរបស់ខ្ញុំបានចាកចេញពីខ្ញុំ ទៅបម្រើឲ្យកងទ័ពរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយមិនដែលឃើញវិលត្រឡប់មកវិញឡើយ។

នៅអំឡុងឆ្នាំ១៩៩៦ ខ្ញុំបានស្តាប់វិទ្យុដោយចៃដន្យ ស្រាប់តែបានឮសំឡេងបុរសម្នាក់ដែលបានផ្តល់បទសម្ភាសន៍ដល់អ្នកការសែតនៅក្នុងវិទ្យុ ហាក់បីដូចជាសំឡេងរបស់ បងផុន។ បន្ទាប់ពីស្តាប់ការសម្ភាសន៍នោះ

បានមួយសន្ទុះ ខ្ញុំប្រាកដក្នុងចិត្តថាសំឡេងរបស់បុរសម្នាក់នោះ គឺដូចបេះបិទទៅនឹងសំឡេងរបស់ បងផុន ពិតប្រាកដមែនៗ គាត់បានប្រាប់ទៅកាន់អ្នកកាសែតថា គាត់ឈ្មោះ ស៊ុំ ផុន មានអាយុ៤៤ឆ្នាំៗ ប៉ុន្តែនៅពេលសម្ភាសន៍នោះ បុរសម្នាក់នោះ មិនបាននិយាយប្រាប់អំពីទីកន្លែងកំណើតរបស់គាត់ថានៅទីណានោះទេៗ ឈ្មោះរបស់បុរសម្នាក់នោះដូចគ្នាទៅនឹងឈ្មោះរបស់បងប្រុស ខ្ញុំ ចំណែកឯអាយុរបស់គាត់ស្រដៀងគ្នាទៅនឹងអាយុរបស់បងប្រុសខ្ញុំដែរៗ ខ្ញុំមានជំនឿក្នុងចិត្តថា បុរសនោះ គឺជាបងប្រុសរបស់ខ្ញុំៗ ក្រោយមកទៀត ខ្ញុំមិនដែលធ្លាប់បានទទួលដំណឹងអ្វីឡើយពីបងផុនរហូតដល់បច្ចុប្បន្ននេះៗ

សព្វថ្ងៃ ខ្ញុំរស់នោះជាមួយម្តាយ ប្អូនប្រុស និងចៅៗៗ កូនស្រីរបស់ខ្ញុំបានស្លាប់ដោយសារជំងឺមហារីកដោះអស់រយៈពេល២ឆ្នាំកន្លងមកហើយៗ បន្ទាប់ពីកូនស្រីរបស់ខ្ញុំស្លាប់ កូនប្រសាររបស់ខ្ញុំ បានវិលត្រឡប់ទៅស្រុកកំណើតវិញ ដោយបានបន្សល់ទុកចៅចំនួន ៥នាក់ឲ្យរស់នៅជាមួយខ្ញុំៗ ចៅទី១របស់ខ្ញុំ បានមកស៊ីឈ្នួលបម្រើនៅតាមផ្ទះនៅឯទីក្រុងភ្នំពេញ, ចៅទី២ បានបួសជាព្រះសង្ឃ ចំណែកឯចៅតូចៗ ចំនួន ៣នាក់ទៀត កំពុងរស់នៅជាមួយខ្ញុំសព្វថ្ងៃនេះៗ

ទោះបីជាជីវិតខ្ញុំស្ថិតក្នុងស្ថានភាពលំបាកយ៉ាងណា ខ្ញុំនៅតែចង់បន្តស្វែងរកបងប្រុសរបស់ខ្ញុំៗ គាត់គឺជាបងប្រុសដ៏ល្អម្នាក់សម្រាប់ខ្ញុំៗ ខ្ញុំចង់ដឹងសុខទុក្ខរបស់គាត់ និងចង់ជួបជុំក្រុមគ្រួសារវិញប៉ុណ្ណោះៗ

សព្វថ្ងៃនេះ ខ្ញុំមានអាយុ ៦៣ឆ្នាំ ហើយៗ ខ្ញុំមានជំងឺលើសឈាមនិងឈឺសន្លាក់ដៃជើងៗ ខ្ញុំជារឿយៗទៅទិញថ្នាំពីមណ្ឌលសុខភាពមកផឹកដើម្បីព្យាបាលជំងឺៗ ទោះបីជាខ្ញុំឈឺ ប៉ុន្តែវាមិនបានធ្វើឲ្យខ្ញុំឈប់សម្រាកពីការងារឡើយៗ ខ្ញុំមានតួនាទីទទួលខុសត្រូវមើលថែរក្សាម្តាយដែលពិការដោយសារជំងឺស្រ្តូក និងចៅតូចៗដែលមិនទាន់ដឹងក្តីនៅឡើយៗ

ខ្ញុំសង្ឃឹមថា ខ្ញុំនឹងអាចជួបបងប្រុសរបស់ខ្ញុំវិញៗ ដំណឹងរបស់បងប្រុស ខ្ញុំគឺពិតជាមានអត្ថន័យណាស់សម្រាប់ខ្ញុំនិងក្រុមគ្រួសារៗ ប្រសិនបើអ្នកស្គាល់ភិនភាគដូចដែលខ្ញុំរៀបរាប់ខាងលើនេះ សូមមេត្តាទាក់ទងមកខ្ញុំផ្ទាល់ឈ្មោះ ស៊ុំ ឡុន តាមរយៈទូរស័ព្ទលេខ ០៩៧ ៨៩៥៥ ៦៥៣ ឬទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈអ៊ីម៉ែល: truthsodavy.u@dccam.org ឬទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ៗ



មេដឹកនាំ និងកងយោធាខ្មែរក្រហម នៅស្តាតអូឡាំពិកៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប៊ិន ម៉ាច៖ អន្លង់វែងគឺជាលំនៅដ្ឋានចុងក្រោយ បន្ទាប់ពីសង្រ្គាមបានបញ្ចប់

*មេក វិន*



ប៊ិន ម៉ាច នៅផ្ទះរបស់គាត់ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (មេក វិន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប៊ិន ម៉ាច អាយុ៦១ឆ្នាំ មានទីកន្លែងកំណើតនៅភូមិព្រែកតាអាំ ឃុំបុសលាវ ស្រុកចិត្របុរី ខេត្តក្រចេះ បានរៀបរាប់ពីរឿងរ៉ាវជីវិតរបស់ខ្លួន និងការធ្វើដំណើរដ៏វែងឆ្ងាយមកកាន់តំបន់អន្លង់វែងថា នៅឆ្នាំ១៩៧៦ ខ្ញុំបានបែកចេញពីឪពុកម្តាយ ហើយបានសម្រេចចិត្តចូលបម្រើការងារជាកងចល័តរបស់ខ្មែរក្រហមនៅក្នុងស្រុកក្រចេះ។ នៅទីនោះ ខ្មែរក្រហមបានប្រើឲ្យខ្ញុំដេញចាបនៅក្នុងវាលស្រែរហូតដល់ឆ្នាំ១៩៧៩។ ខ្ញុំតែងតែក្រោកពីព្រលឹមដើម្បីទៅដេញចាបរហូតដល់ម៉ោង១១ព្រឹក ទើបខ្ញុំទទួលអាហារថ្ងៃត្រង់។ ការហូបចុករបស់ខ្ញុំមិនសូវពិបាកទេពី ព្រោះប្រធានសហករណ៍គឺជាបងប្អូនរបស់ខ្ញុំ។ ខ្ញុំចាំបានថា ថ្ងៃមួយសហករណ៍អនុញ្ញាតឲ្យខ្ញុំហូបបាយលាយជាមួយល្ពៅ ប៉ុន្តែមិត្តនៅក្នុងក្រុមគ្មាននណាម្នាក់ហ៊ានប្រកែកតវ៉ាឡើយ។ បន្ទាប់ពីហូបបាយរួច ខ្ញុំត្រូវស្ទៀកពាក់ទៅរៀន ដោយត្រូវប្តូរវេនជាមួយមិត្តរួមក្រុមដើម្បីចាំដេញចាប។

លុះដល់ឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានវាយប្រហារចូលមកក្នុងស្រុកស្នួល ខេត្តក្រចេះ នៅពេលនោះខ្ញុំក៏បានធ្វើដំណើរចាកចេញពីភូមិកំណើតជាមួយប្រជាជនជាច្រើននាក់ផ្សេងទៀត ឆ្ពោះទៅភាគខាងលិចដោយត្រូវឆ្លងកាត់ទន្លេ។ បន្ទាប់មកខ្ញុំបានធ្វើដំណើរបន្តទៅកាន់ព្រៃមួយក្នុងខេត្តកំពង់ធំ។ យើងបានធ្វើដំណើរអស់រយៈពេល ១ឆ្នាំ ដោយឆ្លងកាត់ភ្នំជាច្រើនទម្រាំទៅដល់ទីនោះ។ យើងបានបន្តរស់នៅក្នុងព្រៃដោយគ្មានអាហារហូបចុកគ្រប់គ្រាន់។ ជារៀងរាល់ថ្ងៃ យើងតែងតែដើរជីកដំឡូងព្រៃដើម្បីបរិភោគ។ ពេលខ្លះក្រុមរបស់ខ្ញុំបាននាំគ្នាចាំស្ទាក់អ្នកភូមិដែលធ្វើដំណើរតាមផ្លូវដើម្បីសុំស្រូវអង្ករទុកបរិភោគនៅក្នុងក្រុម។ អ្នកភូមិបានរកអង្ករមកឲ្យក្រុមរបស់ខ្ញុំ ហើយក្រុមរបស់ខ្ញុំបានឲ្យមាសទៅគាត់វិញ។ ខ្ញុំនៅចាំបានថា ខ្ញុំមានមាសប្រាំជីនៅជាប់ខ្លួន។ ខ្ញុំបានយកទៅដូរអង្ករមកហូបទាំងអស់គ្នាដើម្បីឲ្យរួចពីការដាច់ពោះស្លាប់។ នៅពេលដែលកងទ័ពវៀតណាមវាយប្រហារម្តងៗ ខ្ញុំតែងតែស្ពាយអង្ករ និងឆ្នាំងបាយតាមខ្លួន។ ជីវិតរស់នៅក្នុងព្រៃរបស់ខ្ញុំជួបការលំបាកវេទនាខ្លាំងណាស់ បើប្រៀបធៀបទៅនឹងជីវិតរស់នៅជាកងចល័តនៅក្នុងខេត្តក្រចេះ ។

នៅចុងឆ្នាំ១៩៧៩ តាម៉ុក បានចាត់កងកម្លាំងឲ្យមកទទួលប្រជាជនដែលរស់នៅក្នុងព្រៃស្ថិតនៅខេត្តកំពង់ធំទាំងអស់យកទៅនៅលើភ្នំដងរែក។ កងកម្លាំង តាម៉ុក

បានឃោសនាថា ពុក ម៉ែ បង ប្អូន និងប្រជាជនទាំងអស់ទៅរស់នៅលើភ្នំដងរែកទើបមានសុវត្ថិភាព និងបានរួចផុតពីការយាយីរបស់កងទ័ពវៀតណាម។ ខ្ញុំ និងប្រជាជនជាច្រើននាក់ផ្សេងទៀតក៏បានសម្រេចចិត្តធ្វើដំណើរតាមកងកម្លាំងរបស់ តាម៉ុក ដែលនាំផ្លូវ។ ការធ្វើដំណើររបស់ខ្ញុំបានចំណាយពេលអស់ជាច្រើនខែ ទើបទៅដល់តំបន់ភ្នំដងរែក។ នៅតាមផ្លូវក្រុមរបស់ខ្ញុំបានប្រឈមនឹងបញ្ហាជាច្រើនជាមួយកងទ័ពវៀតណាមដែលចាំវាយប្រហារមកលើកងកម្លាំងរបស់ តាម៉ុក និងប្រជាជនរួមដំណើរ។ អ្នករួមដំណើរទាំងអស់ក៏ត្រូវមានការប្រុងប្រយ័ត្នចំពោះមីនបង្កប់ ហើយពេលដំណើរត្រូវដើរជាជួរគឺ ស្រីៗត្រូវដើរកណ្តាល ចំណែកឯប្រុសៗត្រូវដើរនៅខាងមុខ និងខាងក្រោយ។ ដោយសារតែការធ្វើដំណើរចេញពីទឹកដីខេត្តកំពង់ធំ ឆ្ពោះទៅកាន់ភ្នំដងរែកត្រូវប្រើរយៈពេលយូរខែ និងមិនមានស្បៀងអាហារហូបចុកគ្រប់គ្រាន់ ដូច្នេះ កងកម្លាំងរបស់ តាម៉ុក ដែលប្រចាំការនៅលើភ្នំ បានយកអង្ករ មី ត្រីខកំប៉ុង ទឹកដោះគោ នំ អង្រឹង ខោអាវ មកចែកឲ្យយើងហូប និងស្លៀកពាក់។ ប៉ុន្តែ ក៏មានប្រជាជនខ្លះបានស្លាប់ដោយសារភាពហេវហត់ មុនពេលស្បៀងអាហារទាំងនោះមកដល់។ មានប្រជាជនខ្លះដោយសារស្រេកឃ្លានខ្លាំងពេក បានហែកមីហូបអស់ជាច្រើនកញ្ចប់ដោយមិនបានចម្អិន រហូតដល់ហើមពោះ ហើយមួយចំនួនបានដេកស្លាប់នៅក្នុងអង្រឹង។

ខ្ញុំរួមទាំងប្រជាជនមួយចំនួនទៀតដែលនៅសេសសល់ បានបន្តដំណើរដោយឆ្លងកាត់ភ្នំជាច្រើន និងបានចំណាយពេលជាច្រើនថ្ងៃទៀតទើបមកដល់ទន្លេល្ពៅ ប៉ុស្តិ៍ក ១០០១ ដែលស្ថិតក្នុងខេត្តព្រះវិហារ។ ខ្ញុំរស់នៅតំបន់ទន្លេល្ពៅ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ សុន សេន និង ខៀវ សំផន។ បន្ទាប់ពីបានធ្វើដំណើរមកដល់ភ្នំ១០០១ បានរយៈពេល៣ខែ ខ្ញុំបានចូលធ្វើការនៅកងនារីដឹកជញ្ជូន។ ការងាររបស់ខ្ញុំនៅទីនោះ គឺជញ្ជូនអង្ករក្នុងម្នាក់៣០គីឡូ និងជញ្ជូនគ្រាប់ ដេកា៨២, ៦០, ៨០ និងគ្រាប់១២០មីលីម៉ែត្រទៅឲ្យយោធាខ្មែរក្រហមនៅលេណដ្ឋាននៅខាងលើភ្នំ និងនៅខាងក្រោមភ្នំ។ ពេលនោះក្រុមរបស់ខ្ញុំបានទទួលសាច់ និង ត្រីងៀត យកមកហូប។ ក្នុងមួយឆ្នាំម្តង ខ្ញុំបានបើកសារុងមួយ អង្រឹងមួយ មុងមួយ និងក្រណាត់៤ម៉ែត្រ សម្រាប់កាត់ខោអាវពីអង្គភាពដឹកជញ្ជូន។

នៅក្នុងឆ្នាំ១៩៨១ ខ្ញុំបានរៀបជាមួយប្តីដែលធ្វើជាយោធាខ្មែរក្រហម ហើយមួយឆ្នាំក្រោយមកយើងមានកូនម្នាក់។ ខ្ញុំនិងគ្រួសារបានបន្តរស់នៅលើទឹកដីទន្លេល្ពៅ។ ក្រោយមកដោយសារមានការវាយប្រហារពីកងទ័ពវៀតណាមខ្លាំងនៅឆ្នាំ១៩៨៥ ខ្ញុំបានសម្រេចចិត្តចាកចេញពីទន្លេល្ពៅ មករស់នៅក្នុងភូមិដងទង់ ស្ថិតនៅក្នុងទឹកដីថៃវិញ។ នៅក្នុងឆ្នាំ១៩៨៧ ខ្ញុំបានផ្លាស់មកនៅជំរំអូត្រាវ ប៉ុ ប្រក១០០៣ ដោយពេលនោះប្រជាជនបានរស់នៅជាក្រុម ក្រោមការគ្រប់គ្រងរបស់ តាម៉ុក។ នៅក្នុងឆ្នាំ១៩៨៩ ប្រជាជននៅក្នុងជំរំអូរត្រាវ បានធ្វើមាតុភូមិនិវត្តន៍ចុះមករស់នៅខាងក្រោមភ្នំវិញ។ ខ្ញុំជាមួយមិត្តភក្តិខ្ញុំម្នាក់ទៀត ដែលមានកូនតូចៗនិងប្តីពិការជើង បានចុះមករស់នៅខាងក្រោមភ្នំដែរ។ ខ្ញុំបានបិទស្រា និងដាំបន្លែ ដើម្បីយកទៅលក់នៅផ្សារអន្លង់វែងដើម្បីផ្គត់ផ្គង់ជីវភាព។ ខ្ញុំបានធ្វើដំណើរឆ្លងកាត់បឹងអូរជីកដែលមានទឹកហូរគួចត្របាញ់ ដោយសារ តាម៉ុក មិនទាន់សង់ទំនប់នៅឡើយ។ នៅចន្លោះឆ្នាំ១៩៩១ ដល់ឆ្នាំ១៩៩២ ប្រជាជនចាប់ផ្តើមកាប់ឆ្ការព្រៃ ដើម្បីរានដីធ្វើស្រែចម្ការ និងដាំដំណាំហូបរៀងៗខ្លួន។

ប្រជាជនភាគច្រើនដែលបានភៀសខ្លួនមកនៅសហគមន៍អន្លង់វែងតែងតែបានផ្សារភ្ជាប់ជីវិតរស់នៅរបស់ខ្លួនទៅនឹងសហគមន៍នេះក្នុងសម័យសង្គ្រាម និងរហូតមកដល់បច្ចុប្បន្ន។



ចម្ការបន្លែរបស់ ប៉ិច ម៉ាច នៅខាងក្រោយផ្ទះ។
(មេក វិន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រវត្តិ និងបទឧក្រិដ្ឋរបស់ អោម អាន

សោម ប៊ុនថន



អោម អាន បានផ្តល់បទសម្ភាសន៍ដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា កាលពីថ្ងៃទី១ ខែសីហា ឆ្នាំ២០១១ នៅឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អោម អាន ឬ អោម យឿង គឺជាឈ្មោះដែលគាត់បានប្រាប់ទៅដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ពេលដែលចុះទៅសម្ភាសន៍គាត់នៅឆ្នាំ២០១១ ប៉ុន្តែឈ្មោះ ឌិម យឿង, អោ យឿង, តា អាន គឺជាឈ្មោះដែលប្រើនៅក្នុងឯកសារផ្លូវការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលគាត់ត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ឲ្យស្ថិតនៅក្រោមបទឧក្រិដ្ឋកម្មជាច្រើន នៅក្នុងសំណុំរឿង ០០៤/០២។ ខាងក្រោមគឺជាការរៀបរាប់របស់ អោម អាន៖

ខ្ញុំមានឈ្មោះពីកំណើត អោម យឿង ដែលបានប្រើតាំងពីអំ ឡុងពេលចូលបួសជាព្រះសង្ឃ។ នៅសម័យក្រោយមក មានការសម្តែងល្ខោននៅវត្តពោធិ៍។ ល្ខោននោះមានចំណងជើងថា គ្រូអា ន បេះផ្កាស្មោះ ថ្មី ស្របពេលដែលខ្ញុំបេះផ្កាស្មោះ ថ្មី និងបេះផ្កាដប្រាំថ្នាំពីបុសឈើឲ្យក្មេងបាត់យំដែរនោះ ទើបប្រជាជននៅក្នុងភូមិឃុំនាំគ្នាហៅឈ្មោះខ្ញុំតាមរឿងល្ខោនថា «គ្រូអា ន។» ជាប់រហូតមក។ ចាប់តាំងពីពេលនោះមក មិនមានអ្នកណាហៅឈ្មោះកំណើតខ្ញុំ យឿង ទៀតទេ ចំណែកត្រកូលរបស់

ខ្ញុំគឺយកតាមឈ្មោះជីតា គឺតាអោម ដូច្នេះ ខ្ញុំមានឈ្មោះ អោម អានៗ

ឪពុករបស់ខ្ញុំឈ្មោះ ឱ បានស្លាប់តាំងពីខ្ញុំនៅក្មេង ហើយម្តាយរបស់ខ្ញុំឈ្មោះ នុន បានស្លាប់នៅឆ្នាំ១៩៧៩។ ខ្ញុំមានបងប្អូនបង្កើតចំនួន៥នាក់ ស្លាប់អស់ពីរនាក់ គឺ បងប្រុសទី១) ឈ្មោះ អោម យ៉ុង និងប្អូនស្រីទី៣) ឈ្មោះ អោម ណានៗ នៅសល់តែខ្ញុំកូនទី២ ប្អូនស្រីទី៤ឈ្មោះ អោម នឿន និង ប្អូនប្រុសទី៥ឈ្មោះ អោម សុវិតៗ

នៅពេលខ្ញុំអាយុ១២ឆ្នាំ ជីតាខាងម្តាយរបស់ខ្ញុំ បានឲ្យខ្ញុំចូលបួសនៅវត្តតាំងខ្មៅ ស្ថិតនៅក្នុងឃុំពាម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំងៗ លោក តាវិញ គឺជាព្រះមេគណៈសង្ឃនៅវត្តតាំងខ្មៅ។ លោកតា វិញ បានបួសតាំងពីព្រះអង្គនៅវ័យក្មេងនិងមានព្រះជន្ម១២០ព្រះវស្សាៗ

ខ្ញុំបានស្នាក់នៅវត្តតាំងខ្មៅរយៈពេល២ឆ្នាំ ក៏បានចេញទៅរៀនបាលីនៅថ្នាក់ពុទ្ធិកបឋមសិក្សា នៅវត្តអង្គជុំ ក្នុងឃុំគោករការ ស្រុកដង្កោ ក្រុងភ្នំពេញៗ កាលនោះគ្រូ អ៊ូ គឺជាអ្នកបង្រៀនខ្ញុំៗ ក្រៅពីបង្រៀនសិស្សគ្រូ អ៊ូ បានធ្វើជាអាចារ្យៗ មិត្តភក្តិដែលរៀនជាមួយខ្ញុំ គឺមានឈ្មោះ សុក, សាន់, សម និង ម៉េតៗ មិត្តភក្តិទាំងនោះគឺជាកូនចៅរបស់ប្រជាជននៅក្នុងភូមិព្រៃខ្លា, ភូមិព្រៃមូល, ភូមិពុទ្រា និងភូមិបែកបក ដែលស្ថិតនៅក្បែរវត្ត ចំណែកខ្ញុំគឺជាអ្នកចម្ងាយៗ ខ្ញុំបានរៀនធម៌វិន័យរហូតដល់ខ្ញុំបំពេញបានជាភិក្ខុៗ

នៅឆ្នាំ១៩៦០ ខ្ញុំមានជំងឺក្រញង់ដៃជើង (ប៉ុជំងឺឃ្លង់) ដូច្នេះម្តាយរបស់ខ្ញុំក៏ឲ្យខ្ញុំទៅសុំព្រះចៅអធិការវត្តសឹកៗ ម្តាយរបស់ខ្ញុំបាននាំខ្ញុំទៅឲ្យគ្រូខ្មែរព្យាបាល ព្រោះនៅសម័យនោះមិនសូវមានពេទ្យៗ ម្តាយខ្ញុំបាននៅមើលថែទាំខ្ញុំរហូតដល់ឆ្នាំ១៩៦៣ ទើបខ្ញុំបានជាពីជំងឺ និងនៅជួយធ្វើស្រែឪពុកម្តាយវិញៗ

នៅរដូវវស្សា ឆ្នាំ១៩៦៩ ពេលខ្ញុំត្រឡប់មកពីស្ទូងនៅពេលល្ងាច និងបន្ទាប់ពីដឹកគោយកទៅចង ឈ្មោះ ប៉ក់ មានឋានន្តរស័ក្តិជាសែបនៃរដ្ឋការ លន់ នល់ បានបញ្ជាឲ្យខ្ញុំលើកដៃឡើងដើម្បីចងខ្ញុំ ដោយបានចោទប្រកាន់ខ្ញុំថាបានធ្វើសមាគមខ្មែរក្រហមៗ ខ្ញុំបានប្រកែកមិនឲ្យចង ហើយបានសួររកមេរបស់ ប៉ក់ ដែលបញ្ជាមកដើម្បីទៅជួប និងដោះស្រាយៗ ប៉ក់ បាននាំខ្ញុំទៅជួបឈ្មោះ លឹម ហេង នៅបន្ទាយត្រែងៗ ពេលទៅដល់មាត់ទ្វារចូល ទាហាន លន់ នល់ បានក្ដួងខ្ញុំៗ មួយរយៈក្រោយមកឈ្មោះ សម ដែលធ្លាប់បួសរៀនជាមួយខ្ញុំបានដើរចូលមក និងបានសួរមកកាន់ខ្ញុំថា តើដូចម្តេចបានអ្ហែងមកទីនេះ? ប៉ុន្តែខ្ញុំមិនបានឆ្លើយតបទៅវិញទេៗ សម បាននិយាយបន្តថា «អ្ហែងបានប្រព្រឹត្តល្មើសនឹងមេរបស់អញ!»ៗ ព្រដូច្នេះ ខ្ញុំបានតបទៅ សម វិញ ថា «មេរបស់អ្ហែងបានប្រព្រឹត្តល្មើសមកលើអញ» ព្រោះបានយកអញមកបង្អត់បាយទឹក ហើយខ្ញុំបានជេរ សមៗ ពេលព្រទៅដល់ លឹម ហេង ពាក់ស័ក្តិ៣ លឹម ហេងបាននិយាយប្រាប់ទៅ សម មិនឲ្យនិយាយជាមួយខ្ញុំទៀតៗ នៅវេលាម៉ោង៣រសៀល លឹម ហេង បានហៅខ្ញុំទៅសួរថា ប្អូនឯងបានចូលរួមជាមួយសមាគមខ្មែរក្រហមមែនទេ? អូនឯងនិយាយតាមត្រង់មក! ខ្ញុំបានឆ្លើយតបទៅវិញថា តេជគុណ! ខ្ញុំមិនបានធ្វើទេៗ លឹម ហេង បានបន្តសួរថា មានគេថាប្អូនច្បាស់ណាស់! ដូច្នេះតើប្រធានសមាគមខ្មែរក្រហមឈ្មោះអ្វី? ខ្ញុំបានបញ្ជាក់ទៅគាត់ថា ប្រធានសមាគមឈ្មោះ ម៉ែន សុះ បានស្លាប់ហើយៗ សមាគមនោះគឺទិញខ្ទើយ កន្ទេល ចាន ឆ្នាំង ស្លាបព្រា ចង្កៀងមុំាងសុង សម្រាប់ធ្វើបុណ្យប៉ុណ្ណោះៗ បន្ទាប់មក លឹម ហេង បានអនុញ្ញាតឲ្យខ្ញុំទៅផ្ទះវិញ ប៉ុន្តែខ្ញុំបានសុំឲ្យគាត់ធ្វើសំបុត្របញ្ជាក់ពីការដែលមិនជាប់ពាក់ព័ន្ធនឹងខ្មែរក្រហម ព្រោះខ្លាចទាហាន លន់ នល់ ចាប់ខ្ញុំម្តងទៀតៗ

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ពេលដែលព្រះអង្គយាងទៅព្យាបាលព្រះរោគនៅទីក្រុងប៉េកាំងៗ ព្រះអង្គបានធ្វើសេចក្តីប្រកាសពីទីក្រុងប៉េកាំងឲ្យកូនចៅចូលព្រៃម៉ាគីដើម្បីតស៊ូ ដើម្បីព្រះអង្គបានវិលត្រឡប់មកមាតុភូមិវិញៗ ខ្ញុំរួមទាំងប្រជាជនបានរួមគ្នាធ្វើបាតុកម្មដោយមានតា១៥ ឬ តាម៉ុក គឺជាអ្នកដឹកនាំៗ

ដំបូងខ្ញុំត្រូវរៀបចំឲ្យចូលខាងផ្នែកឃោសនា ឬហៅថាលក្ខារុង ដែលក្រុមនេះមានសមាជិក១៥នាក់ ត្រូវមានអាវុធកាន់ និងត្រូវដើរឃោសនាដើម្បីប្រមូលកម្លាំងៗ ក្រុមរបស់ខ្ញុំបានដើរឃោសនាប្រាប់ប្រជាជននៅវាលពង់

ត្រាចទង វាលពន់ ក្នុងស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ពីផែនការគឺ ទី១) វាយ លន់ នល់ និងទី២) ការប្រកាសរបស់សម្ដេចព្រះ នរោត្តម សីហនុ ឲ្យកូនចៅរួបរួមគ្នាដើម្បីធ្វើការតស៊ូ។ ពេលនោះសមាជិកនៅក្នុងក្រុមរបស់ខ្ញុំមួយចំនួនដូចជា ម៉ូត, ហ៊ុយ, យ៉ន បានស្លាប់នៅពេលវាយប្រយុទ្ធជាមួយកងទ័ព លន់ នល់ ដែលមានរថពាសដែកអមមកជាមួយនៅវាលពន់ ចំណែកខ្ញុំបានគេចខ្លួនរួច។

នៅឆ្នាំ១៩៧២ ខ្ញុំត្រូវបាន តាម៉ុក ផ្លាស់ឲ្យទៅគ្រប់គ្រងប្រជាជននៅស្រុកកណ្ដាលស្ទឹងក្នុងខេត្តកណ្ដាលវិញ ព្រោះ គុណ ដែលជាប្រធានគ្រប់គ្រងនៅទីនោះត្រូវបានសមាជិកក្នុងអង្គភាពយោធាជាមួយចាប់ខ្លួន។ ពេលខ្ញុំទៅដល់ស្រុកកណ្ដាលស្ទឹង ខ្ញុំមិនឃើញប្រជាជនរស់នៅទីនោះឡើយ គឺប្រជាជនត្រូវបានខ្មែរក្រហមកៀរឲ្យទៅរស់នៅភ្នំស្រង់ កាត់ភ្លុក ក្នុងស្រុកបសេដ្ឋអស់ហើយ។ ដូច្នេះខ្ញុំបាននៅធ្វើជាប្រធានកងពលលេខ១១ ក្នុងអង្គភាពយោធា។ នៅអំឡុងពេលដែលខ្ញុំផ្លាស់ទៅស្រុកកណ្ដាលស្ទឹង ក៏មានការផ្លាស់ប្ដូរភូមិភាគដែរ គឺតំបន់ដែលស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៤ រួមមានស្រុកកណ្ដាលស្ទឹង និងស្រុកដង្កោ ត្រូវបានកាត់បញ្ចូលទៅក្នុងភូមិភាគពិសេសទាំងអស់ ដែលមាន វន វ៉េត គឺជាលេខា។ ក្រៅពីកងពលលេខ១១របស់ខ្ញុំ នៅភូមិភាគពិសេសមានពីរកងពលទៀតគឺកងពលលេខ១២ គ្រប់គ្រងដោយ តាណាត និងកងពលលេខ៩២០ គ្រប់គ្រងដោយ សារឿន ហៅ ០៥។

កងពលរបស់ខ្ញុំមានបីកងវរសេនាធំបញ្ចូលគ្នា ដែលមានសមាជិកសរុប២៧០០នាក់ ប្រចាំការនៅផ្សារកន្ទួច និងនៅទួលគី។ កងពលរបស់ខ្ញុំបានវាយពីទួលគី កាត់មកផ្លូវជាតិលេខ៣ ចោមចៅ និងពោធិចិនតុង រហូតទទួលបានជ័យជម្នះ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ រយៈពេលមួយខែក្រោយមក សុន សេន បានហៅខ្ញុំទៅប្រជុំនៅសាលាខេត្តកណ្ដាល ក្នុងក្រុងតាខ្មៅ។ សុន សេន បានប្រាប់ខ្ញុំថា «មិត្តមិនទទួលខុសត្រូវខាងកងទ័ពទៀតទេ មិត្តត្រូវទៅទទួលខុសត្រូវខាងមូលដ្ឋានវិញ» គឺនៅតំបន់២៥។ នៅពេលនោះគណៈកម្មាធិការនៅតំបន់ ២៥ មានមនុស្ស៤នាក់គឺ១) ឈ្មោះ ជា គឺជាលេខាតំបន់, ២) ឈ្មោះ ប្រាក់ គឺជាអនុលេខា, ៣) ស៊ាន គឺជាសមាជិក និង ៤) ខ្ញុំគឺជាសមាជិក ដែលទទួលលេខាស្រុកស្អាង។

នៅខែកុម្ភៈ ឆ្នាំ១៩៧៦ ខ្ញុំត្រូវបាន តាម៉ុក ដកឲ្យទៅនៅតំបន់៣៥ ក្នុងភូមិភាគនិរតីវិញ ដែលមាន កង ចាប គឺជាលេខាតំបន់, រឿន អនុលេខាតំបន់ ហើយខ្ញុំគឺជាសមាជិក។ ពេលនោះ ខ្ញុំមានតួនាទីគ្រប់គ្រងប្រជាជននៅស្រុកឈូក, កោះស្លា និង ស្រែក្នុង។ ខ្ញុំបានដឹកនាំប្រជាជនលើកទំនប់កោះស្លា ស្តុកឈូក ទំនប់ក្បាលមាស ទំនប់ព្រែកតន់ហន់ និងទំនប់រំលេច។ នៅអំឡុងពេលនោះខ្ញុំក៏បានរៀបការជាមួយប្រពន្ធឈ្មោះ កាន គឺជាប្រធានកងចល័តនៅស្រុកឈូកដែលបានដឹកនាំកម្លាំងប្រជាជនទៅលើកទំនប់រំលេចដែរ។

នៅរដូវប្រាំង ឆ្នាំ១៩៧៧ ខ្ញុំត្រូវបាន តាម៉ុក ផ្លាស់ឲ្យមកធ្វើជាលេខាតំបន់៤១ ភូមិភាគកណ្ដាលវិញ ព្រោះគណៈគ្រប់គ្រងនៅភូមិភាគកណ្ដាលស្ទើរតែទាំងអស់ត្រូវបានចាប់ខ្លួននៅសល់តែ កែ ពក មួយប៉ុណ្ណោះ។ ចំណែកប្រពន្ធរបស់ខ្ញុំក៏បានមកធ្វើការនៅមន្ទីរតំបន់៤១ជាមួយខ្ញុំដែរ។ មន្ទីរតំបន់៤១ មានទីតាំងស្ថិតនៅព្រៃទទឹង ចំណែកគណៈកម្មាធិការគ្រប់គ្រងតំបន់៤១ មាន ខ្ញុំ, ស៊ុម, ជឹម និងកេត។ តំបន់៤១ ពេលនោះរួមមាន ១) ស្រុកបាធាយ គ្រប់គ្រងដោយ ភឹម ២) ស្រុកជើងព្រៃ គ្រប់គ្រងដោយ ម៉ុន ៣) ស្រុកកងមាស គ្រប់គ្រងដោយ កាន ៤) ស្រុកព្រៃឈរ និង ៥) ស្រុកកំពង់សៀម។ ខ្ញុំបានដឹកនាំប្រជាជនកងចល័តទៅលើកទំនប់ ១មករា នៅជាប់ស្ទឹងជីនិត ក្នុងខេត្តកំពង់ធំ, ទំនប់ ៦ មករា ជាប់ស្រុកសន្ទុក ក្នុងខេត្តកំពង់ធំ, ទំនប់១៧ មេសា ជាប់ស្រុកជើងព្រៃ និងព្រៃឈរក្នុងខេត្តកំពង់ចាម, ទំនប់ពាមជាំង នៅស្រុកកងមាស និងភ្នំព្នៅ ក្នុងស្រុកបាធាយ ខេត្តកំពង់ចាម ដែលស្ថិតនៅក្នុងភូមិភាគឧត្តរនៅពេលនោះ។

ខ្ញុំបានទៅចូលរួមសន្និបាតទូទាំងប្រទេស នៅស្តាតអូឡាំពិក ដែលមានប៉ុល ពត, នួនជា, អៀង សារី, តាម៉ុក និង សោ ភឹម គឺជាគណៈអធិបតី។ សន្និបាតបានលើកពីផែនការសំខាន់ពីរគឺ ការការពារ និងកសាងប្រទេសដែលក្នុងនោះមានការកសាងកម្លាំងពង្រឹងកម្លាំង ពង្រីកកម្លាំង វិធានការផ្ទៃក្នុង លទ្ធផលការងារដែលសម្រេចបាន និងលើកផែនការសម្រាប់ឆ្នាំខាងមុខ។ នៅពេលសន្និបាត

នោះ គណៈតំបន់ត្រូវឡើងរាយការណ៍ប្រាប់ទៅដល់គណៈអធិបតីអំពីលទ្ធផលការងារដែលសម្រេចបាន។

នៅពេលវៀតណាម វាយចូលមកនៅឆ្នាំ១៩៧៩ ខ្ញុំបានភៀសខ្លួនមកទៅនៅអន្លង់ និងបូសពក ជាប់ស្ទឹងជីនិត ក្នុងខេត្តកំពង់ធំ។ ចំណែកប្រពន្ធរបស់ខ្ញុំ បានស្លាប់នៅពេលរត់គេចខ្លួននោះ ។

នៅឆ្នាំ១៩៨០ ខ្ញុំបានបន្តភៀសខ្លួនទៅរស់នៅភ្នំដងរែក ជាមួយ សុន សេន ម្ដុំតំបន់មុំបី។ នៅទីនោះ ខ្ញុំបានគ្រប់គ្រងកងនារីនៅមន្ទីរក-៧ របស់ សុន សេន។ ខ្ញុំបានរៀបការប្រពន្ធទី ២ឈ្មោះ នាង និងមានកូនស្រីម្នាក់។ ក្រោយមកខ្ញុំចុះមកនៅជំរំស្ទឹងចាន់ (ក្នុងទឹកដីថៃ)។ នៅពេលវៀតណាម ដកកងទ័ពចេញពីប្រទេសកម្ពុជា ខ្ញុំបានមកនៅអន្លង់វែង ហើយមួយឆ្នាំក្រោយមក ខ្ញុំក៏បានផ្លាស់មកនៅឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង។

ប៉ុន្តែនៅក្នុងឯកសារសំណុំរឿងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អោម អាន មានតួនាទីជាច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩) ៖

- លេខាតំបន់ ៤១ (ភូមិភាគកណ្ដាល)
- សមាជិកគណៈកម្មាធិការភូមិភាគកណ្ដាល
- អនុលេខាភូមិភាគកណ្ដាល (នៅចុងឆ្នាំ១៩៧៧ ដល់ខែមករា ឆ្នាំ១៩៧៩)

អោម អាន ត្រូវបានសហចៅក្រមអន្តរជាតិដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទឧក្រិដ្ឋជាច្រើនតាំងពីឆ្នាំ ២០១៥មក ៖

- អំពើប្រល័យពូជសាសន៍លើជនជាតិចាម (នៅក្នុងខេត្តកំពង់ចាម)
- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ជាទាសករ ការដាក់ពន្ធនាគារ អំពើទារុណកម្ម អំពើអមនុស្សធម៌ ដទៃទៀត (រួមមាន អាពាហ៍-ពិពាហ៍ដោយបង្ខំ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងសាសនា
- ការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺអំពើមនុស្សឃាតដោយចេតនា។

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺ ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅតាមតំបន់ និងទីតាំងនានាដូចខាងក្រោម៖

- ការដ្ឋានធ្វើពលកម្មដោយបង្ខំនៅទំនប់អន្លង់ជ្រៃ
- ទីតាំងសម្លាប់មនុស្សគោកព្រីង
- មន្ទីរសន្តិសុខមិត្តសុប
- មន្ទីរសន្តិសុខទួលបេង និងវត្តអង្គញដី
- មន្ទីរសន្តិសុខវត្តអូរត្រកួន
- មន្ទីរសន្តិសុខវត្តបាធាយ
- មន្ទីរសន្តិសុខវត្តភ្នំប្រុស
- មន្ទីរសន្តិសុខវត្តតាមៈ

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាអំពើអមនុស្សធម៌ដទៃទៀត តាមរយៈអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅតាមតំបន់ និងទីតាំងនានាដូចខាងក្រោម៖

- ស្រុកកំពង់សៀម (តំបន់ ៤១)
- ស្រុកព្រៃឈរ (តំបន់ ៤១)

អោម អាន បានស្លាប់នៅរសៀល ថ្ងៃសុក្រ ទី៦ ខែវិច្ឆិកា ឆ្នាំ២០២០ ក្នុងអាយុ៨៧ឆ្នាំ។ អោម អាន គឺជាជនសង្ស័យមួយរូប នៅក្នុងសំណុំរឿង ០០៤/០២។ បើតាមច្បាប់ជាតិត្រង់មាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជាបានចែងថា មរណភាពនៃជនជាប់ចោទនាំដល់ការរំលត់បណ្ដឹងអាជ្ញា។

# ស្នូរគ្រាប់កាំភ្លើង

អ៊ុន សុជាទី




*ជូ គីម ឡូន នៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ (អ៊ុន សុជាទី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ម៉ោងប្រហែល៩យប់ នៅពេលដែលខ្ញុំកំពុងតែដេកក្បែរប្តីនិងកូនរបស់ខ្ញុំនៅក្នុងខ្ទម ស្រាប់តែ ឮសូរសំឡេងជើងរបស់មនុស្សបានដើរសំដៅចូលមករកខ្ទមរបស់ខ្ញុំ។ ភ្លាមៗនោះ ខ្ញុំបានឮសូរសំឡេងស្រែកហៅពីខាងមុខមាត់ទ្វារខ្ទមរបស់ខ្ញុំថា «អង្គការឲ្យមកហៅបងនួនទៅរៀនសូត្រ»។ ខ្ញុំស្គាល់ថានោះគឺជាសំឡេង ពូថ្ងៃរបស់ខ្ញុំ។ មិនបង្អង់យូរ ខ្ញុំក៏ស្រែកសួរពីក្នុងខ្ទមរបស់ខ្ញុំទៅវិញថា «តើអង្គការឲ្យគាត់ទៅរៀនសូត្រនៅឯណាដែរពូ»? គាត់បាននិយាយតបមកខ្ញុំវិញដោយកំបុតៗថា «មិនដឹងយកទៅរៀនសូត្រនៅឯណាទេ»? ខ្ញុំក៏ប្រាប់ទៅគាត់វិញថា «គាត់សម្រាន្តលក់ហើយ»។

ស្វួស ឌឹម ហៅ កុត នួន គឺជាប្តីរបស់ខ្ញុំ។ គាត់មានស្រុកកំណើតនៅក្នុងភូមិធ្លក់រលើង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ បងនួនរស់នៅ និងសិក្សានៅក្នុងភូមិ ហើយក្រោយមកគាត់បានចាកចេញពីស្រុកកំណើតដើម្បីទៅធ្វើការងារនៅខេត្តកំពង់ឆ្នាំង, កំពង់ស្ពឺ និងក្រោយមកនៅទីក្រុងភ្នំពេញ។ នៅក្នុងសម័យសង្គមរាស្ត្រនិយម បងនួន ធ្វើជាប៉ូលីស ហើយនៅក្នុងរបប លន់ នល់ គាត់បានផ្លាស់ប្តូរមកធ្វើជាពេទ្យទាហានវិញ។

ខ្ញុំឈ្មោះ ជូ គីម ឡួន អាយុ៦៩ មានមុខរបរធ្វើស្រែចម្ការ។ ខ្ញុំមានស្រុកកំណើតនៅក្នុងភូមិធ្នង់រលើង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំគឺជាកូនទី៧ក្នុងចំណោមបងប្អូន១០នាក់។ ឪពុករបស់ខ្ញុំឈ្មោះ ជូ ទឹម និងម្តាយរបស់ខ្ញុំឈ្មោះ ប៉ាន់ លឹម។ ចាប់ពីឆ្នាំ១៩៧១ មកនៅក្នុងឃុំលាយបូរ ជារឿយៗមានការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម។ ការប្រយុទ្ធគ្នានេះ បានធ្វើឲ្យផ្ទះសម្បែងរបស់ប្រជាជនជាច្រើន ឆាបឆេះខ្ទេចខ្ទីគ្មានសល់ដោយសារតែគ្រាប់ផ្លោងធ្លាក់ចំ។ បងប្រុសរបស់ខ្ញុំឈ្មោះ ជូ តេង ដែលជាទាហានបម្រើដល់របស់រដ្ឋាភិបាល លន់ នល់ បានដឹងអំពីហេតុការណ៍ខ្លះៗនៃការចាប់ផ្តើមសង្គ្រាមនេះ។ គាត់បានដឹងថាសភាពការណ៍នៃការប្រយុទ្ធគ្នារវាងទាហានលន់នល់ និងកងទ័ពខ្មែរក្រហម គឺមិនងាយស្រាកស្រាន្តឡើយ ហើយក៏បានប្រាប់ខ្ញុំ និងក្រុមគ្រួសារចាកចេញពីស្រុកកំណើត ទៅរស់នៅក្នុងទីក្រុងភ្នំពេញបណ្តោះអាសន្នមួយរយៈពេលសិន។ បងតេង បានស្នើសុំខទ្ទម្កាគចក្រ ដែលដឹកស្បៀងអាហារពីភ្នំពេញដើម្បីផ្គត់ផ្គង់ដល់ទាហាន លន់ នល់ នៅក្នុងខេត្តតាកែវ ឲ្យក្រុមគ្រួសាររបស់ខ្ញុំធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញ។ ខ្ញុំនិងម្តាយ បានចាកចេញទៅភ្នំពេញមុនឪពុកនិងប្អូនប្រុសរបស់ខ្ញុំ ព្រោះខទ្ទម្កាគចក្រនោះមិនអាចជិះបានគ្នាច្រើនឡើយ។ រំលងបានប្រហែល ៣ថ្ងៃ ឪពុកនិងប្អូនប្រុសរបស់ខ្ញុំ បានធ្វើដំណើរមកភ្នំពេញដែរ។ នៅក្នុងទីក្រុងភ្នំពេញ ខ្ញុំនិងក្រុមគ្រួសារ បានសុំផ្ទះបងស្រីរបស់ខ្ញុំឈ្មោះ ជូ សារឿន ដើម្បីស្នាក់នៅបណ្តោះអាសន្នសិន។ ផ្ទះរបស់គាត់ស្ថិតនៅម្តុំសារមន្ទីរខេត្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងបច្ចុប្បន្ន។ គ្រួសារយើង គឺជាគ្រួសារធំ។ បងសារឿនមានកូនចំនួន៨នាក់។ គាត់មិនប្រកបមុខរបរអ្វីនោះទេ។ បងសារឿន ស្នាក់នៅផ្ទះដើម្បីមើលថែរក្សាកូនៗរបស់គាត់។ ចំណែកឯបងថ្លៃរបស់ខ្ញុំវិញ គឺជាគយ។ បងថ្លៃរបស់ខ្ញុំ គឺជាអ្នករកចំណូលដើម្បីផ្គត់ផ្គង់ដល់ក្រុមគ្រួសារ។ រស់នៅក្នុងទីក្រុងភ្នំពេញ ខ្ញុំនៅតែផ្ទះជួយដាំបាយធ្វើម្ហូប និងកិច្ចការផ្ទះផ្សេងៗទៀត។ ចំណែកឯឪពុកម្តាយរបស់ខ្ញុំចាស់ជរា មិនអាចជួយការងារអ្វីបានច្រើននោះទេ។

នៅក្នុងឆ្នាំ១៩៧១ ដដែល ខ្ញុំបានរៀបការជាមួយប្តីរបស់ខ្ញុំ។ ប្តីរបស់ខ្ញុំធ្លាប់បានរៀបការម្តងរួចមកហើយ។ លុះប្រពន្ធរបស់គាត់ ឈឺស្លាប់ ចាស់ទុំក៏បានផ្សំផ្គុំឲ្យខ្ញុំនិងប្តីរបស់ខ្ញុំរៀបការជាមួយគ្នា។ ពិធីរៀបការរបស់ខ្ញុំ បានធ្វើឡើងនៅផ្ទះបងសារឿន។ យើងរៀបការមួយព្រឹក ដោយមានប្រគំភ្លេងការរណ្តំរងំ។ យើងមិនអញ្ជើញភ្ញៀវមកចូលរួមច្រើនកុះករនោះទេ។ យើងអញ្ជើញតែសាច់ញាតិទាំងសងខាងមកចូលរួមតែប៉ុណ្ណោះ។ បន្ទាប់ពីរៀបការរួច ខ្ញុំនិងក្រុមគ្រួសារ បានផ្លាស់ទៅរស់នៅផ្ទះប្តីរបស់ខ្ញុំនៅឯម្តុំផ្សារដេប៉ូវិញ។ យើងរៀបការមិនដល់១ឆ្នាំផង ខ្ញុំក៏មានផ្ទៃពោះកូនដំបូង។ នៅក្នុងឆ្នាំ១៩៧៤ ខ្ញុំបានបង្កើតកូនស្រីម្នាក់ ហើយយើងដាក់ឈ្មោះឲ្យវាថា ស្រីពៅ។

នៅខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលខ្ញុំកំពុងតែដាំបាយ ស្រាប់តែខ្ញុំឮសូរក្បួនរថយន្តចូលមកក្នុងទីក្រុងភ្នំពេញ ហើយឮសូរមនុស្សស្រែកប្រកាសតាមផ្លូវថា «ជ័យយោ! ជ័យយោ! រណសិរ្សសាមគ្គីសង្គ្រោះជាតិឈ្នះហើយ! បងប្អូនទាំងអស់គ្នាឆាប់ចាកចេញពីទីក្រុងភ្នំពេញទៅ ហើយ៣ថ្ងៃ ក្រោយមកចាំវិលត្រឡប់មកវិញ»។ ក្រុមខ្មែរក្រហមបានស្រែកឃោសនាទ្រហឹងអឺងកងពាសពេញទីក្រុងភ្នំពេញ។ មិនតែប៉ុណ្ណោះ ក្រុមខ្មែរក្រហមទាំងអស់នោះ បានស្រែកប្រកាសតាមឧបករណ៍បំពងសំឡេងឲ្យប្រជាពលរដ្ឋនៅក្នុងទីក្រុងភ្នំពេញទាំងអស់រៀបចំបង្វេចដើម្បីចាកចេញពីទីក្រុងភ្នំពេញភ្លាមៗ ដោយយកតែឆ្នាំងបាយ និងអង្ករសម្រាប់ហូបតាមផ្លូវប្រហែលរយៈពេល៣ថ្ងៃបានហើយ។ ខ្ញុំដាំបាយរួចនិងមិនទាន់បានហូបផងក៏ប្រញាប់រៀបចំអីវ៉ាន់ចាកចេញតាមការឃោសនា។ ខ្ញុំ, ប្តី, កូន, ម្តាយឪពុក និងប្អូនប្រុសរបស់ខ្ញុំ បាននាំគ្នាប្រមូលចានឆ្នាំង និងបាយដែលដាំរួចនោះ ខ្ចប់យកមកទុកហូបនៅតាមផ្លូវ។ យើងមិនបានប្រមូលសម្ភារល្អៗយកជាប់ទៅជាមួយនោះទេ។ យើងបានចាក់សោទុកសម្ភារល្អៗនៅក្នុងផ្ទះទាំងអស់។ ប្អូនរបស់ខ្ញុំ មានកង់១ដាក់អីវ៉ាន់ ចំណែកឯខ្ញុំនិងប្តី មានឡានចាស់មួយគ្រឿងសម្រាប់ដាក់អីវ៉ាន់រុញ។ ខ្ញុំចាកចេញពីផ្ទះដោយមានតែអង្ករ, សម្លៀកបំពាក់,មុង និងកន្ទេល សម្រាប់ក្រាលដេកតាមផ្លូវតែប៉ុណ្ណោះ។ នៅតាមផ្លូវកងទ័ពខ្មែរក្រហម បានស្រែកកុំឲ្យយើងរុញឡាននោះ ប៉ុន្តែខ្ញុំបានប្រាប់ទៅកងទ័ព

ខ្មែរក្រហមវិញថា ឡាននេះខូចហើយ យើងយកវាមកសម្រាប់ដាក់តែអីវ៉ាន់តែប៉ុណ្ណោះ។ យើងធ្វើដំណើរចេញមកពីទីក្រុងភ្នំពេញសំដៅមកស្រុកកំណើតតាមផ្លូវជាតិលេខ៣។ ប្អូនខ្ញុំម្នាក់បណ្តើរកង់ និងម្នាក់ទៀតរុញឡានដាក់អីវ៉ាន់ជាមួយប្តីរបស់ខ្ញុំ។ ចំណែកឯខ្ញុំវិញដឹកដៃកូន និងមើលថែម្តាយឪពុកដែលចាស់ជរា។ ពេលនោះខ្ញុំមានផ្ទៃពោះកូនទី២ របស់ខ្ញុំចំនួន២ខែ ហើយខ្ញុំចាញ់កូនខ្លាំងណាស់នៅតាមផ្លូវ។ ខ្ញុំស្ទើរតែគ្មានកម្លាំងដើរទៅមុខ។ មនុស្សម្នាជាច្រើនធ្វើដំណើរនៅតាមផ្លូវរៀងៗខ្លួន។ ខ្ញុំឃើញមានប្រជាជនជាច្រើនដេកស្លាប់នៅតាមផ្លូវជាបន្តបន្ទាប់។ យើងចំណាយអស់រយៈពេល ២២ ថ្ងៃទម្រាំធ្វើដំណើរមកដល់ស្រុកត្រាំកក់ ខេត្តតាកែវ។

ដំបូងខ្ញុំនិងក្រុមគ្រួសារ បានធ្វើដំណើរមកដល់អង្គតាសោម។ ក្រុមខ្មែរក្រហមបានមកទទួលយើងនៅម្តុំពោធិ៍ព្រះសង្ឃ ស្ថិតនៅខាងលិចផ្សារអង្គតាសោម ដែលមានឈ្មោះ ឈិន ធ្វើជាមេភូមិ។ ពោធិ៍ព្រះសង្ឃ គឺជាកន្លែងស្នាក់នៅលើកទី១ របស់ខ្ញុំនិងក្រុមគ្រួសារ និងប្រជាជនផ្សេងទៀត ដែលជម្លៀសមកពីទីក្រុងភ្នំពេញ។ មកដល់ពោធិ៍ព្រះសង្ឃ ក្រុមគ្រួសាររបស់ខ្ញុំអស់អង្ករហូប។ ខ្មែរក្រហម បានចែកអង្ករដែលមានគ្រាប់ពណ៌ក្រហមឲ្យយើងហូប។ អង្ករនោះរឹងខ្លាំងណាស់ យើងទំពារស្ទើរមិនបែក ប៉ុន្តែយើងគ្មានជម្រើសអ្វីផ្សេងឡើយ។ មកដល់ថ្ងៃដំបូង ខ្មែរក្រហមមិនទាន់បែងចែកឲ្យយើងធ្វើការងារអ្វីនោះទេ។ ខ្មែរក្រហម នៅអង្កេតមើលយើងសិន ព្រោះយើងត្រូវខ្មែរក្រហមចាត់ចូលជាប្រជាជនថ្មី។ ខ្មែរក្រហមបានប្រើប្តីរបស់ខ្ញុំនិងប្រជាជនមួយចំនួនទៀតឲ្យទៅសាងសង់ខ្ទមតូចៗសម្រាប់ក្រុមគ្រួសារ និងប្រជាជនថ្មី ដែលខ្មែរក្រហមជម្លៀសមកពីកន្លែងផ្សេងៗស្នាក់នៅ។ ខ្ទមនោះ មានសសរធ្វើអំពីដើមឫស្សី ដំបូលប្រក់ស្លឹកត្នោត និងជញ្ជាំងបាំងស្លឹកដូង។

មិនយូរប៉ុន្មាន ខ្មែរក្រហមបានឲ្យយើងបានចាកចេញពីពោធិ៍ព្រះសង្ឃមករស់នៅខាងជើងសាលាឃុំលាយបូរវិញ។ ប្តីរបស់ខ្ញុំ បានយកដើមឫស្សីមកធ្វើជារានខ្ពស់ផុតពីដីបន្តិចដើម្បីដេក។ មកដល់ត្រឹមពេលនេះខ្ញុំមានផ្ទៃពោះកូនទី២ប្រហែលជា៥ខែ។ នៅក្នុងរដូវស្ទូងឆ្នាំ១៩៧៥ ខ្មែរក្រហម បានចាប់ផ្តើមប្រមូលយករបស់របរចានឆ្នាំងរបស់យើងដាក់រួមគ្នា បែកចែកការងារឲ្យយើងធ្វើរួម ហើយក៏ចាប់ផ្តើមហូបរួមដែរ។ ខ្ញុំត្រូវចេញទៅដកស្ទូង រែកដី លើកប្រឡាយ និងធ្វើការងារផ្សេងៗទៀតតាមការចាត់តាំងរបស់មេកង។ ចំណែកឯ ម្តាយរបស់ខ្ញុំវិញ នៅមើលថែរក្សាចៅ រីឯឪពុករបស់ខ្ញុំធ្វើបង្គី។ ឪពុករបស់ខ្ញុំ គឺជាអតីតមេឃុំលាយបូរតាំងតែពីខ្ញុំនៅតូចៗម៉្លេះ។ នៅពេលត្រឡប់ទៅរស់នៅក្នុងភូមិវិញ ប្រជាជននៅទីនោះស្គាល់ឪពុករបស់ខ្ញុំគ្រប់ៗគ្នា ដូច្នេះគាត់មិនអាចលាក់បាំងប្រវត្តិរូបរបស់គាត់បានទេ។ ថ្ងៃមួយ ខ្មែរក្រហម បាននាំគាត់ទៅសួរចម្លើយ។ ខ្មែរក្រហម បានបញ្ចុះបញ្ចូលឲ្យឪពុករបស់ខ្ញុំត្រឡប់ទៅធ្វើការងារបម្រើដល់ខ្មែរក្រហមវិញ ប៉ុន្តែឪពុករបស់ខ្ញុំប្រកែកតវ៉ាថា គាត់មានវ័យចំណាស់ ហើយគាត់បានលាលែងពីការងារនៅក្នុងរបបចាស់អស់ទៅហើយ។ ឪពុករបស់ខ្ញុំប្រាប់ទៅខ្មែរក្រហមថា គាត់អាចជួយធ្វើបង្គីឲ្យក្រុមយុវជនរែកដីបាន។ បន្ទាប់មក ឪពុករបស់ខ្ញុំ ក៏រួចខ្លួនពីការចាប់ខ្លួននិងសម្លាប់។ ក្រៅពីនោះ ខ្ញុំបានទទួលដំណឹងពីប្រជាជនមូលដ្ឋានថា បានឃើញបងប្រុសរបស់ខ្ញុំឈ្មោះ ហៀម ចៅហ៊ី និងអតីតទាហាន លន់ នល់ ផ្សេងទៀត ប្រហែលជា ១០០នាក់ ត្រូវខ្មែរក្រហមជម្លៀសចេញពីខេត្តតាកែវ ដោយដៃមានជាប់ចំណង និងដើរជាជួរៗទៅនៅម្តុំក្រាំងតាចាន់ ហើយក៏បាត់ខ្លួននៅទីនោះតែម្តង។ ខ្ញុំគ្មានសង្ឃឹមថាបងហ៊ី នៅរស់រានមានជីវិតនោះទេ ព្រោះគាត់គឺជាអតីតទាហានលន់ នល់ ពាក់ស័ក្តិ៣។

ថ្ងៃមួយ មានកងឈ្លបស្រីៗចំនួន២នាក់ បានដើរឆែកឆេរផ្ទះរបស់ប្រជាជន។ ឈ្លបស្រីទាំងពីរនាក់នោះក៏បានមកឆែកអីវ៉ាន់នៅក្នុងខ្ទមរបស់ខ្ញុំដែរ។ ឈ្លបបានរើរុះយកឥវ៉ាន់របស់ខ្ញុំដូចជាក្រែមម្សៅជាដើម។ កងឈ្លបស្រីនោះ ក៏បានប្រទះឃើញស័ក្តិរបស់ប្តីខ្ញុំ ដែលធ្លាប់ពាក់នៅក្នុងសម័យ លន់ នល់ ដែរ។ រំលងបានមួយយប់មួយថ្ងៃ ពេលដែលប្តីរបស់ខ្ញុំត្រឡប់មកពីធ្វើការងារវិញ និងបន្ទាប់ពីអាហារពេលល្ងាចរួច យើងក៏ចូលដេក។ យប់នោះគឺជាយប់ចុងក្រោយដែលខ្ញុំបានឃើញមុខប្តីរបស់ខ្ញុំ។ ពូថ្លៃរបស់ខ្ញុំ, ប្រធានភូមិ ព្រមទាំងអនុប្រធានភូមិ បាន



*ជូ គីម ឡួន នៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ (អ៊ុន សុដារី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

មកហៅប្ដីខ្ញុំឲ្យទៅរៀនសូត្រនៅម៉ោងប្រហែល៩យប់។ ខ្ញុំសួរយ៉ាងណា ក៏គ្មាននរណាប្រាប់ខ្ញុំថា គាត់យកប្ដីរបស់ខ្ញុំទៅរៀនសូត្រនៅឯណាឡើយ។ នៅពេលដែលប្ដីរបស់ខ្ញុំ បានឮសំឡេងស្រែកហៅ គាត់ក៏បានក្រោកឡើងទាញអាវយកមកពាក់ ហើយទាញក្រមាដែលមានពណ៌ខៀវលាយនិងពណ៌ក្រហម ដែលយើងយកមកពីភ្នំពេញនោះមកស្លៀក រួចចាកចេញពីខ្ទមដើរចេញទៅជាមួយបុរសទាំង៣នាក់នោះ។ ជួនពេលនោះ កូនរបស់ខ្ញុំភ្ញាក់ ហើយស្រែកយំយ៉ាងខ្លាំង។ ខ្ញុំបានដើរត្រឡប់ចូលទៅក្នុងខ្ទមវិញ ដើម្បីលួងលោមកូនរបស់ខ្ញុំកុំឲ្យយំ។ ក្នុងយប់នោះ កូនរបស់ខ្ញុំយំមិនឈប់ទាល់តែសោះ ហាក់បីដូចជាវាបានដឹងរឿងអ្វីមួយដែលនឹងបម្រុងកើតឡើងចំពោះប្ដីរបស់ខ្ញុំ។ បងស្រីរបស់ខ្ញុំ បានហែកជញ្ជាំងស្លឹកដូង រួចលួចមើលចេញទៅក្រៅផ្ទះ។ គាត់បានឃើញបុរសទាំង៣នាក់នោះ មានស្ពាយកាំភ្លើង និងកាន់ចបនៅនឹងដៃ ហើយថែមទាំងយកខ្សែគោមកចងដៃទាំងពីររបស់ប្ដីខ្ញុំទៅខាងក្រោយខ្នងរួចបណ្ដើរចេញទៅ។ ចំណែកឯ ម្ដាយឪពុកក្មេករបស់ខ្ញុំវិញ គឺជាប្រជាជនមូលដ្ឋានបានឮសូរមេភូមិប្រជុំគ្នាពីពេលល្ងាចថា «យប់នេះ យើងត្រូវយក សមមិត្ត នួន ដែលជាប្ដីរបស់ សមមិត្ត ឡួនទៅរៀនសូត្រ»។ គ្រាន់តែឮអំពីរឿងរ៉ាវទាំងនេះហើយ គាត់យំមិនឈប់សោះឡើយ។ ប្រហែលជាមួយម៉ោងក្រោយ បន្ទាប់ពីកងឈ្លបនាំប្ដីរបស់ខ្ញុំចាកចេញទៅ ស្រាប់តែឮសូរសំឡេងគ្រាប់កាំភ្លើងបាញ់ចំនួន ៣គ្រាប់ជាំងជាំងជួនៗគ្នាបានផ្ទុះឡើង។ ឪពុកម្ដាយក្មេករបស់ខ្ញុំ បានស្រែកទ្រហោយំយ៉ាងខ្លាំង ព្រោះគាត់ដឹងថាកូនរបស់គាត់ ត្រូវបានសម្លាប់ហើយ។ ឪពុកម្ដាយក្មេករបស់ខ្ញុំ ដើរចុះដើរឡើងពេញមួយយប់ដោយឥតបានដេកឡើយ។ នៅយប់នោះ ប្រជាជនមូលដ្ឋាន បានមកប្រាប់ខ្ញុំថា ឈ្លបបានសម្លាប់ប្ដីរបស់ខ្ញុំនៅខាងលិចវត្តលាយបូរហើយ។ ខ្ញុំ ដេកយំឱបកូននិងឈឺចាប់បំផុតនៅក្នុងយប់នោះ។ ក្រោយមក ម្ដាយឪពុកក្មេករបស់ខ្ញុំ ក៏ឈឺចិត្តខ្លាំងណាស់ដែរ ដោយមិនអាចការពារជីវិតកូនរបស់ខ្លួនបាន។ គាត់ហូបអាហារមិនបានរហូតដល់ធ្លាក់

ខ្លួនឈឺស្លាប់។

បន្ទាប់ពីប្តីរបស់ខ្ញុំស្លាប់មិនបានប៉ុន្មានផង ប្រធានភូមិឈ្មោះ តាវិត បានបញ្ជូនខ្ញុំ កូននិងសាច់ញាតិរបស់ខ្ញុំទាំងអស់ចេញពីសហករណ៍ ដែលខ្ញុំកំពុងតែរស់នៅ ដោយផ្លាស់ទៅរស់នៅឯកង៣ ដែលស្ថិតនៅខាងត្បូងសាលាឃុំលាយបូរវិញ ព្រោះប្រធានកងបានសង្កេតឃើញខ្ញុំតែងតែយំជារៀងរាល់ថ្ងៃ។ តាហង់ គឺជាអ្នកបររទេះដូនដំណើរឪពុកម្តាយរបស់ខ្ញុំ ដើម្បីជិះទៅកាន់ទីកន្លែងថ្មី ព្រោះឪពុកម្តាយរបស់ខ្ញុំចាស់ជរាពិបាកក្នុងការធ្វើដំណើរណាស់។ មេកងបានរាយការណ៍ប្រាប់មេកងនៅកង៣ថា ខ្ញុំគឺជាខ្មាំងដែលប្តីទើបតែត្រូវអង្គការយកទៅរៀនសូត្រ។ អ្នកនៅកង៣ តែងតែតាមដាន និងអង្កេតមើលប្រជាជនថ្មី។ រស់នៅក្នុងកង៣ មេកង បានប្រើខ្ញុំឲ្យធ្វើការងារជាច្រើន ហើយខ្ញុំមិនដែលទទួលបានអាហារហូបចុកគ្រប់គ្រាន់ឡើយ។ ជីវិតជាស្ត្រីមេម៉ាយ រស់នៅជាមួយកូន គ្មានប្តីមើលថែរក្សា ធ្វើការងារលំបាកលំបិនតែម្នាក់ឯង ថែមទាំងពពោះកូននៅក្នុងផ្ទៃទៀត វាពិតជាការធ្វើទារុណកម្មមួយដ៏ធ្ងន់ធ្ងរខ្លាំងណាស់សម្រាប់រូបខ្ញុំ។ រស់នៅក្នុងសហករណ៍ថ្មីនេះ ខ្ញុំកើតបានកូនប្រុសម្នាក់ទៀត។ ខ្ញុំដាក់ឈ្មោះឲ្យកូនប្រុសរបស់ខ្ញុំថា រតនា ។ ពេលដែលខ្ញុំសម្រាលកូនរួច ខ្ញុំបានដេកអាំងភ្លើងបានចំនួន៥ថ្ងៃ ហើយសម្រាកបានជិត១ខែដែរ។ អំឡុងពេលដែលខ្ញុំពពោះ និងបង្កើតកូនប្រុសរបស់ខ្ញុំ គឺខ្ញុំគ្មានថ្នាំលេប ឬគ្មានពេទ្យមកពិនិត្យផ្ទៃពោះឲ្យបានត្រឹមត្រូវនោះទេ។ លុះដល់ពេលរដូវច្រូតកាត់បានមកដល់ ប្រធានក្រុមរបស់ខ្ញុំ ដែលបានទទួលបញ្ជាពីមេភូមិ បានប្រើខ្ញុំឲ្យទៅច្រូតស្រូវក្បែរៗផ្ទះ។ ពេលនោះម្តាយរបស់ខ្ញុំ គឺជាអ្នកជួយមើលកូនឲ្យខ្ញុំ។ គាត់តែងតែស្រែកហៅខ្ញុំពីចម្ងាយ ឲ្យមកបំបៅដោះកូននៅពេលដែលកូនរបស់ខ្ញុំយំ។ ចំណែកឯកូនស្រីរបស់ខ្ញុំ ស្រីពៅ ត្រូវប្រធានកងឲ្យទៅរស់នៅក្នុងកងចល័ត។ ស្រីពៅ គ្មានអាហារហូបគ្រប់គ្រាន់ទេ។ ស្រីពៅ មានរូបរាងកាយស្គមកំព្រឹង។ ដោយគ្មានអាហារហូបគ្រប់គ្រាន់ ស្រីពៅ ដើររើសសម្បកខ្យងខ្ចៅហូប រហូតដល់ឈឺជ្រុះសក់។ ក្រោយមក ខ្ញុំបានបញ្ជូនស្រីពៅ ទៅព្យាបាលនៅឯមន្ទីរពេទ្យ ប៉ុន្តែ ស្រីពៅ នៅតែស្លាប់។

លុះរដូវច្រូតស្រូវរួចរាល់អស់ មេកង បានចាប់ផ្តើមចាត់ចែងការងារថ្មីឲ្យយើងធ្វើ។ ខ្ញុំមានកូនតូច មេកង បានឲ្យខ្ញុំទៅប្រមូលលាមកមកដាក់ហាល និងចិញ្ច្រាំទន្ទ្រានខែត្រ ដើម្បីធ្វើជាជីសម្រាប់ដាក់ស្រែនៅក្នុងរដូវវស្សា។ មិនយូរប៉ុន្មាន រដូវវស្សាក៏ចូលមកដល់ មេកងបានចាត់ឲ្យខ្ញុំទៅស្ទូងស្រូវនៅក្នុងស្រែ។ ពេលនោះជើងរបស់ខ្ញុំ មានដំបៅរហូតដល់ធ្លាយជាខ្ទុះហូរចេញមកក្រៅ ប៉ុន្តែខ្ញុំគ្មានថ្នាំសង្កូវអ្វីសម្រាប់ព្យាបាលនោះទេ ហើយខ្ញុំនៅតែត្រូវទៅចុះស្ទូងនៅវាលស្រែដដែល។ ក្រៅពីការងារដកស្ទូង ខ្ញុំត្រូវទៅគាស់គល់ឈើនៅក្នុងព្រៃ និងកាប់ឆ្ការព្រៃ ដើម្បីយកដីដាំដំណាំផ្សេងៗ ដូចជាដំឡូង, សណ្តែកដី និងអំពៅ។ នៅពេលដែលខ្ញុំធ្វើដំណើរឆ្លងកាត់ព្រៃទៅធ្វើចម្ការម្តងៗ ខ្ញុំតែងតែឃើញមានសាកសពដែលកប់មិនជិត ហើយធុំក្លិនស្អុយឆ្អួលនៅពាសពេញតាមផ្លូវ។ ពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំត្រូវតែទៅធ្វើការងារដែលការងារទាំងអស់នោះតែងតែផ្លាស់ប្តូរទៅតាមរដូវកាល។ អង្គការមិនដែលខ្វល់ខ្វាយថា តើអ្នកមកពីណាឈឺឬក៏ជា មានផ្ទៃពោះឬអត់នោះទេ ប៉ុន្តែអង្គការនៅតែឲ្យយើងទៅធ្វើការងារនិងសម្រេចឲ្យបានទៅតាមផែនការដែលអង្គការបានកំណត់ឲ្យ។

នៅរដូវស្រូវទុំក្នុងឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានចូលមកដល់ក្នុងខេត្តតាកែវ។ កងទ័ពវៀតណាម បានបាញ់ផ្លោងកងទ័ពខ្មែរក្រហម ដែលបានធ្វើឲ្យកងទ័ពខ្មែរក្រហមរត់ទៅទិសខាងលិចសំដៅទៅរកតំបន់ភ្នំ។ ខ្ញុំឃើញកងទ័ពខ្មែរក្រហម ត្រូវគ្រាប់ផ្លោងនៅតាមផ្លូវ ហើយគ្នីគ្នារបស់គេនាំគ្នាសែងអ្នករបួសរត់ប្រសេចប្រសាច។ ខ្ញុំនិងក្រុមគ្រួសារ បានរត់ទៅទិសខាងកើតដូយពីក្រុមខ្មែរក្រហម។ យើងធ្វើយ៉ាងណារត់គេចកុំឲ្យជួបនឹងក្រុមខ្មែរក្រហម ព្រោះខ្លាចខ្មែរក្រហមសម្លាប់យើងចោល។ ខ្ញុំរត់សំដៅទៅប្រទេសវៀតណាមបម្រុងនឹងឆ្លងដែន ប៉ុន្តែខ្ញុំមិនអាចឆ្លងទៅប្រទេសវៀតណាមបានទេ ព្រោះម្តាយឪពុកខ្ញុំចាស់ជរាមិនអាចធ្វើដំណើរឆ្ងាយបាន។ ពេលដែលខ្មែរក្រហមរត់ទៅបាត់អស់ ខ្ញុំនិងក្រុមគ្រួសាររត់ត្រឡប់មកវិញ។ ក្រោយមក ខ្មែរក្រហមបានវិលត្រឡប់ចូលមកក្នុងភូមិវិញ នៅពេលដែលវៀតណាមដកកងទ័ព

ចេញលើកទី១ ហើយបានចោទប្រជាជនដែលរត់សំដៅទៅប្រទេសវៀតណាមថាជា ពួកក្បត់ៗ មិនយូរប៉ុន្មាន កងទ័ពវៀតណាម ចូលមកម្តងទៀត ហើយដេញបាញ់ខ្មែរក្រហមរត់រប៉ាត់រប៉ាយអស់ៗ ពេលនោះ ខ្ញុំនិងក្រុមគ្រួសារមិនបានរត់ទៅណាទៀតទេៗ យើងនាំគ្នារត់ចូលទៅក្នុងលេណដ្ឋាន ដើម្បីគេចចេញពីគ្រាប់ផ្លោងៗ នៅពេលដែលសភាពការណ៍បាញ់គ្នាស្ងប់ស្ងាត់ហើយ ខ្ញុំនិងក្រុមគ្រួសារក៏បានស៊ុះស៊ែងរកបងប្អូនដើម្បីជួបជុំគ្នាវិញ ប៉ុន្តែសមាជិកក្រុមគ្រួសាររបស់ខ្ញុំមួយចំនួនបានបាត់បង់ជីវិតៗ

បន្ទាប់ពីរបបខ្មែរក្រហមបានកន្លងផុត អស់រយៈពេល៥ឆ្នាំ ខ្ញុំនិងសាច់ញាតិបាននាំគ្នាទៅគាស់កកាយរកសាកសពប្តីរបស់ខ្ញុំៗ យើងមិនបានប្រទះឃើញអ្វីនោះទេនៅកន្លែងកប់សពប្តីរបស់ខ្ញុំនោះ ប៉ុន្តែយើងធុំក្លិនស្អុយដូចមានសាកសពរលួយៗ ខ្ញុំគិតថា សាកសពរបស់ប្តីខ្ញុំ អាចមានសត្វស៊ីអស់ទៅហើយៗ យើងយំខ្លាំងណាស់ពេលទៅគាស់កកាយរកសាកសពនោះ ព្រោះវាបានរំឭករឿងរ៉ាវគ្រប់យ៉ាងដែលកើតមានឡើងចំពោះយើងទាំងអស់គ្នាៗ ក្រោយមក នៅពេលដែលខ្ញុំដឹងច្បាស់អំពីទីតាំងសម្លាប់ប្តីរបស់ខ្ញុំ ខ្ញុំនិងក្រុមគ្រួសារ នាំគ្នាធ្វើបុណ្យឧទ្ទិកុសលជូនដល់គាត់ៗ



ជូ គីម ឡូន ទៅវត្តធ្វើបុណ្យឧទ្ទិលកុសលជូនដល់ប្តីរបស់គាត់ដែលត្រូវបានខ្មែរក្រហសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)ៗ (អ៊ុន សុដាវី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងឆ្នាំ២០០៨ ខ្ញុំបានដាក់ពាក្យបណ្តឹងមកកាន់តុលាការខ្មែរក្រហមតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាៗ ខ្ញុំដាក់ពាក្យបណ្តឹងនេះ ពីព្រោះខ្ញុំខឹងនឹងខ្មែរក្រហម ដែលធ្វើបាបខ្ញុំ, សម្លាប់កូន, ប្តី និងសាច់ញាតិរបស់ខ្ញុំៗ ខ្ញុំដាក់ពាក្យបណ្តឹងនេះ ដោយក្នុងចិត្តសង្ឃឹមថា តុលាការខ្មែរក្រហម នឹងស្វែងរកយុត្តិធម៌ និងផ្តល់ជាសំណងដល់ខ្ញុំដែរៗ ភាពឈឺចាប់ចំពោះអតីតកាលដ៏ខ្មៅងងឹតមួយនេះ បានជំរុញឲ្យខ្ញុំក្លាហានក្នុងការចូលរួមជាមួយនឹងដំណើរការរបស់តុលាការខ្មែរក្រហមដោយមិនរារែកឡើយៗ ទោះបីជាយ៉ាងណា ខ្ញុំនៅតែមិនទាន់អស់ចិត្តទៅនឹងលទ្ធផលនៃការកាត់ទោសរបស់តុលាការខ្មែរក្រហមចំពោះមេដឹកនាំខ្មែរក្រហមទាំងអស់នោះឡើយ ពីព្រោះទំហំនៃការបាត់បង់របស់ខ្ញុំគ្មានអ្វីអាចយកមកប្រៀបធៀបបានឡើយៗ នៅពេលដែលខ្ញុំចាប់ផ្តើមនិយាយអំពីរឿងរ៉ាវទាំងអស់នេះ វាហាក់បីដូចជារឿងរ៉ាវដែលទើបតែកើតមានឡើងថ្មីៗៗ ខ្ញុំបានចូលរួមផ្តល់សក្ខីកម្មនៅក្នុងតុលាការខ្មែរក្រហម និងបានចូលរួមជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយកិច្ចការទាំងអស់នេះ បានធ្វើឲ្យខ្ញុំធូរស្បើយនៅក្នុងចិត្តបានច្រើនណាស់ដែរៗ

មកទល់សព្វថ្ងៃនេះ សំឡេងស្នូរគ្រាប់កាំភ្លើងចំនួន៣គ្រាប់ដែលបានបាញ់សម្លាប់ប្តីរបស់ខ្ញុំ នៅតែលាន់ឮរំពងពេញក្នុងត្រចៀករបស់ខ្ញុំៗ រំឭកដល់ត្រង់ចំណុចនេះ ខ្ញុំតែងតែស្រក់ទឹកភ្នែកដោយមិនដឹងខ្លួន ព្រោះរឿងគ្រប់យ៉ាងបានកើតឡើងចំពោះខ្ញុំ ហាក់បីដូចជាការដាក់ទណ្ឌកម្មមួយដ៏ធ្ងន់ធ្ងរពេកៗ













# ការិយាល័យ ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨÷០០ ដល់ម៉ោង ១២÷០០ និងពេលរសៀលពីម៉ោង ២÷០០ ដល់ម៉ោង ៥÷០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល៖

truthchenda.s@dccam.org

សូមអរគុណ!











# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

**ដារ៉ាវដ្ឋ មេត្តា**

(តពីលេខមុន)

**២៦៩.** *តាមប្រពៃណីទំនៀមទម្លាប់ ថ្ងៃរៀបអាពាហ៍ពិពាហ៍ត្រូវបានប្រារព្ធឡើងនៅក្នុងពិធីដ៏អធិកអធម។ ពិធីរៀបអាពាហ៍ពិពាហ៍នេះត្រូវបានចាត់ទុកថា ជាការងាររបស់សហគមន៍ដោយឪពុកម្តាយ បងប្អូនប្រុសស្រី សាច់ញាតិ អ្នកជិតខាង អ្នកភូមិ ព្រះសង្ឃ និងអាជ្ញាធរមូលដ្ឋាន (ដូចជាមេភូមិជាដើម) ត្រូវចូលរួមនៅក្នុងពិធីនោះ។ សហព័ន្ធបានត្រូវ «អនុញ្ញាត» «ឲ្យពរជ័យ» ឬផ្សំផ្គុំឡើងដោយសហគមន៍ និងមានការចូលរួមពីសហគមន៍។*

**២៧០.** *មើតាមប្រវត្តិសាស្ត្រ ពិធីរៀបអាពាហ៍ពិពាហ៍ត្រូវបានធ្វើឡើងរវាងពីមួយថ្ងៃទៅប្រាំពីរថ្ងៃ ជាទូទៅធ្វើឡើងក្បែរផ្ទះកូនក្រមុំ ឬនៅទីតាំងមួយនៅកណ្តាលភូមិ អាចជាទីវត្តអារាម។ នៅក្នុងពិធីទាំងមូល ភ្ញៀវការត្រូវបានប្រគុំកំដរ/នាំមុខក្បួនដង្ហែរកូនកំលោះ កូនក្រមុំដែលតុបតែងកាយដោយស្លៀកសម្លៀកបំពាក់ពណ៌ស្រស់ឆើតឆាយ និងគ្រងដោយសម្លៀកបំពាក់ធ្វើពីសំឡីកប្បាសឬ សូត្រ មានក្បូរក្បាច់រចនានិងលម្អដោយទឹកមាស។ ភ្ញៀវកិត្តិយសត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកម្មវិធីជប់លៀង និងការសម្តែងសិល្បៈយ៉ាងសប្បាយរីករាយ ដែលជានិមិត្តរូបនៃការរៀបអាពាហ៍ពិពាហ៍ ហើយប្រពៃណីផ្សេងៗ ដូចជា ពិធីកាត់សក់កូនកំលោះកូនក្រមុំ ពិធីសែនចងដៃ និងពិធីពិសារស្លានិមិត្តរូប ត្រូវបានរៀបចំធ្វើឡើងនៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍។*

**២៧១.** *ព្រះសង្ឃមានតួនាទីយ៉ាងសំខាន់នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ដោយមានការសូត្រមន្ត វេរទិសដល់បុព្វការីជន បណ្តេញឧបទ្រពចង្រៃ ហើយផ្តល់ឱវាទដល់គូស្វាមីភរិយាថ្មី។*

**២៧២.** *បន្ទាប់ពីពិធីចប់រួចរាល់ គូស្រករត្រឡប់ទៅសម្រាកនៅផ្ទះរបស់ឪពុកម្តាយម្ខាង។ ការពិគ្រោះអំពីការផ្សំដំណេកឬការរួមដំណេក ត្រូវបានចាត់ទុកថា ជាពាក្យតំណម ហើយគូស្រករដែលទើបតែរៀបការរួច កម្រទទួលបានការណែនាំអំពីកិច្ចដែលត្រូវប្រព្រឹត្តនៅយប់ផ្សំដំណេកនោះណាស់។*

**២៧៣.** *ភ័ស្តុតាងនៅក្នុងសវនការបានបង្ហាញថា មានការដាក់កំហិតទៅលើពិធីរៀបអាពាហ៍ពិពាហ៍នៅក្នុងតំបន់ «រំដោះ» ដោយខ្មែរក្រហម នៅចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥។ នៅចន្លោះពេលនោះ រណសិរ្សរួបរួមជាតិកម្ពុជាបានផ្សព្វផ្សាយកម្មវិធីនយោបាយស្តីពីស្មើភាពគ្នារវាងភេទទាំងពីរ ហើយព្យាយាម «លុបបំបាត់ប្រពៃណីអន់ថយដែលរើសអើងទៅលើស្ត្រី » ដោយជំរុញឲ្យស្ត្រី «អភិវឌ្ឍអាជីពការងារ» ដោយផ្តោតជាសំខាន់ទៅលើការបណ្តុះបណ្តាលនិងការអប់រំស្ត្រីនៅគ្រប់កម្រិតទាំងអស់ «ដើម្បីជំរុញស្ត្រីអាចចូលរួមពេញលេញនៅក្នុងការតស៊ូរួម»។ ទេពន្ធភាពត្រូវបានលុបបំបាត់ត្រឹមតែពាក្យសម្តី»។ ពេជ្រ ដឹម ដែលជាលេខាស្រុកត្រាំកក់បានមកផ្តល់សក្ខីកម្មថា « មានការរៀបការតិចតួចប៉ុណ្ណោះ» នៅក្នុងស្រុកនោះ នៅចន្លោះឆ្នាំ១៩៧១ដល់១៩៧៣។ ពិធីរៀបអាពាហ៍ពិពាហ៍ទាំងនោះ ត្រូវបានប្រារព្ធឡើងដោយលួចលាក់ដែល ពេជ្រ ដឹម បានពន្យល់ថាពិធីអធឹកអធម «ប៉ះពាល់ដល់ស្មារតី» យុទ្ធជនដែលអាចរារាំងខ្មែរក្រហមក្នុងការ«បញ្ចុះបញ្ចូលប្រជាជនឲ្យទៅសមរភូមិ» បាន។ មានភ័ស្តុតាងផងដែរថាពិធីរៀបអាពាហ៍ពិពាហ៍ត្រូវបានរៀបចំឡើងដោយ «អង្គការ» តាំងពីមុនឆ្នាំ១៩៧៥ មកម្ល៉េះ។*

## ៤. ផិដ្ឋភាពទូទៅ៖ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩

**២៧៤.** *អង្គជំនុំជម្រះបានកម្រិតសំណុំរឿង០០២/០២ និងបានទទួលអង្គហេតុចោទប្រកាន់ ដូចបានរៀបរាប់នៅក្នុងដីការដំណោះស្រាយ និងបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលទាក់ទងនឹងសហករណ៍ និងការដ្ឋានការងារ (ដោយកម្រិតត្រឹមសហករណ៍ត្រាំកក់ ការដ្ឋានការងារទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង) មន្ទីរសន្តិសុខនិងទីកន្លែងសម្លាប់មនុស្ស (ដោយកម្រិតត្រឹមមន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខត្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល) ការប្រព្រឹត្តចំពោះក្រុមគោលដៅ (ដោយកម្រិតត្រឹមត្រូវ (១) ការប្រព្រឹត្តចំពោះក្រុមសាសនិកនៅសហករណ៍ត្រាំកក់ (២) ការប្រព្រឹត្តចំពោះជនជាតិចាម ក្នុងអំឡុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ ការអនុវត្តដោយមិនរាប់បញ្ចូលមន្ទីរសន្តិសុខក្រូចឆ្មារ (៣) ការប្រព្រឹត្តចំពោះជនជាតិវៀតណាម ការអនុវត្តដោយមិនរាប់បញ្ចូលនូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកងទ័ពបដិវត្តន៍កម្ពុជា នៅលើទឹកដីវៀតណាមនិង (៤) ការប្រព្រឹត្តចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (រួមមានអ្នករដ្ឋការ និងទាហាន) និងក្រុមគ្រួសាររបស់ពួកគេ ការអនុវត្តត្រឹមតែសហករណ៍ត្រាំកក់ ការដ្ឋានការងារទំនប់ ១មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ការដ្ឋានការងារទំនប់ ១មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់) និងបទបញ្ញត្តិពីការរៀបអាពាហ៍ពិពាហរណ៍ (នៅទូទាំងប្រទេស)។*

**២៧៥.** *អង្គជំនុំជម្រះកត់សម្គាល់ថា ផ្នែកនេះមានគោលបំណងមានកម្រិត គឺដើម្បីវិភាគថា តើលក្ខខណ្ឌទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩*



*ពិធីរៀបការរបស់កម្មាភិបាលខ្មែរក្រហម។*

*ត្រូវបានរកឃើញដែរឬទេ។ អង្គជំនុំជម្រះលើកឡើងចំណុចនេះនៅក្នុងសាលក្រមនាពេលនេះតែម្តង ព្រោះការពិចារណាទាំងនេះមានផលវិបាកទៅលើឧក្រិដ្ឋកម្មប្រឆាំងនិងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៥ ដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង០០២/០២ និងបានពិភាក្សានៅក្នុងផ្នែកដែលនៅសេសសល់ក្នុងសាលក្រមខាងក្រោម។ យោងតាមដីកាដំណោះស្រាយ ឧក្រិដ្ឋកម្មនានាពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ ប្រតិបត្តិការនៃសហករណ៍ និងការដ្ឋានការងារ បណ្តាញមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស ការកំណត់គោលដៅទៅលើក្រុមជាក់លាក់ និងបទបញ្ញត្តិពីការរៀបអាពាហ៍ពិពាហ៍ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហេតុដូច្នេះ ការចោទប្រកាន់នេះគឺជាផ្នែកមួយនៃការ*



*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*វាយប្រហារជាទូទៅ និងជាប្រព័ន្ធប្រឆាំងនិងប្រជាជនស៊ីវិល ដែលបានប្រព្រឹត្តឡើងនៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ និងគ្រប់តំបន់ទាំងអស់ក្នុងប្រទេសកម្ពុជា។ លើសពីនេះទៀត ដីកាដំណោះស្រាយចាត់ទុកឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខអូរកន្សែងដែលត្រូវបានប្រព្រឹត្តចំពោះអ្នកជាប់ឃុំជនជាតិវៀតណាមថា ជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅក្នុងអំឡុងពេល និងជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនិងជម្លោះប្រដាប់អាវុធជាមួយនឹងប្រទេសវៀតណាម។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ចាំបាច់ត្រូវតែដោះស្រាយបញ្ហាទាំងពីរដោយសង្ខេប ទាំងលើអង្គហេតុដែលត្រូវបានចោទប្រកាន់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានប្រកាន់ទាំងឡាយ ទាក់ទងនឹងបរិបទធំធេងជាងនេះរួមទាំងអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ដែលនាំឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។*

## ៤.១ ទិដ្ឋភាពអង្គហេតុទូទៅនៃវិសាលភាពពេលវេលាក្នុងសំណុំរឿង០០២/០២ (រួមទាំងលក្ខណៈនៃជម្លោះប្រដាប់អាវុធ)

**២៧៦.** *អង្គជំនុំជម្រះរកឃើញថា នៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី០៦ ខែ មករា ឆ្នាំ១៩៧៩ ចំពោះយុត្តាធិការពេលវេលាដែលជាបញ្ហាចោទនៅក្នុងសំណុំរឿង០០២/០២ ប.ក.ក. បានពង្រឹងប្រមូលផ្តុំអំណាចលើកម្ពុជាប្រជាធិបតេយ្យ និងប្រជាជននៃរបបនេះតាមរយៈការលុបចោលប្រព័ន្ធតុលាការ ស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័នរដ្ឋផ្សេងៗទៀតនៅក្នុងរបបមុន ហើយនឹងការកសាងស្ថាប័ននិងរចនាសម្ព័ន្ធក្នុងពេលដំណាលគ្នាក្រោមការគ្រប់គ្រងផ្តាច់មុខរបស់ ប.ក.ក. ។ ផ្អែកតាមផែនការនិងគោលនយោបាយបក្សដែលមានគោលបំណងកសាងសង្គមនិយមរបស់ខ្លួននោះ ទើបជាដោគវាសនាប្រជាជនកម្ពុជាត្រូវស្ថិតនៅក្នុងកណ្តាប់ដៃនៃ ប.ក.ក. ពោលគឺពួលគេ ត្រូវបានផ្លាស់ទីលំនៅដោយបង្ខំ តម្រូវឲ្យធ្វើការងារ និងកំណត់ឲ្យរស់នៅទៅតាមគោលបំណងរបស់ ប.ក.ក.។ ជាពិសេសក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិប-តេយ្យ ប.ក.ក. បានផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីខេត្តក្រុង និងទីប្រជុំជននានានៅទូទាំងប្រទេសកម្ពុជាទៅកាន់តំបន់ជនបទ និងពីទីជនបទមួយទៅកាន់ជនបទមួយ ក្នុងគោលបំណងដើម្បីធ្វើឲ្យខ្មាំងចុះខ្សោយ ទាំងខ្មាំងផ្ទៃក្នុងនិងខ្មាំងខាងក្រៅ និងដើម្បីទប់ស្កាត់កុំឲ្យមានការងើបបះបោរ ដើម្បីលុបបំបាត់ និងលត់ដំពួកវណ្ណៈនាយទុន និងសក្តិភូមិ និងដើម្បីកសាងពង្រីកសហករណ៍នានា។*

**២៧៧.** *អង្គជំនុំជម្រះជឿជាក់ថានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប.ក.ក. បានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ក្នុងចំនួនយ៉ាងច្រើនសន្ធឹកសន្ធាប់។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និង បន្ទាប់ពីកាលបរិច្ឆេទនេះមកប្រជាជនក៏ត្រូវបានគេបម្លាស់ទីរួមខេត្តនានា នៅទូទាំង*

ប្រទេសកម្ពុជារួមមានខេត្តកំពង់ស្ពឺ តាកែវ កំពត ក្រុងព្រះសីហនុ (ពីមុនហៅថា ក្រុងកំពង់សោម) កំពង់ធំ ប៉ៃលិន កំពង់ចាម កំពង់ឆ្នាំង សៀមរាប ប៉ោយប៉ែត បាត់ដំបង និង ពោធិ៍សាត់។

**២៧៨.** បន្ថែមពីនេះទៀត អង្គជំនុំជម្រះជឿជាក់ថាចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ និងបន្តរហូតដល់ឆ្នាំ១៩៧៧ ប្រជាជនស៊ីវិលមួយចំនួនធំត្រូវបានគេផ្លាស់ទីដោយបង្ខំ ទៅកាន់ខេត្តបាត់ដំបងនិងខេត្តពោធិ៍សាត់ ចំណែកឯប្រជាជនផ្សេងទៀតត្រូវបានផ្លាស់ទីលំនៅដោយបង្ខំ នៅក្នុងតំបន់ផ្សេងៗ អាស្រ័យលើត្រូវការកម្លាំងពលកម្មតាមរដូវនិង ដើម្បីឈោងទៅសម្រេចការតស៊ូវណ្ណៈ។ អង្គជំនុំជម្រះកត់សម្គាល់ថា ដីកាដំណោះស្រាយក៏បានចោទប្រកាន់ដែរថា ការផ្លាស់ទីលំនៅដោយបង្ខំបានបន្តនៅគ្រប់ពេលក្នុងឆ្នាំ១៩៧៨។ ទោះបីជាយ៉ាងណា អង្គជំនុំជម្រះមិនបានដាក់បញ្ចូលការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី៣ ទៅក្នុងសំណុំរឿង ០០២/០២ទេ និងបានបញ្ចប់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុទាំងអស់ដូចបានលើកឡើងនៅក្នុងដីកាដំណោះស្រាយដែលមិនត្រូវបានបញ្ចូលនៅក្នុងសំណុំរឿង០០២/០១ឬសំណុំរឿង០០២/០២។

**២៧៩.** អង្គជំនុំជម្រះរកឃើញថា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ មិនមានទីផ្សារ រូបិយប័ណ្ណត្រូវបានបោះបង់ចោល កម្មសិទ្ធិឯកជនត្រូវបានបំបាត់ ដោយដាក់ជំនួសវិញនូវសហករណ៍និងការដ្ឋានធ្វើការឲ្យដំណើរការទៅទូទាំងប្រទេស ដើម្បីគ្រប់គ្រងប្រជាជននិងធ្វើការតស៊ូវណ្ណៈ។ ប្រជាជនត្រូវបានគេបង្ខំឲ្យរស់នៅ និងធ្វើការជាសមូហភាពនៅតាមសហករណ៍ និងការដ្ឋានការងារ ដែលនៅទីនោះពួកគេទទួលរងការធ្វើបាបលក្ខខណ្ឌធ្ងន់ធ្ងរ ការបាត់ខ្លួននិងការកាប់សម្លាប់។ វិធីសាស្ត្រសមូហភាពរបស់ ប.ក.ក. ដែលមានបំណងធ្វើការតស៊ូវណ្ណៈ ក៏ត្រូវបានបញ្ចូលទាំងបញ្ហាគ្រួសារដូចជា ការរៀបអាពាហ៍ពិពាហ៍ផងដែរ ដោយសារ ប.ក.ក. ចាត់ទុកថា វិធីសាស្ត្រនេះមានសារសំខាន់ក្នុងការកសាងសង្គមថ្មីមួយ ឲ្យស្របតាមស្តង់ដាមនោគមន៍វិជ្ជានៃបដិវត្តន៍សង្គមនិយមរបស់ខ្លួន។ ដូចបានពន្យល់នៅក្នុងផ្នែកផ្សេងទៀតនៃសាលក្រមនេះ គោលនយោបាយបក្ស ក្នុងការកំណត់បទបញ្ញត្តិគ្រប់គ្រងការកសាងគ្រួសារ និង អាពាហ៍ពិពាហ៍ក្នុងគោលបំណងគ្រប់គ្រងប្រជាជន និងបង្កើតចំនួនប្រជាជននៃកម្ពុជាប្រជាធិបតេយ្យ បានបណ្តាលឲ្យមានជាប្រព័ន្ធនៅទូទាំងប្រទេស និងអនុវត្តដោយបណ្តាញរដ្ឋបាលទាំងមូលរបស់ ប.ក.ក ពោលគឺ លេខាភូមិភាគ តំបន់ស្រុក និងមូលដ្ឋាន កម្មាភិបាល ប.ក.ក. កងទ័ពបដិវត្តកម្ពុជា ដែលពាក់ព័ន្ធ និងអាពាហ៍-ពិពាហ៍ដោយបង្ខំនិងការរំលោភផ្លូវភេទជាទូទៅ។

**២៨០.** ទន្ទឹមនឹងនេះ យោងតាមដីកាដំដោះស្រាយ ក្នុងចន្លោះពីខែមេសា ឆ្នាំ១៩៧៥ និងយ៉ាងហោចណាស់ដល់ថ្ងៃទី០៧ មករា ឆ្នាំ១៩៧៩ នៅពេលដែលកងទ័ពបដិវត្តន៍កម្ពុជាត្រូវបានបង្ខំឲ្យភៀសខ្លួនចេញពីទីក្រុងភ្នំពេញ ជម្លោះប្រដាប់អាវុធបានកើតឡើងរវាងកម្ពុជាប្រជាធិ-បតេយ្យ និងសាធារណរដ្ឋសង្គមវៀតណាម(ស.ស.វ ឬ វៀតណាម)។ ដីកាដំណោះស្រាយបញ្ជាក់ថា ទោះបីជាអត្ថិភាពនៃជម្លោះប្រដាប់អាវុធមិនត្រូវបានទទួលស្គាល់ជាផ្លូវការរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ថាជាថ្ងៃដែលកម្ពុជាប្រជាធិបតេយ្យបានផ្តាច់ទំនាក់ទំនងការទូតជាមួយ ស.ស.វ ក៏ដោយប៉ុន្តែរដ្ឋទាំងពីរបានវាយប្រយុទ្ធទៅវិញទៅមក នៅក្នុងអំឡុងពេញមួយរបបកម្ពុជាប្រជា-ធិបតេយ្យ។ ដីកាដំណោះស្រាយបង្ហាញបន្ថែមទៀតថា ទោះបីជាការប្រយុទ្ធគ្នាត្រូវបានផ្អាកជាពិសេស នៅមុនឆ្នាំ១៩៧៧ ក៏ដោយក៏មិនដែលមានពេលណាមួយដែលរដ្ឋទាំងពីរអាចឈានទៅរកការចុះសន្ធិសញ្ញាសន្តិភាពជាទូទៅណាមួយរវាងគ្នានិងគ្នា ដើម្បីបញ្ចប់ជម្លោះប្រដាប់អាវុធអន្តរជាតិនេះបានដែរ។

**២៨១.** បញ្ហាអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិរវាងកម្ពុជាប្រជាធិបតយ្យ និងប្រទេសវៀតណាម ចាប់ពីខែឧសភា ឆ្នាំ១៩៧៥ រហូតដល់យ៉ាងហោចណាស់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ មិនត្រូវបានភាគីណាមួយជំទាស់នោះទេ។

**២៨២.** ការប្រយុទ្ធគ្នារវាងកងទ័ពកម្ពុជាប្រជា-ធិបតេយ្យនិងកងទ័ពវៀតណាម នៅដែនទឹកជុំវិញតំបន់កោះដែលមានជម្លោះរវាងកម្ពុជា និងវៀតណាម ព្រមទាំង

ការប៉ះទង្គិចនៅកន្លែងជាច្រើនតាមព្រំដែនត្រូវបានរាយការណ៍ បានកើតឡើងភ្លាមៗក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ទោះជាយ៉ាងណាក្តី សក្ខីកម្មដែលអង្គជំនុំជម្រះបានស្តាប់ បង្ហាញពីការលើកឡើងផ្ទុយគ្នាពាក់ព័ន្ធនិងការវាយប្រយុទ្ធគ្នាទាំងនេះនៅក្នុងអំឡុងត្រីមាសទីពីរនៃឆ្នាំ១៩៧៥។ ប្រភពព័ត៌មានផ្សព្វផ្សាយជាសាធារណៈរបស់វៀតណាមលើកឡើងថា កងទ័ពកម្ពុជាប្រជាធិបតេយ្យបានវាយកាន់កាប់កោះនានា ដែលជាប្រវត្តិសាស្ត្រត្រូវបានស្គាល់ថាជា កោះត្រល់ ដែលបច្ចុប្បន្នមានឈ្មោះថាកោះ Phu Quoc និងកោះក្រចកសេះ ដែលបច្ចុប្បន្នមានឈ្មោះថាកោះ Tho Chu នៅក្នុងប្រតិបត្តិការនោះ ហើយអះអាងថា កងទ័ពកម្ពុជាប្រជាធិបតេយ្យក៏បានចូលវាយលុកទៅក្នុងប្រទេសវៀតណាមនៅតំបន់ព្រំដែនពី ហាទៀង ទៅ តាយនិញ។ បន្ទាប់មក មានការចោទប្រកាន់ថា ប្រទេសវៀតណាម បានសងសឹកដោយវាយដណ្តើមយកកោះ Phu Quoc និងកោះ Tho Chu ទៅវិញ ចាប់ខ្លួនអ្នកទោសប្រហែល ៣០០នាក់ ហើយចុងក្រោយវាយកាន់កាប់បានកោះពូលូវៃរបស់កោះកម្ពុជា នៅដើមឆ្នាំខែមិថុនា ឆ្នាំ១៩៧៥។ ទោះបីជាលំដាប់លំដោយព្រឹត្តិការណ៍ទាំងនេះមិនត្រូវបានគាំទ្រដោយសាក្សីផ្ទាល់ដែលអង្គប្រជុំជម្រះនេះបានស្តាប់សក្ខីកម្មឬឯកសារផ្ទៃក្នុងសម័យកម្ពុជាប្រជាធិបតេយ្យក៏ដោយ ប៉ុន្តែមានការយល់ស្របពីបញ្ញវន្តជាច្រើនរូប។ ផ្ទុយទៅវិញប្រភពព័ត៌មានផ្សព្វផ្សាយជាសាធារណៈរបស់កម្ពុជាប្រជាធិបតេយ្យបានលើកឡើងថា វៀតណាមបានវាយប្រយុទ្ធទៅលើកោះពូលូវៃភ្លាមៗ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ឬ ក្នុងខែឧសភា ឆ្នាំ១៩៧៥ ដោយបដិសេធថា កងទ័ពកម្ពុជាប្រជាធិបតេយ្យមិនបានវាយកាន់កាប់កោះ Phu Quoc និងកោះ Tho Chu ជាមុននោះទេ ហើយបានចោទប្រកាន់វៀតណាមថា បានវាយសម្រុកទៅក្នុងខេត្តមណ្ឌលគិរី និងខេត្តរតនគិរី របស់កម្ពុជា នៅខែឧសភាឆ្នាំ១៩៧៥។ ទោះបីជាអង្គជំនុំជម្រះប្រុងប្រយ័ត្ននៅក្នុងការថ្លឹងថ្លែងទម្ងន់ភស្តុតាងនៃប្រភពឯកសារឃោសនារបស់របបកម្ពុជាប្រជាធិបតេយ្យ និងវៀតណាមយ៉ាងណាក៏ដោយ ប៉ុន្តែអង្គជំនុំជម្រះជឿជាក់ថា ផ្អែកលើចំណុចរួមនៃការរៀបរាប់ខុសៗគ្នា ជម្លោះប្រដាប់អាវុធបានចាប់ផ្តើមនៅលើដែនទឹកជុំវិញតំបន់ កោះដែលមានជម្លោះរវាងកម្ពុជានិងវៀតណាម ព្រមទាំងនៅកន្លែងជាច្រើនទៀតតាមបណ្តោយព្រំដែន ដែលបានកើតឡើងយ៉ាងឆាប់រហ័សនៅក្នុងខែឧសភា ឆ្នាំ១៩៧៥ ហើយកងទ័ពវៀតណាម បានកាន់កាប់កោះពូលូវៃ យ៉ាងយូរបំផុតរហូតដល់ដើមខែមិថុនា ឆ្នាំ១៩៧៥។ ការកាន់កាប់កោះពូលូវៃក៏ត្រូវបានគាំទ្រដោយអត្ថបទសារព័ត៌មានសម័យកាលនោះ ជាមួយនឹងសក្ខីកម្មរបស់ ប៉ាក សុខ ដែលបានលើកឡើងថា វៀតណាម បានចូលមកកាន់កាប់កោះពូលូវៃ នៅខែមិថុនា ឆ្នាំ១៩៧៥។

**២៨៣.** នៅខែមិថុនា ឆ្នាំ១៩៧៥ កម្ពុជាប្រជាធិបតេយ្យបានបញ្ជូនប្រតិភូមួយក្រុមរួមមាន ប៉ុល ពត និង នួន ជា ទៅកាន់ទីក្រុងហាណូយ ដើម្បីពិភាក្សាគ្នាអំពីជម្លោះនៅតាមព្រំដែនជាមួយមេដឹកនាំវៀតណាម ឡេ វ៉ាន់លិញ ប៉ុន្តែការពិភាក្សានេះមិនទទួលបានលទ្ធផលនោះឡើយ។ ក្រោយមក ឡេ យន់ ដែលជាអគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម ក៏បានដឹកនាំប្រតិភូមួយក្រុមមកបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជា នៅដើមខែសីហា ឆ្នាំ១៩៧៥។ បន្ទាប់មក វៀតណាមបានដកកងទ័ពរបស់ខ្លួនចេញពីកោះពូលូវៃ នៅចុងខែសីហា។ ពីថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ១៩៧៥ ខៀវ សំផន និង សម្តេច សីហនុ បានធ្វើដំណើរទៅវៀតណាមខាងជើងដើម្បីចូលរួមអបអរសាទរខួបលើកទី៣០ នៃការចាប់ផ្តើមចលនាទាមទារឯករាជ្យរបស់វៀតណាម។ ទោះបីជាយ៉ាងណាជម្លោះជុំវិញតំបន់កោះនៅតែបន្តយ៉ាងហោចណាស់រហូតដល់ដើមឆ្នាំ១៩៧៦។

**២៨៤.** ចំពោះបញ្ហាដែនគោក ព្រឹត្តិការណ៍នានានៅតាមព្រំដែនបានកើតឡើងនៅក្នុងអំឡុងពាក់កណ្តាលឆ្នាំ១៩៧៥។ នៅដើមឆ្នាំ១៩៧៦ មានកិច្ចខិតខំប្រឹងប្រែងដោះស្រាយបញ្ហាទាំងនេះ តាមរយៈការចងចាំជាច្រើនលើករវាងប្រតិភូកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម ក្នុងគោលបំណងរៀបចំកិច្ចប្រជុំត្រៀមសម្រាប់ជំនួបកំពូលនៅខែមិថុនា ឆ្នាំ១៩៧៦។ ណៃ សារ៉ាន់ ហៅ យ៉ា ដែលជាលេខាភូមិភាគឦសាន បានរាយការណ៍ជូនគណៈ

កម្មាធិការអចិន្ត្រៃយ៍ចំនួនពីរលើក អំពីការចងចាំជាមួយវៀតណាមអំពីបញ្ហាទាំងនេះ។ ជាក់ស្តែង «គណៈទាក់ទងព្រំដែន» ត្រូវបានលើកឡើង ក៏ប៉ុន្តែមិនបានទទួលមតិឯកច្ឆ័ន្ទទេ ហើយជំនួបនៅខែមិថុនា ក៏មិនអាចប្រព្រឹត្តទៅបានដែរ។ ទោះបីជាការប្រយុទ្ធគ្នាត្រូវបានផ្អាកមួយរយៈ ក្នុងឆ្នាំ១៩៧៦ក្តី ប៉ុន្តែការប៉ះទង្គិចនៅតាមព្រំដែនបានបន្តកើតឡើងនៅក្នុងឆ្នាំដដែលនោះ រហូតដល់ឆ្នាំ១៩៧៧។

**២៨៥.** អ្នកជំនាញជាច្រើនបានលើកឡើងថា ក្នុងចំណោមការវាយប្រហារទ្រង់ទ្រាយធំចំនួនពីរលើក កងទ័ពកម្ពុជាប្រជាធិបតេយ្យបានវាយប្រហារចូលក្នុងប្រទេសវៀតណាមជាលើកដំបូងនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧។ ការលើកឡើងនេះវាមានភាពស៊ីសង្វាក់គ្នាជាមួយនឹងប្រភពព័ត៌មានផ្សព្វផ្សាយជាសាធារណៈរបស់វៀតណាម ព្រមទាំងកិច្ចសម្ភាសន៍របស់អ្នកជំនាញ Ben KIFRNAN ជាមួយលោក ហេង សំរិន ជា ស៊ីម និង អ៊ុក ប៊ុនឈឿន។ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៧ កងទ័ពកម្ពុជាប្រជាធិបតេយ្យបានវាយប្រហារក្នុងទ្រង់ទ្រាយធំជាលើកទីពីរ ចូលក្នុងប្រទេសវៀតណាម ហើយការលើកឡើងនេះត្រូវបានអះអាងដូចគ្នាដោយអ្នកជំនាញ ហើយអំណះអំណាង វាស៊ីសង្វាក់គ្នាទៅនឹងប្រភពព័ត៌មានដែលផ្សព្វផ្សាយជាសាធារណៈរបស់ប្រទេសវៀតណាម និងកិច្ចសម្ភាសន៍របស់ Ben KERNAN ផងដែរ។ ការវាយ-តម្លៃលើភាពត្រឹមត្រូវ និងភាពធ្ងន់ធ្ងរនៃអំពើឈ្លានពានដែលបានរៀបរាប់នេះមិនអាចធ្វើទៅបាននោះឡើយ ដោយសារមិនមានប្រភពព័ត៌មានដែលមានតម្លាភាពនិងឯករាជ្យ។ ភស្តុតាងពាក់ព័ន្ធនឹងហេតុការណ៍នៃការវាយប្រយុទ្ធគ្នា ជារឿយៗ គឺផ្អែកលើការសិក្សារបស់អ្នកជំនាញនិងបញ្ញវន្ត ហើយពេលខ្លះទៀត ការសិក្សាបែបនេះត្រូវចាត់ទុកថាជាភស្តុតាងចចាមអារ៉ាម។ អង្គជំនុំជម្រះមិនអាចរកឃើញឯកសារផ្ទៃក្នុងរបស់កម្ពុជាប្រជា-ធិបតេយ្យ ជាពិសេស ឯកសារផ្នែកយោធាដែលអាចបញ្ជាក់ថា ហេតុការណ៍នៃការវាយប្រហារទ្រង់ទ្រាយធំចូលក្នុងប្រទេសវៀតណាម បានកើតឡើងនៅក្នុងខែមេសា ឬ ខែកញ្ញាឆ្នាំ១៩៧៧នោះទេ។ សាក្សីផ្សេងៗទៀតដែរអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស. បានស្តាប់ចម្លើយ បានលើកឡើងថា ពួកគេបានចូលរួមក្នុងការវាយប្រហារចូលក្នុងទឹកដីវៀតណាម។ ការវាយប្រយុទ្ធគ្នាទាំងនេះជានិច្ចកាលមិនមានភាពច្បាស់លាស់នោះទេ ប៉ុន្តែយ៉ាងហោចណាស់ ការវាយប្រយុទ្ធគ្នាមួយផ្នែកទំនងជាបានកើតឡើងនៅក្នុងអំឡុងឆមាសទីពីរនៃឆ្នាំ១៩៧៨។

**២៨៦.** ទាក់ទិននឹងការវាយប្រហារទ្រង់ទ្រាយធំនៅក្នុងខែមេសា និងខែកញ្ញា ឆ្នាំ១៩៧៧ អង្គជំនុំជម្រះក៏បានពិចារណាទៅលើទូរលេខមួយចំនួនដែល ឈាន ឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំទីក្រុង ហាណូយ បានផ្ញើជូនមជ្ឈិមបក្ស រួមមាន ប៉ុល ពត , នួន ជា, អៀង សារី, វន វ៉េត និង សុន សេន ដែរ។ ទូរលេខទាំងនេះរាយការណ៍ថា វៀតណាមបានរិះគន់យ៉ាងខ្លាំងមកលើសកម្មភាពឈ្លានរបស់កងកម្លាំងប្រដាប់អាវុធកម្ពុជាប្រជាធិបតេយ្យនៅលើទឹកដីវៀតណាម។ ការរិះគន់ក្នុងលិខិតផ្លូវការនេះ ត្រូវបានរាយការណ៍ដោយកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យមិនមែនសម្រាប់ចែកចាយឲ្យសាធារណៈជនបានដឹងនោះទេ។ ហេតុដូច្នេះ ពុំមានហេតុផលដែលអាចជឿជាក់បានថា ហេតុការណ៍ទាំងនេះត្រូវបានរៀបរាប់ក្នុងគោលបំណងឃោសនានោះឡើយ។ ដោយហេតុថា ទូរលេខមួយចំនួនបានរាយការណ៍ជាផ្លូវការតែអំពីហេតុការណ៍ដែលបានកើតឡើងនិងមិនមានបញ្ចូលព័ត៌មានចចាមអារ៉ាមនោះហេតុដូច្នេះ បើទោះបីជាហេតុការណ៍ទាំងនោះមានលក្ខណៈធ្ងន់ធ្ងរ តែមិនត្រូវបានរៀបរាប់ក្នុងឯកសារប្រើប្រាស់ការឃោសនានោះឡើង។

**២៨៧.** អង្គជំនុំជម្រះជឿជាក់ថា ភាគីជម្លោះទាំងពីរបានវាយលុកចូលទៅក្នុងទឹកដីទៅវិញទៅមកប្រមាណជាពីរបីលើក ប៉ុន្តែភស្តុតាងមិនបានបង្ហាញឲ្យហួសពីវិមតិសង្ស័យ ដែលថាកម្ពុជាប្រជាធិបតេយ្យបានវាយលុកចូលក្នុងទឹកដី ស.ស.វ. ក្នុងទ្រង់ទ្រាយធំនៅក្នុងខែមេសា និងខែកញ្ញា ឆ្នាំ១៩៧៧ ដូចដែលបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍ផ្លូវការជាសាធារណៈរបស់អាជ្ញាធរវៀតណាមនោះទេ។ ពាក់ព័ន្ធនិងចំណុចនេះ អង្គជំនុំជម្រះកត់សម្គាល់ថា ការចោទប្រកាន់គ្នាទៅវិញទៅមកលើបញ្ហាថា តើភាគីណាមួយបានឈ្លានពានចូលក្នុងទឹកដីភាគីណា

មួយមុននោះ (មុនដំបូងនិង/ឬពេលណានោះ) គឺមានលក្ខណៈស្រដៀងជាមួយនឹងបញ្ហាចម្រូងចម្រាសដែលធ្វើឲ្យលំដាប់លំដោយព្រឹត្តិការណ៍ដែលបានកើតឡើងជុំវិញជម្លោះដែនកោះ មិនមានភាពច្បាស់លាស់នៅក្នុងរយៈពេលប៉ុន្មានខែ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ នេះគឺជាបញ្ហាធម្មតាដែលបានកើតឡើងរវាងកម្ពុជាប្រជាធិបតេយ្យ និងប្រទេសវៀតណាម ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

**២៨៨**. នៅក្នុងកាលៈទេសៈណាក៏ដោយ ការពិភាក្សាអំពីហេតុការណ៍វាយប្រយុទ្ធជាក់លាក់ទាំងនេះអាចជាប់ពាក់ព័ន្ធនឹងការយល់ដឹងអំពីវិសាលភាពនៃប្រតិបត្តិការយោធា ដែលភាគីទាំងពីរបានធ្វើ និងថាតើការប្រទូសរ៉ាយបានកើតឡើងជាក់ស្តែងដល់កម្រិតណា ហើយការពិភាក្សាទាំងនេះក៏មានប្រយោជន៍ផងដែរ ដល់សេចក្តីសន្និដ្ឋានទាក់ទងនឹងអត្ថិភាពនៃជម្លោះប្រដាប់អាវុធ។ ទោះបីជាមិនមានភាពច្បាស់លាស់ពាក់ព័ន្ធនឹងការវាយប្រហារទ្រង់ទ្រាយធំទាំងពីរលើករបស់កម្ពុជាប្រជាធិប-តេយ្យដែលត្រូវបានចោទប្រកាន់ថា បានកើតឡើងនៅក្នុងខែមេសា និងខែកញ្ញា ឆ្នាំ១៩៧៧ ក៏ដោយប៉ុន្តែឯកសារផ្ទៃក្នុងរបស់កម្ពុជាប្រជាធិបតេយ្យជាច្រើនបានរៀបរាប់អំពីលំដាប់លំដោយនៃការប្រយុទ្ធគ្នា នៅតាមបណ្តាខេត្តដែលស្ថិតនៅតាមព្រំដែនកម្ពុជាប្រជាធិបតេយ្យ និង ស.ស.វ. ព្រមទាំងការប្រយុទ្ធគ្នាទៅវិញទៅមកដែលមានទ្រង់ទ្រាយតូច ក្នុងអំឡុងឆ្នាំ១៩៧៧ ផងដែរ។

ជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ និង ស.ស.វ. ដែលបានកើតឡើងជាបន្តបន្ទាប់ក្នុងឆ្នាំ១៩៧៧ ក៏ត្រូវបានគាំទ្រដោយសក្ខីកម្មរបស់សាក្សី ឡុង សាត ដែលបានរៀបរាប់អំពីការវាយប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លាទៅតាមព្រំដែនក្នុងខេត្តកំពង់ចាម នៅចុងឆ្នាំ១៩៧៧ នៅពេលកងទ័ពកម្ពុជាប្រជាធិបតេយ្យបានវាយបន្ទាយលេខ២៧ នៅលើទឹកដីវៀតណាម។

**២៨៩**. ក្នុងខែតុលា និងខែវិច្ឆិកា ឆ្នាំ១៩៧៧ សង្គ្រាមនៅតាមព្រំដែនកើនឡើងកាន់តែច្រើននៅពេលកងទ័ពវៀតណាមបានវាយលុកក្នុងទ្រង់ទ្រាយធំចូលក្នុងខេត្តស្វាយរៀង។ ស.ស.វ. បានវាយចូលបន្ថែមនៅក្នុងខែធ្នូ ឆ្នាំ១៩៧៧ ហើយបានគ្រប់គ្រងចម្ការកៅស៊ូ និងរោងចក្រនៅមេមត់ក្នុងខេត្តកំពង់ចាម នៅក្នុងដំណើរការវាយប្រយុទ្ធនោះ បានធ្វើឲ្យភាគីកម្ពុជាប្រជាធិបតេយ្យទទួលបរាជ័យយ៉ាងធ្ងន់ធ្ងរ នៅភូមិភាគបូព៌ា។ ជម្លោះនេះបានកើតឡើងកាន់តែខ្លាំងរហូតដល់ចុងឆ្នាំ១៩៧៧ ហើយវាបានបណ្តាលឲ្យកម្ពុជាប្រជាធិបតេយ្យកាត់ផ្តាច់ចំណងការទូតជាមួយប្រទេសវៀតណាមនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧។ ស.ស.វ. បានចេញលិខិតឆ្លើយតបមួយនៅថ្ងៃដដែលនោះផងដែរ។

**២៩០**. វៀតណាមបានដកកងទ័ពចេញដោយស្ម័គ្រចិត្តនៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៨ តែជម្លោះនៅតាមព្រំដែន រួមទាំងការវាយប្រយុទ្ធគ្នាទៅវិញទៅមក នៅតែបន្តកើតឡើង នៅក្នុងអំឡុងពេញមួយខែនោះ។ មួយរយៈពេលខ្លី ក្រោយថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៨ ប៉ុល ពត បានទៅធ្វើទស្សនកិច្ចនៅភូមិភាគបូព៌ា និងបានចូលរួមការប្រជុំជាសាធារណៈមួយនៅវត្តតូង ស្រុកសួង នៅខណៈនោះ គាត់បានលើកឡើងពីគោលនយោបាយរបស់ ប.ក.ក. ដែលថាប្រជាជនកម្ពុជាម្នាក់ៗ ត្រូវសម្លាប់ជនជាតិវៀតណាមឲ្យបាន៣០នាក់។ ព្រំ សារ៉ាត បានចងចាំថា គាត់បានឮ ខៀវ សំផន ប្រកាសតាមវិទ្យុថា ឲ្យកងទ័ពប្រុងជើង ក្រោយពេលមានការវាយប្រហារពីវៀតណាមនៅក្នុងឆ្នាំ១៩៧៧ និងត្រៀមខ្លួនវាយខ្លាំង «ឈ្លានពានទឹកដីយើង»។ នៅចុងឆ្នាំ១៩៧៧ ដោយសារសង្គ្រាមនៅតាមព្រំដែនកាន់តែមានភាពតានតឹងខ្លាំង ជាពិសេសនៅក្នុងខេត្តស្វាយរៀង តាម៉ុក និង ប៉ុល ពត បានបញ្ជូនទ័ពពីខេត្តតាកែវ ទៅស្វាយរៀង ដើម្បីពង្រឹងកម្លាំងការពារនៅព្រំដែន។ ទីបញ្ជាការសមរភូមិមួយគ្រប់គ្រងដោយ សុន សេន ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ១ ចំណែកឯទីបញ្ជាការសមរភូមិមួយទៀតគ្រប់គ្រងដោយ សោ ភឹម ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៧។

**២៩១**. នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ១៩៧៨ វៀតណាមបានស្នើសុំចចារលើបញ្ហាព្រំដែនសាជាថ្មីម្តងទៀត តែសំណើនោះមិនត្រូវបានកម្ពុជាទទួលយកនោះទេ។ ចិនបានចូលរួមរៀបចំកិច្ចពិភាក្សាដោយ ចិនបានបញ្ជូនប្រតិភូមួយក្រុមមកកម្ពុជានិងបានគាំទ្ររបបកម្ពុជាប្រជាធិបតេយ្យ

តាមរយៈការបញ្ជូនអ្នកជំនាញការផ្នែកយោធា និងអ្នកស្ម័គ្រចិត្តបន្ថែមទៀត។ ទោះបីជាយ៉ាងនេះក្ដី ការវាយប្រយុទ្ធគ្នានៅតាមបណ្ដោយព្រំដែនគោក និងព្រំដែនទឹក បានបន្តកើតឡើងក្នុងអំឡុងពេលជាច្រើនខែ បន្ទាប់ពីមានជម្លោះនៅខេត្តក្រចេះ ខេត្តស្វាយរៀង ខេត្តកំពង់ចាម និងនៅជុំវិញទន្លេមេគង្គ និងទន្លេបាសាក់ ក្នុងខេត្តកណ្ដាល និង ខេត្តព្រៃវែង។

២៩២. ព័ត៌មានចចាមអារ៉ាមពាក់ព័ន្ធនិងការប៉ុនប៉ងធ្វើរដ្ឋប្រហារបានឈានដល់កម្រិតកំពូលនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៨ នៅពេលដែលប្រភពផ្សេងៗគ្នាបានចង្អុលបង្ហាញថា បុគ្គលផ្សេងៗគ្នាត្រូវបានសង្ស័យថាជាអ្នកប៉ុនប៉ងធ្វើរដ្ឋប្រហារ។ ឧទាហរណ៍ «សៀវភៅខ្មៅ» របស់កម្ពុជាប្រជាធិបតេយ្យដែលបានបោះពុម្ពផ្សាយដោយក្រសួងការបរទេស នៅខែកញ្ញា ឆ្នាំ១៩៧៨ បានលើកឡើងថា ការប៉ុនប៉ងធ្វើរដ្ឋប្រហារនៅភូមិភាគបូព៌ា ក្នុងខែឧសភា ឆ្នាំ១៩៧៨ បានលើកឡើងថា ការប៉ុនប៉ងធ្វើរដ្ឋប្រហារនៅភូមិភាគបូព៌ា ក្នុងខែឧសភា ឆ្នាំ១៩៧៨ ត្រូវបានរៀបចំដោយវៀតណាម ក្រោយពួកគេបានប្រជុំជាសម្ងាត់ជាមួយនឹងមេដឹកនាំភូមិភាគបូព៌ាជាច្រើនសារនៅខេត្តកំពង់ចាម និងខេត្តស្វាយរៀង នៅដើមឆ្នាំ១៩៧៨។ យ៉ាងណាមិញ បញ្ហានេះត្រូវបានពន្យល់លម្អិតបន្ថែមនៅក្នុងផ្នែកស្ដីពីការបែកបាក់ផ្ទៃក្នុងសាលក្រមនេះ ដែលពិភាក្សាអំពីទំនាស់ផ្ទៃក្នុង (ផ្នែក ១២.២.)។ មិនមានភស្តុតាងដែលគួរឲ្យជឿជាក់បានដែលអាចបង្ហាញថា សោ ភឹម លេខាភូមិភាគបូព៌ា បានចូលរួមក្នុងការប្រជុំដែលត្រូវបានចោទប្រកាន់ឬ បង្ហាញពីការក្បត់របស់កម្មាភិបាលភូមិភាគបូព៌ានោះទេ។ ជាក់ស្ដែងអ្នកផ្សេងទៀតបានចោទប្រកាន់ ប៉ុល ពត និង/ឬ សុន សេន ថាបានប៉ុនប៉ងធ្វើរដ្ឋប្រហារ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៨។ ឧទាហរណ៍ ឡុង សាត ដែលជាសាច់ញាតិសាច់ឆ្ងាយម្នាក់របស់ សោ ភឹម និងជាពេទ្យនៅកងវរសេនាធំ១៥៦ កងពលលេខ៤ ដឹកនាំដោយលោក ហេង សំរិន នៅភូមិភាគបូព៌ា បានផ្ដល់សក្ខីកម្មថា គាត់ចាត់ទុកថា ប៉ុល ពត ជាជនក្បត់ដោយសារ ប៉ុល ពត បានបញ្ជូនកងកម្លាំងភូមិភាគកណ្ដាលមកបោសសម្អាតនៅភូមិភាគបូព៌ា។ លោក ហេង សំរិន,ជា ស៊ីម និង អ៊ុក ប៊ុនឈឿន ក៏បានបង្ហាញការយល់ឃើញដូចគ្នានេះផងដែរ។ យ៉ាងណាមិញ ការបោសសម្អាតផ្ទៃក្នុងនៅភូមិភាគបូព៌ាបានកើតឡើងកាន់តែខ្លាំងនៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ១៩៧៨ និងជាចុងក្រោយ ឡុង សាត,ហេង សំរិន,អ៊ុក ប៊ុនឈឿន និង ជា ស៊ីម ក្នុងចំណោមអ្នកផ្សេងទៀត បានប្រមូលគ្នារត់គេចខ្លួនចូលក្នុងព្រៃ និងក្រោយមកបានផ្ដាច់ខ្លួនចូលជាមួយវៀតណាម។ ក្នុងពេលជាមួយគ្នានេះ បន្ថែមលើការវាយទៅលើកងទ័ពភូមិភាគបូព៌ា ដោយកងទ័ពភូមិភាគកណ្ដាល ជម្លោះនៅតាមព្រំដែនក៏បានកើតឡើងកាន់តែច្រើនឡើងៗ នៅត្រីមាសទីពីរ និងទីបីនៃឆ្នាំ១៩៧៨។

២៩៣. នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៧៩ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា (KNUFNS) ត្រូវបានបង្កើតឡើងនៅទីក្រុង ហូជីមិញ ដែលមានលោក ហេង សំរិន ជាប្រធាន និង លោក ជា ស៊ីម អនុប្រធាន។ ក្រុមរណសិរ្សនេះបានគាំទ្រដល់កងទ័ពវៀតណាម ក្នុងការវាយប្រហារទ្រង់ទ្រាយធំមកលើកម្ពុជាប្រជាធិបតេយ្យ នៅចុងខែធ្នូ ឆ្នាំ១៩៧៨។ នៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពបដិវត្តន៍កម្ពុជាត្រូវបានបង្ខិតថយចេញពីទីក្រុងភ្នំពេញ ចំណែកឯកងទ័ពវៀតណាម បានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពលើទឹកដីកម្ពុជាមួយភាគធំ។

២៩៤. អង្គជំនុំជម្រះយល់ឃើញថា អត្ថិភាពនៃជម្លោះប្រដាប់អាវុធជាមួយនិងវៀតណាម ក៏ត្រូវបានបង្ហាញឲ្យឃើញផងដែរ តាមរយៈវត្តមាននៃអ្នកជាប់ឃុំវៀតណាមនៅមន្ទីរសន្តិសុខ ស-២១ តាំងតែពីដើមខែមីនា ឆ្នាំ១៩៧៦មកម្ល៉េះ។ មន្ទីរសន្តិសុខស-២១ គឺជាផ្នែកមួយនៃបណ្ដាញមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្សទូទាំងប្រទេស ពោលគឺជាប្រព័ន្ធមួយដ៏ធំ ដែល ប.ក.ក. បានចាប់ផ្ដើមបង្កើតនៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដើម្បីកំណត់អត្តសញ្ញាណនិងលុបបំបាត់ខ្មាំងរបស់បក្ស ទាំងនៅខាងក្រៅជួរនិងក្នុងជួរ។ ដូចបានបង្ហាញនៅក្នុងផ្នែកផ្សេងទៀតក្នុងសាលក្រមនេះ នៅក្នុងអំឡុងពេលនៃការចោទប្រកាន់ យ៉ាងហោចណាស់ក៏មានមន្ទីរសន្តិសុខ

និងទីកន្លែងសម្លាប់មនុស្សចំនួន២០០ ដែលប្រតិបត្តិការទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ។ ប.ក.ក. បានប្រើវដ្តធម្មនុញ្ញរបស់ខ្លួន ដើម្បីធ្វើឲ្យប្រព័ន្ធនេះមានធម្មានុរូប ក្នុងនោះគឺខ្មាំងត្រូវបានផ្តន្ទាទោសដោយការឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខ ហើយជាញឹកញាប់ត្រូវបានសម្លាប់នៅតាមទីកន្លែងសម្លាប់មនុស្សក្បែរៗនោះ ព្រមទាំងបានអនុវត្តតាមប្រព័ន្ធនេះ តាមរយៈក្រឹត្យក្រមជាផ្លូវការរបស់បក្ស។ ដូចបានបង្ហាញនៅក្នុងផ្នែកផ្សេងទៀតនៃសាលក្រម នៅតាមទីតាំងទាំងនេះ អ្នកជាប់ឃុំបានទទួលរងការប្រព្រឹត្តអមនុស្សធម៌ និងទារុណកម្ម ដែលជាញឹកញាប់ត្រូវបានសម្លាប់តាមទំនើងចិត្ត ដោយគ្មានឆ្លងកាត់នីតិវិធីផ្លូវច្បាប់ត្រឹមត្រូវនោះឡើយ បន្ទាប់ពីបានរងអំពើទាំងនោះមក។

**២៩៥**. អង្គជំនុំជម្រះយល់ឃើញថា ប.ក.ក. បានចំណាយពេលវេលានិងកិច្ចខិតខំប្រឹងប្រែងជាច្រើន ដើម្បីកំណត់អត្តសញ្ញាណខ្មាំងនិងអាកប្បកិរិយារបស់ខ្មាំង ទាំងក្នុងចំណោមប្រជាជនស៊ីវិលនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងជួររបស់ខ្លួន។ នៅក្នុងន័យនេះ និងនៅក្នុងវិសាលភាពពេលវេលាទាំងមូលក្នុងសំណុំរឿង00២/0២ ប.ក.ក. បានបន្តបែងចែកប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទៅតាមវណ្ណៈភាព និងបានស្វែងរកលទ្ធភាពគំរាមកំហែងក្នុងប្រភេទផ្សេងៗ។ បុគ្គលឬអង្គភាពណាមួយ ដែលមិនប្រកាន់ខ្ជាប់ខ្លួន ឬ គំរាមគំហែងដល់មាគ៌ា ប.ក.ក. ពោលគឺទស្សនៈ ម៉ាក្សលេនីន សំដីពីបដិវត្តន៍កុម្មុយនីស្ត តាមរយៈការតស៊ូប្រដាប់អាវុធអាចត្រូវបានចាត់ទុកថាជាខ្មាំង។ ខ្មាំងបែបនេះត្រូវបានកំណត់គោលដៅ ដើម្បីដកចេញ និងយកទៅអប់រំកែប្រែ ហើយអ្នកដែលមិនអាចអប់រំបាន ត្រូវបានកំណត់គោលដៅដើម្បីកម្ចាត់ចោល។ លើសពីនេះទៀត នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ មានគោលនយោបាយកំណត់គោលដៅក្រុមខ្មាំងជាក់លាក់ពោលគឺ ជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិក និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដើម្បីចាប់ខ្លួនឃុំខ្លួន ធ្វើបាប និង/ឬសម្លាប់ចោល។

**២៩៦**. អង្គជំនុំជម្រះជឿជាក់ថា ស្របពេលជាមួយនឹងជម្លោះប្រដាប់អាវុធអន្តរជាតិដែលកំពុងបន្តកើតមានជាមួយវៀតណាមនៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនស៊ីវិលបានទទួលរងការកាប់សម្លាប់ជាទូទៅ ការធ្វើទារុណកម្ម ការរំលោភផ្លូវភេទ អំពើហិង្សាលើរាងកាយ អាពាហ៍ពិពាហ៍ដោយបង្ខំ ការធ្វើការងារដោយបង្ខំ ការបាត់ខ្លួន និងការធ្វើបាបដោយអមនុស្សធម៌ផ្សេងៗទៀត ហើយការធ្វើបាបខ្លះត្រូវបានប្រព្រឹត្តឡើងដោយមានការរើសអើង។ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនរាប់ពាន់នាក់បានក្លាយជាជនរងគ្រោះ ដោយសាររបបនៃ ប.ក.ក. និងបានស្វែងរកការជ្រកកោននៅក្នុងប្រទេសថៃ និងប្រទេសវៀតណាម។

**២៩៧**. នៅក្នុងឆ្នាំ២០០៨ មជ្ឈមណ្ឌលឯកសារកម្ពុជាបានកំណត់អត្តសញ្ញាណអដ្ឋិធាតុមនុស្សប្រមាណជា ១.៣០០.០០០ នៅក្នុងរណ្តៅកប់សពរួមនៅទូទាំងប្រទេសកម្ពុជាចំនួន ៣៥០កន្លែង។ មានតួលេខប៉ាន់ប្រមាណជាច្រើនអំពីចំនួនមនុស្សស្លាប់ ដែលបានបង្កឡើងដោយគោលនយោបាយនិងការប្រព្រឹត្តរបស់ ប.ក.ក. ។ តួលេខប៉ាន់ប្រមាណទាំងនេះ បញ្ជាក់នូវចំនួនមនុស្សស្លាប់ពី ៦០០.០០០នាក់ ទៅ ៣.០០០.០០០នាក់។ នៅក្នុងរង្វង់តួរលេខនេះអ្នកជំនាញជាច្រើនទទួលយកតួលេខប៉ាន់ប្រមាណនៃចំនួនអ្នកស្លាប់ពី ១.៥០០.០០០ ទៅ ២.០០០.០០០ នាក់ជាចំនួនដែលពិតប្រាកដបំផុត។ ទោះបីជាយ៉ាងណា អង្គជំនុំជម្រះបានរម្លឹកឡើងវិញនូវការយល់ឃើញរបស់ខ្លួនថា អវត្តមានទិន្នន័យស្ថិតិពាក់ព័ន្ធ និងដែលអាចទុកចិត្តបានសម្រាប់គោលបំណងនៃការវាយតម្លៃលើចំនួនមរណភាពជាក់លាក់ដែលជាប់ទាក់ទងនឹង ប.ក.ក. នាំឲ្យមានភាពមិនច្បាស់លាស់ជុំវិញការប្រើប្រាស់ភ័ស្តុតាងប្រជាសាស្ត្រ នៅតែជាមូលដ្ឋានគ្រឹះមិនច្បាស់លាស់បញ្ជាក់លើតួលេខទាំងនេះ។

**(តទៅលេខក្រោយ)**

# វេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»

ស្វួត វិចិត្រ



មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៅលើខ្នងភ្នំដងរែក។ (ស្វួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីខែតុលា ឆ្នាំ២០២០នេះ វេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ត្រូវបានរៀបចំឡើងតាមប្រព័ន្ធអនឡាញ ដោយក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ក្នុងគោលបំណងជំរុញឲ្យមានការពិភាក្សាលើផ្នែកប្រវត្តិសាស្ត្រ លើកកម្ពស់ការយល់ដឹងអំពីសន្តិភាព និងការផ្សះផ្សា។

សិស្សានុសិស្សចូលរួមសរុបចំនួន៨នាក់ មកពីវិទ្យាល័យអន្លង់វែង បានចូលរួមវេទិកានេះ និងបានផ្តោតការចាប់អារម្មណ៍លើទិដ្ឋភាពនៃការរស់នៅរបស់ប្រជាជនកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សិស្សានុសិស្សទាំងនេះស្ទើរតែមិនជឿថា ឪពុកម្តាយរបស់ខ្លួន និងប្រជាជនផ្សេងទៀតអាចឆ្លងកាត់នូវសម័យកាលដ៏លំបាកៗនៅក្នុងរបបខ្មែរក្រហម ស្ថានភាពរស់នៅរបស់ប្រជាជនក្នុងសង្គម ត្រូវបានផ្លាស់ប្តូរទាំងស្រុង ដោយខ្មែរក្រហមប្រើប្រជាជនឲ្យធ្វើការហួសកម្លាំង បង្អត់អាហារ ធ្វើទុក្ខបុក និងការយកមនុស្សទៅសម្លាប់។ ជាលទ្ធផលដ៏





សិស្សានុសិស្សនៃវិទ្យាល័យអន្លង់វែង ចូលរួមវេទិកាថ្នាក់រៀន ស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» តាមប្រព័ន្ធអនឡាញ នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅខែតុលា ឆ្នាំ២០២០។
(ស្ទួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

អាក្រក់ ប្រជាជនប្រមាណជិតពីរលាននាក់បានស្លាប់បាត់បង់ជីវិត ហើយរណ្តៅសាកសពរួមប្រមាណ២ម៉ឺនរណ្តៅបានរាយពាសពេញផ្ទៃប្រទេស។ អំពើឃោរឃៅនិងការសម្លាប់នេះ បានឆ្លុះបញ្ចាំងអំពីការធ្លាក់ចុះនូវផ្នែកសីលធម៌ និងការខ្វះតម្លៃនៅក្នុងការរួមរស់ជាមួយគ្នាក្នុងសង្គម។ សិស្សានុសិស្សបានលើកឡើងថា ប្រជាជនកម្ពុជាប្រមាណ៥លាននាក់ដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម គឺជាបុគ្គលដែលមានសំណាងរួមទាំងឪពុកម្តាយរបស់ខ្លួន។

ផ្នែកបន្ទាប់នៃវេទិកាថ្នាក់រៀននេះ គឺលើកឡើងពីអំពើប្រល័យពូជសាសន៍ និងការទប់ស្កាត់នៃអំពើនេះ។ យោងទៅលើសំណួរស្ទាបស្ទង់មតិរបស់សិស្សនៅក្រោយវេទិកាបានបង្ហាញថា ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ក្នុងសង្គមមួយ មនុស្សម្នាក់ៗ ត្រូវបដិសេធចោលនូវរាល់ការប្រើអំពើហិង្សា, លើកទឹកចិត្តឲ្យមានដំណោះស្រាយដោយសន្តិវិធី ការទិតៀន និងការប្រឆាំងចំពោះអំពើហិង្សា ដែលវាជាវិធីសាស្ត្រដ៏សំខាន់បំផុតនៅក្នុងការផ្លាស់ប្តូរផ្នត់គំនិត និងការយល់ឃើញរបស់មនុស្សម្នាក់ៗ ក្នុងសង្គមកុំឲ្យធ្លាក់ទៅរកអំពើឃោរឃៅ។ ការការពារសិទ្ធិជាបុគ្គលដោយមិនគិតពីពណ៌សម្បុរ និងនិន្នាការនយោបាយ គឺបានបង្ហាញពីភាពសម្បូរបែបរបស់មនុស្ស, វប្បធម៌, សាសនា និងសហគមន៍ទាំងមូល។

ផ្នែកចុងក្រោយនៃវេទិកានេះ គឺលើកឡើងអំពីទស្សនវិស័យនៃវឌ្ឍនៈភាពរបស់សហគមន៍អន្លង់វែង ដែលជាទីតាំងតស៊ូចុងក្រោយរបស់ខ្មែរក្រហមថានឹងអាចលូតលាស់ទៅមុខបាន ឬប្រែទៅជាទីក្រុងតូចមួយនៅជាប់ព្រំដែនកម្ពុជា-ថៃ។ ទស្សនវិស័យនេះ បានរំលេចឡើងតាមរយៈការចាក់បញ្ចាំងវីដេអូឃ្លីបគោលស្រុកអន្លង់វែងទៅកាន់សិស្ស ដោយផ្សារភ្ជាប់ទៅនឹងក្តីសង្ឃឹមរបស់ប្រជាជនក្នុងតំបន់នេះជាមួយនឹងទេសចរណ៍បែបអន្តរកាលទាំង ១៤ទីតាំងនៅក្នុងសហគមន៍នេះផ្ទាល់។

ក្នុងចំណោមទីតាំងទេសចរណ៍បែបអន្តរកាលទាំង ១៤ចំណុចខាងលើនេះ ក្នុងនោះ អតីតផ្ទះប្រជុំរបស់តាម៉ុកលើខ្នងភ្នំដងរែក ត្រូវបានស្គាល់ថា ជាការិយាល័យដំបូងបង្អស់របស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នាពេលបច្ចុប្បន្ន និងការិយាល័យថ្មីមួយកន្លែងទៀតស្ថិតនៅក្នុងទីរួមស្រុកអន្លង់វែង ដែលជាទីតាំងសម្រាប់ប្រមែរប្រមូលផ្តល់ព័ត៌មាន និងតម្កល់ទុកនូវឯកសារប្រវត្តិសាស្ត្រខ្មែរក្រហមប្រមាណជា ២៩០០ឯកសារស្មើនឹង៦៧៤២៦ ទំព័រសម្រាប់អ្នកសិក្សាស្រាវជ្រាវជាតិ និងអន្តរជាតិដែលមានបំណងចង់ស្វែងយល់ពីខ្លឹមសារប្រវត្តិសាស្ត្រនេះ។ ការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមពុំមែនបានសេចក្តីថា ជាការបង្វែរឆន្ទៈ ឬបន្ទុចបង្អាក់ទស្សនវិស័យរបស់យុវជនឲ្យលង់លក់ក្នុងភាពអន្តរកាលនៃប្រវត្តិសាស្ត្រ

ខ្មែរក្រហមទេ ប៉ុន្តែយ៉ាងហោចណាស់ការស្វែងយល់ពីមូលដ្ឋានគ្រឹះនៃអំពើឃោរឃៅ និងការវិន័យលើផ្នែកសីលធម៌គួរតែត្រូវបានឆ្លុះបញ្ចាំងទៅកាន់យុវជនតាមរយៈសាច់រឿង និងខ្លឹមសារប្រវត្តិសាស្ត្រ។

បន្ទាប់ពីវេទិកាថ្នាក់រៀនបានបញ្ចប់ទៅ សិស្សានុសិស្សនៅក្នុងក្រុមបានបញ្ចេញទស្សនយល់ឃើញរៀងៗខ្លួន ទៅលើការចងចាំពីផលប៉ះពាល់ក្រោមរបបខ្មែរក្រហម និងក្ដីសង្ឃឹមយ៉ាងមុតមាំចំពោះសហគមន៍របស់ខ្លួនដូចខាងក្រោម៖

**ហ៊ាន់ ហុងលី** *ភេទស្រី អាយុ១៩ឆ្នាំ ជាសិស្សនៃវិទ្យាល័យអន្លង់វែង បានបង្ហាញចំណាប់អារម្មណ៍ថា «ខ្ញុំយល់ឃើញថាវេទិកានេះពិតជាល្អ ពីព្រោះខ្ញុំទទួលបានចំណេះដឹងជាច្រើនពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំឃើញថា របបខ្មែរក្រហមពិតជាមានការជិះជាន់ និងកាប់សម្លាប់យ៉ាងព្រៃផ្សៃទៅលើប្រជាជនស្លូតត្រង់ឲ្យទទួលរងទុក្ខវេទនាយ៉ាងធ្ងន់ធ្ងរ។ ការកសាងសហគមន៍មួយ ចាំបាច់ត្រូវមានការចងចាំផ្នែកប្រវត្តិសាស្ត្រ ពីព្រោះវាបានបង្ហាញពីការចាប់ផ្ដើមមួយដោយផ្សារភ្ជាប់ពីបទពិសោធន៍របស់ប្រជាជនក្នុងសហគមន៍នេះផ្ទាល់។ ដោយឡែកខ្ញុំមានក្ដីរំពឹងយ៉ាងមុតមាំទៅលើសហគមន៍អន្លង់វែង ថានឹងមានទទួលស្គាល់កាន់តែទូលំទូលាយ តាមរយៈការប្រែប្រួលនូវហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយធ្វើដំណើរ»។*

---

**ហ៊ី ចន្ធី** *ភេទស្រី អាយុ១៩ឆ្នាំ បានយល់ឃើញថា «ខ្ញុំគិតថាការបង្កើតវេទិកាថ្នាក់រៀននេះ គឺល្អសម្រាប់ខ្ញុំផ្ទាល់។ ខ្ញុំមើលឃើញថា ការរៀនពីប្រវត្តិសាស្ត្រនេះក៏មានទំនាក់ទំនងជិតស្និទ្ធទៅនឹងកម្មវិធីសិក្សារបស់រដ្ឋដែរ ដែលបានបំពេញបន្ថែមនូវភាពខ្វះចន្លោះរបស់ខ្ញុំដែលមិនធ្លាប់បានដឹងពីមុនមក។ ខ្ញុំយល់ថា ការកសាងសហគមន៍មួយឲ្យដើរទៅមុខ យើងក៏មិនត្រូវទុកចោលនូវរឿងរ៉ាវប្រវត្តិសាស្ត្រដែលមាននៅក្នុងសហគមន៍នេះដែរ។ ខ្ញុំសង្ឃឹមថា សហគមន៍អន្លង់វែងនឹងមានការរីកចម្រើនទៅមុខ និងក្លាយជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រដែលអាចមានភាពលេចធ្លោរកាន់តែខ្លាំងឡើង»។*



**ជា សុភ័ក្រ** *ភេទប្រុស អាយុ១៧ឆ្នាំ បានយល់ឃើញថា «បន្ទាប់ពីខ្ញុំបានចូលរួមក្នុងវេទិកាថ្នាក់រៀននេះរួចមក ខ្ញុំយល់ថា សញ្ញាណមួយចំនួនដែលនាំឲ្យកើតមានអំពើប្រល័យពូជសាសន៍ គឺភាពស្អប់ខ្ពើមចំពោះជាតិសាសន៍ដទៃ។ ជនជាតិភាគតិច ក៏ទទួលរងទុក្ខវេទនាដែរ។ ដូចនេះ ប្រវត្តិសាស្ត្រនៅតែមានសារសំខាន់ ដែលតម្រូវឲ្យមានការបើកទូលាយក្នុងការពិភាក្សានៅតាមបណ្ដាគ្រឹះស្ថានសិក្សារដ្ឋ និងឯកជន និងតាមភូមិស្រុកជាដើម»។*



*ប្រជាជនត្រង និងបង់សំណាញ់ នៅបឹងតាម៉ុក ឬបឹងអន្ទង់វែង។*
*(សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

# «ផេះផង់ធូលី»
# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
# អ៊ុក ស៊ីវត្ថា ៖ គ្រូបង្រៀន

***ប្រពន្ធរបស់គាត់ ញឹម ណាន បានរៀបរាប់ប្រាប់ថា៖***

*នៅពេលដែលខ្ញុំនៅក្មេង ខ្ញុំចង់រៀនសូត្រ ដែលខ្ញុំអាចក្លាយទៅជាគ្រូបង្រៀនម្នាក់។ ខ្ញុំបានយល់ឃើញថា គ្រូបង្រៀនជាច្រើនមានការអប់រំល្អ ស្លៀកពាក់ស្អាតបាត និងមិនធ្វើការងារលំបាកខ្លាំងឡើយ។ ប៉ុន្តែ ប្រពៃណីរបស់ជនជាតិខ្មែរតឹងតែងណាស់នៅពេលនោះ។ ឪពុកម្តាយរបស់ខ្ញុំ បានខ្លាចក្រែងថាមិនមានបុរសណានឹងចង់រៀបការជាមួយខ្ញុំទេ ប្រសិនបើខ្ញុំមានការអប់រំល្អ។*

*គាត់បាននិយាយដែរថា សាលារៀននៅឆ្ងាយពីផ្ទះរបស់ខ្ញុំ ហើយមិនមានអ្នកណានៅទីនោះមើលខុសត្រូវខ្ញុំ។ មិនចង់ជំទាស់បំណងប្រាថ្នារបស់ឪពុកម្តាយខ្ញុំ ខ្ញុំបានឈប់រៀននៅពេលដែលខ្ញុំរៀនបានថ្នាក់ទី៦ ហើយបានក្លាយជាកសិករម្នាក់។*

*ប្តីរបស់ខ្ញុំឈ្មោះ ស៊ីវុត្ថា និងខ្ញុំបានជួបគ្នានៅពេលដែលគាត់បានមកពីស្រុកជើងព្រៃ ក្នុងខេត្តកំពង់ចាម មកលេងអ្នកជិតខាងរបស់ខ្ញុំ។ គាត់បានឃើញខ្ញុំមុនដំបូង នៅពេលដែលខ្ញុំចេញពីផ្ទះទៅទទួលឪពុកខ្ញុំដែលត្រឡប់មកពីស្រែ។ គាត់បានសួរអ្នកជិតខាងអំពីខ្ញុំ ហើយគាត់បានបញ្ចុះបញ្ចូលឪពុកខ្ញុំឲ្យយល់ព្រមតាមសំណើសុំរៀបការរបស់គាត់។ គាត់បានផ្តល់ប្រាក់៨០០០រៀលឲ្យគ្រួសារខ្ញុំ តាមបន្ទាប់ជាចំណងដៃ។*

*នៅឆ្នាំ១៩៧០ យើងបានរស់នៅក្រុងកំពង់ចាម ហើយ ស៊ីវុត្ថា បានបង្រៀនថ្នាក់ទី៦ និងធ្វើការនៅក្នុងការិយាល័យ ធ្វើឲ្យជីវភាពបានត្រឹមតែគ្រប់គ្រាន់។ បន្ទាប់មករបបសាធារណរដ្ឋខ្មែរបានចាប់ផ្តើមកែនគ្រូបង្រៀនឲ្យធ្វើជាទាហាន លន់ នល់ សម្រាប់រយៈពេល៦ខែ។ ស៊ីវុត្ថា មិនដែលចេញទៅសមរភូមិ គឺគាត់មានវគ្គបណ្តុះបណ្តាលយោធា ហើយគាត់ក៏មិនចូលចិត្តធ្វើជាទាហានដែរ។ បន្ទាប់ពីជាប់កំណែនទាហាន៦ខែបានបញ្ចប់ គាត់បានសុំធ្វើការជាគ្រូបង្រៀនសារជាថ្មី។*

*នៅអំឡុងរបប លន់ នល់ មានការវាយប្រយុទ្ធគ្នាខ្លាំងក្លានៅកំពង់ចាម ដូច្នេះយើងបានបន្តផ្លាស់ទីលំនៅពីភូមិមួយទៅភូមិមួយដើម្បីជៀសវាងការប្រយុទ្ធ។ នៅពេលដែលយើងបានឆ្អែតឆ្អន់នឹងសង្គ្រាម ស៊ីវុត្ថានិងខ្ញុំបានសម្រេចចិត្តផ្លាស់ទៅនៅទីក្រុងភ្នំពេញ។*

*ស៊ីវុត្ថា អាចរកការងារបានជាគ្រូបង្រៀននៅវិទ្យាល័យមួយ នៅក្រុងភ្នំពេញ។ ខ្ញុំបានស្នាក់នៅផ្ទះមើលថែរក្សាកូន៧នាក់របស់យើង ហើយ ស៊ីវុត្ថា បានធ្វើការក្រៅម៉ោងជាអ្នកធាក់ស៊ីក្លូ។ ទោះបីជាយ៉ាងណាក៏ដោយ នៅមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ស្ថានការណ៍នៅទីក្រុងភ្នំពេញបានក្លាយជាតឹងតែងខ្លាំង នៅពេលដែលគ្រាប់បែកជាច្រើនបានធ្លាក់នៅជាយក្រុង។*

*ប្តីរបស់ខ្ញុំត្រូវបានចាត់តាំងឲ្យទៅបង្រៀននៅតាមខេត្ត ដូច្នេះខ្ញុំបានសុំការអនុញ្ញាតផ្លាស់ទៅខេត្តបាត់ដំបង ជាទីដែលប្អូនស្រីខ្ញុំរស់នៅ។ យើងបានធ្វើដំណើរទៅទីនោះតាមយន្តហោះ ព្រោះក្រសួងអប់រំបានចេញថ្លៃសំបុត្រយន្តហោះ។*

*ខ្មែរក្រហមបានកាន់កាប់ខេត្តបាត់ដំបងទាំងស្រុងនៅខែមេសា ឆ្នាំ១៩៧៥។ នៅពេលខ្មែរក្រហមប្រាប់យើងឲ្យចាកចេញ យើងយកបានកូនរបស់យើងទាំងអស់៧នាក់ និងយកបានតែរបស់ប្រើប្រាស់ពីរបីប៉ុណ្ណោះ។ ខ្ញុំចង់ទៅស្រុកកំណើតរបស់ខ្ញុំ ប៉ុន្តែប្តីខ្ញុំនិយាយថា យើងត្រូវរង់ចាំ និងមើលថាតើស្ថានការណ៍វិវត្តទៅយ៉ាងណានៅមុនពេលយើងចេញទៅទីនោះ។ នៅពេលយើងទៅដល់ភូមិកំណាប់ មានមនុស្សចាស់មូលដ្ឋានម្នាក់បានសុំយើងឲ្យរស់នៅក្នុងសហករណ៍នោះ។ កូនៗរបស់យើងត្រូវបានបញ្ចូលទៅក្នុងកងចល័ត ហើយប្តីខ្ញុំបានមើលថែទាំគោ ក្របី និងភ្ជួរស្រែ ចំណែកខ្ញុំបានស្ទូងសំណាប។*

*នៅឆ្នាំ១៩៧៦ កូនពៅរបស់ខ្ញុំបានស្លាប់ដោយអត់ឃ្លាន ព្រោះខ្ញុំមិនមានទឹកដោះគ្រប់គ្រាន់បំបៅវា។ បន្ទាប់មកប្តីខ្ញុំបានស្លាប់ដោយសារការអត់ឃ្លានទៀត។ វាមានស្រូវដែលមានគុណភាពល្អច្រើនណាស់នៅបាត់ដំបង ប៉ុន្តែមានតែខ្មែរក្រហមប៉ុណ្ណោះ ដែល*

អាចហូបបាយទាល់តែឆ្អែតៗ យើងប្រជាជនថ្មី មានបាយហូបតែនៅពេលច្រូតកាត់ប៉ុណ្ណោះៗ ខ្ញុំមិនដឹងខ្មែរក្រហមដឹកជញ្ជូនស្រូវនៅសល់នោះទៅទីណាឡើយ។

នៅថ្ងៃបន្ទាប់ពីខ្ញុំកប់សាកសពប្តីរបស់ខ្ញុំ គ្រូបង្រៀន ៥ ឬ ៦នាក់និងគ្រួសាររបស់គ្រូទាំងនោះដែលរស់នៅក្នុងសហករណ៍របស់ខ្ញុំត្រូវបានបញ្ជូនទៅសម្លាប់ដែរ។ កម្មាភិបាលម្នាក់បានមកផ្ទះខ្ញុំ ហើយសួរថា «ប្តីរបស់អ្នក នៅឯណា?» ខ្ញុំនិយាយថា ប្តីរបស់ខ្ញុំបានស្លាប់ហើយ។ កម្មាភិបាលបាននិយាយថា «អង្គការបានបញ្ជាខ្ញុំឲ្យយកគាត់ទៅ ប៉ុន្តែបើគាត់ស្លាប់ហើយនោះ មិនអីទេ»។ បន្ទាប់ពីនោះ កូនខ្ញុំពីរនាក់ទៀត បានស្លាប់ដោយសារអត់ឃ្លាន។

នៅក្នុងរបបនោះ យើងមិនអាចហូបផ្លែចេក ដែលយើងបានដាំនៅក្នុងដីផ្ទាល់ខ្លួនរបស់យើងឡើយ។ អង្គការបាននិយាយថា អ្វីៗទាំងអស់ត្រូវតែប្រមូលនិងប្រើប្រាស់ជាសមូហភាព។ ប្រសិនបើយើងហូបផ្លែឈើរបស់យើង យើងនឹងត្រូវចោទប្រកាន់អំពីបទក្បត់សហករណ៍ទាំងមូល។

ខ្ញុំបានស្នាក់នៅភូមិកំណាប់ ទាល់តែកងទ័ពវៀតណាមបានវាយចូលមកប្រទេសកម្ពុជានៅ ឆ្នាំ១៩៧៩ បន្ទាប់មកកូនទាំងបីនាក់របស់ខ្ញុំ និងខ្ញុំបានធ្វើដំណើរត្រឡប់ទៅផ្ទះរបស់យើង។ សព្វថ្ងៃនេះខ្ញុំជាដូនជីម្នាក់ៗ ខ្ញុំធ្វើអំពើល្អ និងឧទ្ទិសការបន់ស្រន់របស់ខ្ញុំឲ្យបានដល់ប្តីខ្ញុំ និងកូនទាំងបីនាក់ ដែលបានស្លាប់នៅអំឡុងរបបខ្មែរក្រហម។

**ប៉ាង ពីរ័ន្ត និង ខេនី ខករហ្គៀល**



ញឹម ណាន និង អ៊ុក ស៊ីវុត្ថា បន្ទាប់ពីពិធីមង្គលការរបស់គេនៅខេត្តកំពង់ធំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

### «ផេះផង់ធូលី»

## រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# ជួន លាង វួច ៖ គ្រូបង្រៀន
# ហុក ឆាយ ស្រេង ៖ ប៉ូលីស

***កូនប្រុសរបស់គាត់ឈ្មោះ សន គីណាល់ បានរៀបរាប់ប្រាប់ថា ៖***

*នៅពេលដែលឪពុករបស់ខ្ញុំត្រឡប់មកពីសិក្សានៅសាលាយោធាមួយក្នុងប្រទេសឥណ្ឌូនេស៊ី គាត់ត្រូវបានតែងតាំងទៅជាវរសេនីយ៍ត្រី នៅក្នុងជួរប៉ូលីស។ ម្តាយរបស់ខ្ញុំ គឺជាគ្រូបង្រៀនម្នាក់នៅទីក្រុងភ្នំពេញ។ ពួកគាត់បានជួបគ្នា មុនពេលដែលឪពុករបស់ខ្ញុំចាកចេញទៅប្រទេសឥណ្ឌូនេស៊ី។ បន្ទាប់ពីឪពុករបស់ខ្ញុំត្រឡប់មកវិញ គាត់ក៏បានស្នើសុំម្តាយរបស់ខ្ញុំដើម្បីរៀបការ។*

*នៅក្នុងឆ្នាំ១៩៧៤ ឪពុករបស់ខ្ញុំត្រូវបានផ្លាស់ទៅខេត្តបាត់ដំបង ដោយនៅទីនោះ គាត់គឺជាមេប៉ូលីស។ ម្តាយរបស់ខ្ញុំ និងខ្ញុំបានផ្លាស់ទៅជាមួយឪពុករបស់ខ្ញុំ ហើយគាត់បានបង្រៀននៅសាលាស្ថិតនៅក្នុងវត្តមួយ។*

*អង្គការចាប់ផ្តើមតាមដានសកម្មភាពរបស់គ្រួសារពួកយើង បន្ទាប់ពីខ្មែរក្រហមឡើងគ្រប់គ្រងអំណាច។ នៅពេលដែលអង្គការដឹងថា ឪពុករបស់ខ្ញុំ គឺជាអតីតប៉ូលីស អង្គការបានស្នើគាត់ឲ្យទៅទទួលសម្តេចព្រះ នរោត្តម សីហនុ នៅក្បែរភ្នំធិបតី ដោយប្រាប់ថា សម្តេចព្រះ នរោត្តម សីហនុ មកទស្សនាទីនោះ។*



*ពិធីរៀបការរបស់ ជួន លាង វួច និង ហុក ឆាយ ស្រេង ប្រហែលនៅអំឡុងឆ្នាំ១៩៧០។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*ឪពុករបស់ខ្ញុំ រួមជាមួយប៉ូលីស និងទាហាន លន់ នល់ ជាច្រើននាក់ទៀត ត្រូវបាននាំទៅទទួលសម្តេច សីហនុ។ ឡានបីទៅបួនគ្រឿង ដែលផ្ទុកពេញទៅដោយមនុស្សបានចាកចេញក្នុងថ្ងៃនោះ។ វាគឺជាពេលវេលាចុងក្រោយដែលយើងបានឃើញគាត់។*

*បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ខ្ញុំបានជួបបុរសម្នាក់ដែលធ្លាប់ធ្វើជាប៉ូលីស ហើយបានស្ថិតនៅក្នុងឡានជាមួយឪពុករបស់ខ្ញុំ។ គាត់បានរៀបរាប់ប្រាប់ខ្ញុំថា នៅពេលដែលឡានទៅជិតដល់ភ្នំ គាត់បានឮស្នូរបាញ់កាំភ្លើងចេញពីក្នុងព្រៃ។ ខ្មែរក្រហមបានបាញ់រះមកលើពួកគាត់។ គាត់និយាយថា បើទោះបីជាគាត់បានរត់គេចខ្លួនរួច ប៉ុន្តែឪពុករបស់ខ្ញុំ និងអ្នកផ្សេងទៀតត្រូវបាន*

សម្លាប់ ។

បន្ទាប់មកអង្គការចាប់ផ្តើមស៊ើបអង្កេតទៅលើម្តាយរបស់ខ្ញុំ។ នៅពេលម្តាយរបស់ខ្ញុំ និងមិត្តភក្តិរបស់គាត់ពីរបីនាក់ទៀត ដែលធ្លាប់ជាអតីតគ្រូបង្រៀន មុនរបបខ្មែរក្រហម បានដឹងជាមុនថា ពួកគាត់មានឈ្មោះនៅក្នុងបញ្ជីដែលអង្គការត្រូវកម្ទេច។ មិត្តភក្តិរបស់ម្តាយខ្ញុំបានស្នើម្តាយខ្ញុំឲ្យរត់ទៅជាមួយពួកគេ។ ម្តាយរបស់ខ្ញុំមិនអាចយកខ្ញុំទៅជាមួយគាត់បានទេ ព្រោះវាជាដំណើរផ្សងព្រេងមួយដ៏វែងឆ្ងាយ និងគ្រោះថ្នាក់។

ម្តាយរបស់ខ្ញុំបានសម្រេចចិត្តចាកចេញពីខ្ញុំ ជាមួយនឹងស្ត្រីដែលបច្ចុប្បន្នជាបងស្រីចិញ្ចឹមរបស់ខ្ញុំ។ គាត់មានឈ្មោះ សន ស៊ីយ៉ែម ដែលប្អូនស្រីរបស់គាត់ធ្លាប់ជាកូនសិស្សម្នាក់របស់ម្តាយខ្ញុំ។ ម្តាយរបស់ខ្ញុំបាននិយាយទៅកាន់ យ៉ែម ថា «សូមកុំប្តូរឈ្មោះគីណាល់ កូនប្រុសរបស់ខ្ញុំ»។ ប្រសិនបើខ្ញុំមានសំណាងបានរស់រានមានជីវិត ខ្ញុំនឹងត្រឡប់មកយកកូនខ្ញុំពីអ្នកវិញ»។ នៅពេលដែលម្តាយរបស់ខ្ញុំចាកចេញ ខ្ញុំកំពុងតែគេងលង់លក់ ប៉ុន្តែ យ៉ែម បានប្រាប់ខ្ញុំថា ម្តាយរបស់ខ្ញុំបានយំដោយសារតែគាត់មិនដាច់ចិត្តចាកចេញពីខ្ញុំ។ បន្ទាប់មកគាត់បានធ្វើដំណើរចាកចេញទៅបានចម្ងាយពីរបីម៉ែត្រក៏ឈប់ ហើយរត់ត្រឡប់ក្រោយមកមើលមុខខ្ញុំជាលើកចុងក្រោយ។

ខ្ញុំលាក់ខ្លួនគ្រប់ទីកន្លែងដែលខ្ញុំអាចទៅធ្វើបាន បន្ទាប់ពីម្តាយរបស់ខ្ញុំបាត់ខ្លួនទៅ ព្រោះអង្គការបានចោទប្រកាន់ខ្ញុំថាជាកូនរបស់ខ្មាំង។ នៅពេលយប់ យ៉ែម បានលួចបាយដែលនៅសល់ និងត្រីប្រឡាក់សម្រាប់ខ្ញុំ។ គាត់បានយកបាយនៅសល់នោះទៅដាំបបរសម្រាប់ខ្ញុំហុតទឹកវា។ ពេលខ្លះគាត់បានឲ្យស្ករមកខ្ញុំ ហើយខ្ញុំបានលួចហូបវានៅក្រោមគ្រែដេក ប៉ុន្តែខ្ញុំនៅតែឃ្លាន។

យ៉ែម ធ្វើការនៅមន្ទីរពេទ្យ ដូច្នេះពេលខ្លះគាត់បានលួចទឹកពីមន្ទីរពេទ្យដែលទុកសម្រាប់ដាំបាយ និងយកស្លឹកឈូកគ្របលើទឹកនោះ។ ប្រជាជនជាច្រើនបានស្លាប់នៅក្នុងមន្ទីរពេទ្យ ព្រោះពុំមានថ្នាំព្យាបាល ហើយអ្នកទាំងនោះបានធ្លាក់ខ្លួនទៅជាហើម។ សពរបស់ពួកគេត្រូវបានកប់ទៅក្នុងរណ្តៅរាក់ៗ និងមានស្លឹកឈើគ្របពីលើ។ ពេលខ្លះសត្វឆ្កែបានទៅកាយសាកសពធ្វើឲ្យជះក្លិនអាក្រក់គួរឲ្យរអើម។

ថ្ងៃមួយ ប្រពន្ធរបស់ប្រធានសហករណ៍បានសម្រាលកូននៅមន្ទីរពេទ្យដែលបង យ៉ែម ធ្វើការ។ ឆ្មបពីរបីនាក់ត្រូវបានបញ្ជូនទៅជួយ ប៉ុន្តែឆ្មបទាំងនោះមិនអាចជួយបានទេ ដូច្នេះប្រធានសហករណ៍បានបញ្ជូនអ្នកទាំងនោះទៅសម្លាប់។ បន្ទាប់មក ប្រធានសហករណ៍បានគម្រាមសម្លាប់ យ៉ែម ទៀតប្រសិនបើមិនអាចជួយបង្កើតកូនបាន។ យ៉ែម បានកាត់មែកសង្កែជាដុំៗហើយដុតវាជន្លួសឲ្យធូប ដើម្បីបន់ស្រន់សុំឲ្យប្រពន្ធប្រធានសហករណ៍សម្រាលកូនបានដោយជោគជ័យ។ នៅពេលដែលកូននោះកើតមកដោយសុវត្ថិភាពហើយ ប្រធានសហករណ៍បានអរគុណ យ៉ែម និងបានផ្តល់រង្វាន់អង្ករជាច្រើន។ យ៉ែម នៅតែជាឆ្មបម្នាក់រហូតមកដល់សព្វថ្ងៃ។

អង្គការបានយក យ៉ែម ទៅរៀនសូត្រជាច្រើនដង ដោយសារតែ យ៉ែម បានលាក់កូនប្រុសរបស់ខ្មាំង។ អង្គការចង់សម្លាប់ យ៉ែម ដូច្នេះ យ៉ែម បានបញ្ជូនខ្ញុំឲ្យទៅម្តាយរបស់គាត់ដែលរស់នៅឆ្ងាយពីភូមិដែលគាត់រស់នៅ។ ខ្ញុំត្រូវបានប្តូរឈ្មោះទៅជា សន ដូច្នេះអង្គការមិនអាចរកខ្ញុំឃើញឡើយ។ ខ្ញុំបានផ្លាស់ប្តូរទីកន្លែងជាច្រើនលើកច្រើនសារ ប៉ុន្តែបន្ទាប់ពីនោះមកខ្ញុំបានស្នាក់នៅជាមួយម្តាយរបស់ យ៉ែម រហូតដល់ទីបញ្ចប់នៃរបបនោះ។

បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម ខ្ញុំបានរស់នៅជាមួយ យ៉ែម នៅខេត្តបាត់ដំបង។ ប៉ុន្តែខ្ញុំនៅតែរង់ចាំឪពុកម្តាយរបស់ខ្ញុំត្រឡប់មកវិញ ជាពិសេសម្តាយរបស់ខ្ញុំ។ ខ្ញុំជឿជាក់ថា គាត់នៅរស់រានមានជីវិត។

**ប៉ាង ពីច័ន្ទ និង ខេនី ខករម៉ៀល**

## «ផេះផង់ធូលី»

# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# ឡៅ អ៊ុំ ៖ គ្រូបង្រៀន

***អ៊ុំ សំអាត ជាកូនស្រីរបស់គាត់បាននិយាយរៀបរាប់ប្រាប់ថា ៖***

*ពេលឪពុកខ្ញុំនៅតូច គាត់បានបួសជាព្រះសង្ឃ និងរៀននៅក្នុងវត្ត។ ការបញ្ជូនកូនប្រុសទៅនៅវត្តគឺជាទំនៀមទម្លាប់របស់ចាស់ៗពីបុរាណ។ ពួកគេគិតថា នៅពេលកូនបួសជាសង្ឃនឹងទទួលការអប់រំល្អ ហើយស្ត្រីខ្មែរភាគច្រើននឹងងាយយល់ព្រមរៀបការជាមួយនរណាម្នាក់ដែលមានចំណេះខ្ពស់ដែលអាចបង្រៀនសិស្សនៅសាលានៅវត្តបាន នៅពេលដែលបុរសនោះទៅដណ្តឹងខ្លួនធ្វើជាប្រពន្ធ។ ដូច្នេះហើយឪពុករបស់ខ្ញុំក៏បានសឹកនៅពេលដែលជីតារបស់ខ្ញុំបានរកប្រពន្ធឲ្យគាត់។*

*បន្ទាប់ពីគាត់រៀបការ ឪពុករបស់ខ្ញុំបានធ្វើជាគ្រូអក្សរសាស្ត្រនៅក្នុងភូមិរបស់យើងស្ថិតនៅក្នុងទីក្រុងភ្នំពេញ។ នៅពេលនោះម្តាយរបស់ខ្ញុំក៏បានរៀនអក្សរនៅផ្ទះ ដោយឪពុករបស់ខ្ញុំជាអ្នកបង្រៀនដែរ។ ក្រោយមក ឪពុករបស់ខ្ញុំក៏ត្រូវបានជ្រើសរើសជាអនុភូមិដែលគ្រប់គ្រងផ្ទះ៥០ខ្នង ខណៈដែលប្រធានភូមិគ្រប់គ្រងផ្ទះ១០០ខ្នង។ ប្រព័ន្ធនៃការគ្រប់គ្រងបែបនេះមានតែនៅក្នុងរបបលន់ នល់ ប៉ុណ្ណោះ ដែលប្រើប្រាស់ស្ថិតិជាក់លាក់ដើម្បីទទួលបានជំនួយពីអាមេរិកាំង។ វាក៏ជួយសម្រួលដល់អាជ្ញាធរឲ្យដឹងពីចំនួនប្រជាជនដែលចេញពីភូមិ និងចំនួនប្រជាជនដែលទើបចូលមករស់នៅក្នុងភូមិ។*



*ឡៅ អ៊ុំ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*បងប្រុសរបស់ខ្ញុំឈ្មោះ សំ អេាន ក៏ធ្លាប់បានរៀន និងបួសនៅក្នុងវត្តដូចឪពុករបស់ខ្ញុំដែរ។ គាត់បានស្នាក់នៅក្នុងវត្តរហូតដល់ឆ្នាំ១៩៧៥ ទើបគាត់សឹកហើយរៀបការ។ បន្ទាប់ពីគាត់រៀបការបានរយៈពេលប្រហែលជា៣ឬ៤ខែ យោធាខ្មែរក្រហមបានចូលមកគ្រប់គ្រង។*

*សមាជិកគ្រួសាររបស់ខ្ញុំទាំងអស់ត្រូវបានជម្លៀសចេញជាមួយគ្នា ប៉ុន្តែខ្មែរក្រហមបានបំបែកគ្រួសាររបស់យើង។ ដំបូងខ្ញុំបានចេញទៅខេត្តកោះកុង ប៉ុន្តែក្រោយមកខ្ញុំបានប្តូរទៅស្រែព្រៃ ស្ថិតនៅជិតភ្នំពេញ ដោយរស់នៅ*

ជាមួយឪពុក និងបងប្អូនរបស់ខ្ញុំរហូតដល់ខ្ញុំរៀបការ។

ទោះបីយ៉ាងណា ខ្ញុំមិនបានរស់នៅជុំគ្រួសារទេ។ ខ្មែរក្រហមបានអនុញ្ញាតឲ្យយើងជួបឪពុកម្តាយបានតែមួយម៉ោងប៉ុណ្ណោះ បន្ទាប់ពីយើងធ្វើការងាររចប់ ហើយបន្ទាប់មកយើងត្រឡប់មកកងរៀងៗខ្លួនវិញ។ ប្រសិនបើយើងត្រឡប់មកកងវិញមិនទាន់ម៉ោងទេ យើងនឹងទទួលរងទារុណកម្មមិនខាន។

អង្គការបានរៀបចំឲ្យខ្ញុំរៀបការជាមួយបុរសម្នាក់ឈ្មោះ ចាន់ សុខេង។ នៅថ្ងៃរៀបការនោះមាន៥គូ គឺជាប្រជាជនមូលដ្ឋានដែលស្ម័គ្រចិត្តក្រោកឈរដើម្បីធ្វើការប្តេជ្ញា ហើយក៏តំណាងឲ្យប្រជាជន៩០គូទៀតដែលបានរៀបការនៅថ្ងៃនោះដែរ។ អ្នកទាំងនេះបានឲ្យយើងស្រែកប្តេជ្ញាថា រស់នៅជាមួយគ្នាអស់មួយជីវិត ប៉ុន្តែការពិតមិនមាននរណាម្នាក់ចង់រៀបការទេ។ យើងគិតតែម្យ៉ាងតែប៉ុណ្ណោះ គឺធ្វើយ៉ាងណាគេចពីការយកទៅសម្លាប់ពីមួយថ្ងៃទៅមួយថ្ងៃ។ អង្គការបានបញ្ជូនឲ្យប្តីរបស់ខ្ញុំទៅរស់នៅក្នុងសហករណ៍នៅស្រុកផ្សេង បន្ទាប់ពីយើងរៀបការរួច។

ថ្ងៃមួយនៅពេលដែលខ្ញុំកំពុងដឹកទំនប់ មានមនុស្សវ័យចំណាស់ម្នាក់នៅក្នុងភូមិបានប្រាប់ខ្ញុំថា ឪពុករបស់ខ្ញុំបានស្លាប់។ ខ្ញុំមិនដឹងមូលហេតុនៃការស្លាប់របស់គាត់ទេ។ អ្នកភូមិខ្លះបាននិយាយថា ឪពុករបស់ខ្ញុំស្លាប់ដោយសារឈឺ ខណៈមានអ្នកភូមិខ្លះទៀតបាននិយាយថា ឪពុករបស់ខ្ញុំត្រូវអង្គការបញ្ជូនទៅសម្លាប់។



យ៉ា ទូច ត្រូវជាប្រពន្ធរបស់ ឡោ អ៊ុំ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សំ អោន បងប្រុសរបស់ អ៊ុំ សំអាត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រោយពីព្រឹត្តិការណ៍នេះបានកើតឡើងមិនយូរប៉ុន្មាន ខ្ញុំបានឃើញបងប្រុសរបស់ខ្ញុំ សំ អោន បររទេះគោ។ នៅក្នុងរទេះផ្ទុកទៅដោយត្រសក់យ៉ាងច្រើន ហើយគាត់បានហៅខ្ញុំឲ្យយកត្រសក់ខ្លះទុកហូប។ ខ្ញុំមិនហ៊ានយកត្រសក់ដែលបងខ្ញុំឲ្យទេ ព្រោះខ្ញុំភ័យខ្លាចអង្គការបានដឹងរឿងនេះហើយយកខ្ញុំទៅសម្លាប់។ ពីរបីថ្ងៃក្រោយមក មីងរបស់ខ្ញុំបានប្រាប់ថាបងប្រុសរបស់ខ្ញុំត្រូវបានបញ្ជូនទៅគុកស្អាង និងត្រូវយោធាវាយគាត់នៅតាមផ្លូវរហូត ដូច្នេះគាត់បានស្លាប់មុនពេលបញ្ជូនទៅដល់គុក។

នៅពេលដែលខ្ញុំដឹងថា ឪពុករបស់ខ្ញុំ និងបងប្រុសរបស់ខ្ញុំស្លាប់ ខ្ញុំលួចយំមិនឲ្យខ្មែរក្រហមដឹងឡើយ ហើយខ្ញុំមិនទៅធ្វើការពីរថ្ងៃ។ ខ្ញុំពិតជាសោកស្តាយខ្លាំងណាស់ដែលអង្គការបានអនុញ្ញាតឲ្យខ្ញុំទៅជួបឪពុករបស់ខ្ញុំ នៅពេលដែលគាត់បានស្លាប់បាត់បង់ជីវិតរួចទៅហើយ។

នៅពេលកងទ័ពវៀតណាមចូលមកប្រទេសកម្ពុជា យោធាខ្មែរក្រហមក៏បានរត់ចេញពីភូមិរបស់យើងចូលទៅរស់នៅក្នុងព្រៃវិញ ហើយខ្ញុំក៏បានវិលត្រឡប់មកភូមិកំណើតវិញជាមួយប្តីរបស់ខ្ញុំ។

**ប៉ាង ពិច័ន្ទ និង ខេនី ខករហ្គៀល**

រូបក្របមុខ៖

យី ធា សព្វថ្ងៃមានអាយុ៦៦ឆ្នាំ រស់នៅឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ បានរំឭករឿងរ៉ាវអតីតកាលរបស់គាត់ប្រាប់ ហ៊ាន ពិសី អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

បុរសម្នាក់កំពុងបង់សំណាញ់នៅបឹងអន្លង់វែង ឬបឹងតាម៉ុក ស្ថិតនៅក្នុងស្រុកអន្លង់វែងខេត្តឧត្តរមានជ័យ។

(អ៊ូច មករា/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 251, November 2020 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.